ក្រសួងអប់រំ យុវជន និងកីឡា

# ភាសាខ្មែរ

សម្រាប់លក់

# អាន-សរសេរ




២

ក្រសួងអប់រំ យុវជន និងកីឡា

# ភាសាខ្មែរ

## អាន-សរសេរ

## ថ្នាក់ទី ២

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ៣៩៤ អយក.ប្រក. ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០១២ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

បោះពុម្ពឆ្នាំ ២០១៧

ISBN 9-789-995-001-681

# អារម្ភកថា

សៀវភៅភាសាខ្មែរថ្នាក់ទី ២ **"អាន-សរសេរ"** នេះត្រូវបានរៀបចំឡើងដោយគណៈកម្មការនិពន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានការចូលរួមសហការពីនាយកដ្ឋានបឋមសិក្សា នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអ្នកពាក់ព័ន្ធមួយចំនួនដែលស្ថិតនៅក្រោមគម្រោងកម្មវិធីសកម្មភាពពង្រឹកការគាំទ្រវិស័យអប់រំនៅកម្ពុជា (ESSSUAP/GPE) ។

សៀវភៅនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រួលដល់ការរៀនអក្សររបស់សិស្សថ្នាក់ទី ២ ដោយមានការផ្សារភ្ជាប់មេរៀនមួយចំនួនពីថ្នាក់ទី ១ ។ ខ្លឹមសារសំខាន់ៗនៃឯកសារនេះ មានការរៀបចំតាមលំដាប់ពីតិចទៅច្រើន ពីងាយទៅលំបាក ដើម្បីជួយដល់ការរៀនអក្សររបស់សិស្សឱ្យចេះអាន (ចេះប្រកប)និងចេះសរសេរបានត្រឹមត្រូវដោយចាប់ផ្តើមដំបូង គឺរំឭកឡើងវិញ អំពីស្រៈ ព្យញ្ជនៈ ព្យញ្ជនៈផ្សំស្រៈ ប្រកប ស្រៈពេញតួ និងមេរៀនមួយចំនួនទៀតសម្រាប់តភ្ជាប់ពីមេរៀនផ្ញើជើង ព្យាង្គតម្រួត អមដោយកថាខណ្ឌខ្លីៗដែលសិស្សមិនទាន់ចេះស្ទាត់ពីថ្នាក់ទី ១ ព្រមទាំងខ្លឹមសារសៀវភៅថ្នាក់ទី ២ ដែលកំពុងដំណើរការរៀននិងបង្រៀនតាមរយៈការហាត់អាន សរសេរ និងធ្វើកិច្ចការផ្ទះ ។ ពិសេស គឺផ្តោតទៅលើការពង្រឹងសមត្ថភាពអាននិងសរសេរដែលជាមូលដ្ឋានគ្រឹះសម្រាប់ជួយឱ្យសិស្សមានសមត្ថភាពលើការអាននិងសរសេរភាសាខ្មែរ ។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារនេះនឹងបានជាប្រយោជន៍ចំពោះសិស្សានុសិស្សថ្នាក់ទី ២ សហគមន៍ មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ក៏ដូចជាសាលារៀន គ្រូបង្រៀនក្នុងការជួយបង្រៀនកុមារឱ្យចេះអាន ចេះសរសេរបានគ្រប់គ្នា ហើយសិស្សមានសមត្ថភាពអាននិងសរសេររឹងមាំនឹងអាចបន្តការសិក្សាទៅថ្នាក់បន្ទាប់ទៀតបានប្រកបដោយគុណភាពពិតប្រាកដ ។

**គណៈកម្មការនិពន្ធ**

# មាតិកា

**គណៈកម្មការគ្រប់គ្រងកម្មវិធី**
**លិខិតអនុញ្ញាត**..........
**អារម្ភកថា**..........
**មាតិកា**..........
**សេចក្តីណែនាំ**..........
**សេចក្តីផ្តើម**.......... I
១. ការប្រើប្រាស់ម៉ោងសិក្សា.......... II
២. វិធីសាស្ត្របង្រៀន.......... VI
៣. ការប្រើប្រាស់សម្ភារឧបទេស.......... VI
៤. ការវាយតម្លៃ.......... VII
៥. ការដាក់កិច្ចការផ្ទះ.......... VII
៦. លំនាំបង្រៀន.......... VIII
-លំនាំបង្រៀនរំឭកស្រៈនិស្ស័យនិងព្យញ្ជនៈ.......... VIII
-លំនាំបង្រៀនរំឭកព្យញ្ជនៈពួក អ អ៊ ផ្សំនឹងស្រៈ.......... VIII
-លំនាំបង្រៀនរំឭក ង៏ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ និង ប៊ ស៊ ហ៊ អ៊.......... IX
-លំនាំបង្រៀនរំឭកពាក្យប្រកបពួក អ និងពួក អ៊.......... XI
-លំនាំបង្រៀនរំឭកស្រៈពេញតួ.......... XII
-លំនាំបង្រៀនអាននិងសរសេរព្យញ្ជនៈផ្ញើជើងនិងព្យាង្គតម្រួត.......... XII
-លំនាំបង្រៀនអានអត្ថបទ.......... XIV
-លំនាំបង្រៀនសំណេរ.......... XVI
-លំនាំបង្រៀននិយាយ.......... XIX
-លំនាំបង្រៀនស្តាប់.......... XX
**មេរៀន**..........
-មេរៀនរំឭក(ស្រៈនិស្ស័យនិងព្យញ្ជនៈ ព្យញ្ជនៈផ្សំស្រៈ មូសិកទន្ត ត្រីសព្ទ ស្រៈពេញតួ ប្រកប) ០១
-មេរៀនព្យញ្ជនៈផ្ញើជើង ព្យាង្គតម្រួត.......... ០៩
-មេរៀន(អត្ថបទអំណាន សំណេរ ការស្តាប់ និងការនិយាយ).......... ៣២
**បទានុក្រម**.......... ១៨១

# សេចក្ដីណែនាំ

## សេចក្ដីផ្ដើម

ផ្អែកតាមលទ្ធផលសិក្សារបស់សិស្សប៉ុន្មានឆ្នាំកន្លងមកនេះ យើងឃើញថា សិស្សបឋមសិក្សាមានមូលដ្ឋាននៃការអាននិងសរសេរនៅមានកម្រិតទាបគួរឱ្យបារម្ភ ។ **ក្រសួងអប់រំ យុវជន និងកីឡា** បានរិះរកយុទ្ធវិធី ដើម្បីពង្រឹងគុណភាពនៃការអាននិងសរសេរឱ្យបានកាន់តែប្រសើរ ដោយធ្វើការសម្របសម្រួលវិធីសាស្ត្រ និងកែលម្អឯកសារសម្រាប់បង្រៀនភាសាខ្មែរឱ្យឆាប់ចេះ ក្នុងទិសដៅឆ្លើយតបទៅនឹងគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សានិងដើម្បីធ្វើឱ្យសម្រេចតាមស្តង់ដាកម្មវិធីសិក្សាថ្នាក់ទី ៣ ដែលបានចែងថា សិស្សថ្នាក់ទី ១ ដល់ទី ៣ ត្រូវមានបំណិនមូលដ្ឋានរឹងមាំផ្នែកភាសាខ្មែរនិងគណិតវិទ្យា ពោលគឺចេះអាន សរសេរ និងគិតលេខបានច្បាស់លាស់ ។

សៀវភៅសម្រាប់បង្រៀនអក្សរថ្នាក់ទី ២ថ្មីនេះ រៀបរៀងឡើងដើម្បីសម្រួលដល់ការរៀននិងការបង្រៀនភាសាខ្មែរដោយធ្វើបច្ចុប្បន្នភាពឱ្យស្របតាមបរិបទថ្មីៗ ដែលចាប់ផ្ដើមពី **ការរំឭក និងរៀនមេរៀនតភ្ជាប់មួយចំនួនដែលសិស្សមិនទាន់បានរៀននៅថ្នាក់ទី ១ ការរៀនស្រៈ ព្យញ្ជនៈ ព្យញ្ជនៈផ្សំនឹងស្រៈ ប្រកប ព្យញ្ជនៈធ្វើជើងនិងមេរៀនព្យាង្គតម្រួត**ដើម្បីឱ្យសិស្សមានគ្រឹះរឹងមាំមុននឹងអានអត្ថបទ ។ យោងតាមលទ្ធផលនៃការសាកល្បងពេញមួយឆ្នាំសិក្សាប្រកបដោយជោគជ័យនៅតាមសាលាគោលដៅនៃរាជធានី ខេត្តមួយចំនួន ក្រសួងអប់រំ យុវជន និងកីឡាប្រើប្រាស់សៀវភៅនេះ ដើម្បីអនុវត្តនៅទូទាំងប្រទេស ។

ដើម្បីជាជំនួយដល់គ្រូក្នុងការប្រើប្រាស់សៀវភៅនេះបានត្រឹមត្រូវ គណៈកម្មការបានរៀបចំសេចក្ដីណែនាំអមក្នុងសៀវភៅ ដោយផ្ដោតលើខ្លឹមសារសំខាន់ៗមួយចំនួនដូចជា ៖

១. ការប្រើប្រាស់ម៉ោងសិក្សា

២. វិធីសាស្ត្រ

៣. ការប្រើប្រាស់សម្ភារឧបទេស

៤. ការវាយតម្លៃ

៥. ការដាក់កិច្ចការផ្ទះ

៦. លំនាំបង្រៀន ។

## ១ . ការប្រើប្រាស់ម៉ោងសិក្សា

កម្មវិធីសិក្សាថ្មី តម្រូវឱ្យសិស្សសិក្សាភាសាខ្មែរចំនួន ១៣ម៉ោងក្នុងមួយសប្ដាហ៍ ហើយក្នុង១ម៉ោងសិក្សាមានរយៈពេល ៤០នាទី ។ ក្នុងមួយឆ្នាំសិក្សាសិស្សត្រូវរៀន ៣៨សប្ដាហ៍ ។ ដូច្នេះ ម៉ោងសម្រាប់រៀនភាសាខ្មែរស្មើនឹង ៤៩៤ម៉ោងសិក្សា ។

ខាងក្រោមនេះជាកាលវិភាគសម្រាប់មុខវិជ្ជាភាសាខ្មែរក្នុង ១សប្ដាហ៍ ៖

| ថ្ងៃ | ចំនួនម៉ោងសិក្សា |
|---|---|
| ចន្ទ | ០៣ម៉ោង |
| អង្គារ | ០២ម៉ោង |
| ពុធ | ០៣ម៉ោង |
| សុក្រ | ០២ម៉ោង |
| សៅរ៍ | ០៣ម៉ោង |
| សរុប | ១៣ម៉ោង |

ចំនួនម៉ោងបង្រៀននៅតាមទំព័រមេរៀននីមួយៗខុសៗគ្នា ។ ខ្លឹមសារមេរៀនខ្លះត្រូវបង្រៀន ៣ម៉ោង ខ្លះ ៤ម៉ោង ខ្លះ ៥ម៉ោងសិក្សា ខ្លះ ៦ម៉ោងសិក្សា ខ្លះ ៨ម៉ោងសិក្សាក៏មាន ។ អាស្រ័យហេតុនេះ មុនពេលរៀបចំការបង្រៀនអ្នកគ្រូ-លោកគ្រូគប្បីមើលតារាងបែងចែកម៉ោងសិក្សាខាងក្រោមជាមុនសិន ។

# តារាងបែងចែកម៉ោងសិក្សាសម្រាប់មេរៀន

| ល.រ | ខ្លឹមសារមេរៀន | ទំព័រ | ចំនួនម៉ោងសិក្សា | ល.រ | ខ្លឹមសារមេរៀន | ទំព័រ | ចំនួនម៉ោងសិក្សា |
|---|---|---|---|---|---|---|---|
| ១ | រំឭកស្រៈនិស្ស័យនិងព្យញ្ជនៈ | ១ | ០៥ ម៉ោង | ២ | រំឭកព្យញ្ជនៈពួក "អ" ពួក "អ៊" ផ្សំនិងស្រៈ | ២ | ១២ ម៉ោង |
| ៣ | រំឭកប្រកប | ៦ | ០៦ ម៉ោង | ៤ | រំឭកស្រៈពេញតួ | ៨ | ០៣ ម៉ោង |
| ៥ | ព្យញ្ជនៈផ្ញើជើង | ៩ | ៣៩ ម៉ោង | ៦ | ព្យាង្គតម្រួត | ២២ | ៣០ ម៉ោង |
| ៧ | អំណាននិងសំណេរ "បវេសនកាល" | ៣២ | ០៨ ម៉ោង | ៨ | អំណាននិងសំណេរ "ពេលចេញលេង" | ៣៥ | ០៨ ម៉ោង |
| ៩ | មេសូត្រនិងសំណេរ "ឆ្មាចង់ទៅរៀន" | ៣៨ | ០៨ ម៉ោង | ១០ | ការនិយាយនិងសំណេរ "ការណែនាំមិត្តឱ្យស្គាល់គ្នា" | ៤១ | ០៦ ម៉ោង |
| ១១ | អំណាននិងសំណេរ "សត្វក្រសារ" | ៤៤ | ០៨ ម៉ោង | ១២ | អំណាននិងសំណេរ "ការខិតខំរៀនសូត្រ" | ៤៧ | ០៨ ម៉ោង |
| ១៣ | ការស្ដាប់រឿងនិទាននិងសំណេរ "រឿងក្អែកការកូន" | ៥០ | ០៦ ម៉ោង | ១៤ | ចម្រៀងនិងសំណេរ "យើងទៅសាលារៀន" | ៥២ | ០៨ ម៉ោង |
| ១៥ | អំណាននិងសំណេរ "ការធ្វេសប្រហែស" | ៥៥ | ០៨ ម៉ោង | | | | |

## សរុបម៉ោងក្នុងត្រីមាសទី ១

- ម៉ោងសរុប : ១៣ម៉ x ១៣សប្ដាហ៍ = ១៦៩ ម៉ោងសិក្សា
- ម៉ោងបង្រៀន : = ១៦៣ ម៉ោងសិក្សា
- ម៉ោងនៅសល់ : = ០៦ ម៉ោងសិក្សា

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៦ | មេសូត្រនិងសំណេរ "ម្ដាយឪពុកខ្ញុំ" | ៥៨ | ០៨ ម៉ោង | ១៧ | អំណាននិងសំណេរ "ពេលភ្ញៀវមកលេងផ្ទះ" | ៦១ | ០៨ ម៉ោង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៨ | ការនិយាយនិងសំណេរ "ការប្រើពាក្យរបស់ខ្ញុំ របស់ឯង របស់យើង" | ៦៤ | ០៦ ម៉ោង | ១៩ | អំណាននិងសំណេរ "ឪពុកនិងកូនជីកលាទៅលក់" | ៦៧ | ០៨ ម៉ោង |
| ២០ | អំណាននិងសំណេរ "មិត្តល្អរបស់កូនឆ្មាបូបូ" | ៧១ | ០៨ ម៉ោង | ២១ | អំណាននិងសំណេរ "ការរៀនអក្សរផ្ទង់" | ៧៤ | ០៨ ម៉ោង |
| ២២ | ការនិយាយនិងសំណេរ "ការរៀបរាប់សមាជិកក្នុងគ្រួសារ" | ៧៧ | ០៦ ម៉ោង | ២៣ | ការស្ដាប់និងសំណេរ "រឿងកញ្ជ្រោងនិងកូនពពែ" | ៧៩ | ០៦ ម៉ោង |
| ២៤ | អំណាននិងសំណេរ "រឿងកូនទន្សាយនិងកូនឆ្មា" | ៨១ | ០៨ ម៉ោង | ២៥ | ចម្រៀងនិងសំណេរ "គ្រួសាររីករាយ" | ៨៤ | ០៨ ម៉ោង |
| ២៦ | អំណាននិងសំណេរ "ចម្ការរបស់ជីតាខ្ញុំ" | ៨៧ | ០៨ ម៉ោង | ២៧ | អំណាននិងសំណេរ "មេមាន់និងកូន" | ៩១ | ០៨ ម៉ោង |
| ២៨ | ការនិយាយនិងសំណេរ "ការរៀបរាប់ពីរូបរាងក្លិន ពណ៌ សូរសំឡេង និងរសជាតិ" | ៩៥ | ០៦ ម៉ោង | ២៩ | អំណាននិងសំណេរ "អាត្នោតគោខ្ញុំ" | ៩៨ | ០៨ ម៉ោង |
| ៣០ | អំណាន "ពាក្យបង្ហាញលក្ខណៈ វត្ថុ មនុស្ស សត្វ រុក្ខជាតិ" | ១០១ | ០៤ ម៉ោង | ៣១ | អំណាននិងសំណេរ "ទេសភាពវាលស្រែនៅរដូវវស្សា" | ១០២ | ០៨ ម៉ោង |
| ៣២ | អំណាននិងសំណេរ "អ្នកលក់ម្ហូបនិងសត្វស្វា" | ១០៥ | ០៨ ម៉ោង | ៣៣ | ចម្រៀងនិងសំណេរ "ការងារពុកម៉ែខ្ញុំ" | ១០៨ | ០៨ ម៉ោង |
| ៣៤ | អំណាននិងសំណេរ "មុខរបរអ្នកភូមិខ្ញុំ" | ១១២ | ០៨ ម៉ោង | ៣៥ | អំណាននិងសំណេរ "ដើមត្នោត" | ១១៥ | ០៨ ម៉ោង |
| ៣៦ | មេសូត្រនិងសំណេរ "កិច្ចការនៅសាលារៀន" | ១១៩ | ០៨ ម៉ោង | ៣៧ | អំណាននិងសំណេរ "រាជធានីភ្នំពេញ" | ១២២ | ០៨ ម៉ោង |

# សរុបម៉ោងក្នុងត្រីមាសទី ២

- ម៉ោងសរុប : ១៣ម៉ x ១៣សប្តាហ៍ = ១៦៩ ម៉ោងសិក្សា
- ម៉ោងបង្រៀន : = ១៦៤ ម៉ោងសិក្សា
- ម៉ោងនៅសល់ : = ០៥ ម៉ោងសិក្សា

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣៨ | អំណាននិងសំណេរ "ភូមិរុងរឿង" | ១២៥ | ០៨ ម៉ោង | ៣៩ | អំណាននិងសំណេរ "ផឹកទឹកកខ្វក់នាំឱ្យកើតជំងឺ" | ១២៨ | ០៨ ម៉ោង |
| ៤០ | អំណាននិងសំណេរ "សត្វលលកនិងស្រមោចខ្មៅ" | ១៣១ | ០៨ ម៉ោង | ៤១ | អំណាននិងសំណេរ "ចាបនិងដំរី" | ១៣៤ | ០៨ ម៉ោង |
| ៤២ | អំណាននិងសំណេរ "វត្ថុប្រើប្រាស់នៅក្នុងផ្ទះ" | ១៣៧ | ០៨ ម៉ោង | ៤៣ | ការស្តាប់រឿងនិទាន "ដឹងសងដឹង អំបែងសងអំបែង" | ១៤១ | ០៣ ម៉ោង |
| ៤៤ | អំណាននិងសំណេរ "បឹងទន្លេសាប" | ១៤២ | ០៨ ម៉ោង | ៤៥ | អំណាននិងសំណេរ "សង្គ្រាមរវាងគីង្គក់និងតាព្រហ្ម" | ១៤៥ | ០៨ ម៉ោង |
| ៤៦ | អំណាននិងសំណេរ "ដង្កូវនិងក្អែក" | ១៤៨ | ០៨ ម៉ោង | ៤៧ | មេសូត្រនិងសំណេរ "ច្បារដំណាំ" | ១៥២ | ០៨ ម៉ោង |
| ៤៨ | អំណាននិងសំណេរ "ផ្សារភូមិខ្ញុំ" | ១៥៥ | ០៨ ម៉ោង | ៤៩ | ការនិយាយនិងសំណេរ "ប្រៀបធៀបទីកន្លែងនិងវត្ថុ" | ១៥៨ | ០៦ ម៉ោង |
| ៥០ | អំណាននិងសំណេរ "មេក្រុចនិងពស់" | ១៦០ | ០៨ ម៉ោង | ៥១ | អំណាននិងសំណេរ "ក្មេងសុចរិត" | ១៦៣ | ០៨ ម៉ោង |
| ៥២ | អំណាននិងសំណេរ "ជីដូនជីតា" | ១៦៦ | ០៨ ម៉ោង | ៥៣ | អំណាននិងសំណេរ "សេចក្តីជូនដំណឹង" | ១៦៩ | ០៦ ម៉ោង |
| ៥៤ | អំណាននិងសំណេរ "រឿងសត្វឆ្មាត" | ១៧២ | ០៨ ម៉ោង | ៥៥ | អំណាននិងសំណេរ "ថ្ងៃបុណ្យចូលឆ្នាំ" | ១៧៥ | ០៨ ម៉ោង |
| ៥៦ | អំណាននិងសំណេរ "បុណ្យភ្ជុំបិណ្ឌ" | ១៧៨ | ០៨ ម៉ោង | | | | |

| សរុបម៉ោងក្នុងត្រីមាសទី ៣ | | |
|---|---|---|
| - ម៉ោងសរុប | : ១៣ម៉ x ១២សប្តាហ៍ | = ១៥៦ ម៉ោងសិក្សា |
| - ម៉ោងបង្រៀន | : | = ១៤៣ ម៉ោងសិក្សា |
| - ម៉ោងនៅសល់ | : | = ១៣ ម៉ោងសិក្សា |
| **សរុបម៉ោងក្នុងមួយឆ្នាំសិក្សា** | | |
| - ម៉ោងសរុប | : ១៣ម៉ x ៣៨សប្តាហ៍ | = ៤៩៤ ម៉ោងសិក្សា |
| - ម៉ោងបង្រៀន | : | = ៤៧០ ម៉ោងសិក្សា |
| - ម៉ោងនៅសល់ | : | = ២៤ ម៉ោងសិក្សា |

ដូច្នេះ សូមអ្នកគ្រូ លោកគ្រូ គប្បីរៀបចំចំនួនម៉ោងសិក្សាដែលបានកំណត់ខាងលើឱ្យមានលក្ខណៈទន់ភ្លន់និងមានប្រសិទ្ធភាព ។

## ២ . វិធីសាស្ត្របង្រៀន

មុននឹងចាប់ផ្តើមបង្រៀនមេរៀននីមួយៗ អ្នកគ្រូ លោកគ្រូ គប្បីយល់ពីគោលបំណងនៃការបង្រៀន និងរៀននៅថ្នាក់ទី ២ ដែលសិស្សត្រូវមានសមត្ថភាពស្តាប់ និយាយ ពិសេសសង្កត់ធ្ងន់លើការអាន-សរសេរឱ្យបានត្រឹមត្រូវ ។ ដូច្នេះ ការបង្រៀនត្រូវយកចិត្តទុកដាក់ទៅលើការអនុវត្តរបស់សិស្សដោយផ្ទាល់ ចៀសវាងគ្រូអនុវត្តហើយសិស្សអង្គុយចាំមើល ពោលគឺត្រូវមានសកម្មភាពឆ្លើយតបគ្នារវាងគ្រូនិងសិស្ស ពិសេសត្រូវអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលជាប្រចាំ ដើម្បីទទួលបានលទ្ធផលល្អប្រសើរ ។ ក្នុងការបង្រៀន គ្រូត្រូវចេះលើកទឹកចិត្តសិស្សមិនត្រូវនិយាយបន្តុះបង្អាប់សិស្សទេ ។ គ្រូត្រូវមានឥរិយាបថទន់ភ្លន់តែម៉ឺងម៉ាត់ និងចេះយោគយល់ អធ្យាស្រ័យរាល់កំហុសដែលសិស្សប្រព្រឹត្តដោយចេតនាក្តី ឬអចេតនាក្តី ។ គ្រូត្រូវមានភាពច្បាស់លាស់ក្នុងតួនាទីរបស់ខ្លួន ដែលត្រូវគ្រប់គ្រងសិស្ស និងត្រូវសួរខ្លួនឯងថា ថ្ងៃនេះសិស្សរបស់ខ្លួនត្រូវទទួលបាននូវចំណេះអ្វីខ្លះ ?

## ៣ . ការប្រើប្រាស់សម្ភារឧបទេស

ការបង្រៀនត្រូវប្រើប្រាស់សម្ភារឧបទេស ដើម្បីបញ្ជាក់នូវន័យរបស់ពាក្យនីមួយៗ ។ លោកគ្រូអ្នកគ្រូត្រូវឱ្យសិស្សហាត់ប្រើសម្ភារៈដោយខ្លួនឯងទៅតាមខ្លឹមសារមេរៀន ដើម្បីឱ្យសិស្សកាន់តែចេះអានសរសេរ និងយល់ច្បាស់នូវខ្លឹមសារមេរៀនដែលបានបង្រៀនរួច ។ កត្តាសំខាន់ទៀតនោះ មុននឹង

បង្រៀន គ្រូត្រូវរៀបចំកិច្ចតែងការបង្រៀនដោយកំណត់វត្ថុបំណងមេរៀន ផ្សារភ្ជាប់ទៅនឹងសម្ភារៈគ្រប់គ្រាន់សម្រាប់បង្រៀន ដូចជាអក្សរចល័ត (ព្យញ្ជនៈ ឬស្រៈ) តារាងព្យញ្ជនៈ១៨ពាពគួ និងជើង តារាងស្រៈនិស្ស័យ បណ្ណពាក្យ បណ្ណល្បះ ក្ដារខៀនធំ ឬក្ដារខៀនតូច ដែលអាចបិទភ្ជាប់អក្សរចល័ត ឬរូបភាពបានសម្រាប់សកម្មភាពក្នុងថ្នាក់ ព្រមទាំងអត្ថបទដែលត្រូវយកមកបង្រៀន ដោយត្រូវបានសរសេររួចជាស្រេចលើផ្ទាំងក្រដាសធំ ហើយបិទទុកនៅក្ដារខៀន ។

ក្រៅពីនេះ គ្រូ សិស្សអាចប្រើកាយវិការជាក់ស្ដែងជាច្រើនទៀតតម្រូវទៅតាមពាក្យដែលត្រូវយកមកបង្រៀននិងរៀន ។

## ៤ . ការវាយតម្លៃ

នៅពេលបង្រៀនមេរៀនចប់ គ្រូត្រូវធ្វើការវាយតម្លៃ ដើម្បីវាស់ស្ទង់លទ្ធផលនៃការសិក្សារបស់សិស្ស ។ ការវាយតម្លៃ ត្រូវធ្វើជាប្រចាំតាមដំណាក់រហូតបញ្ចប់ និងការប្រឡងប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ។ ការវាយតម្លៃត្រូវឱ្យសមស្របទៅនឹងកម្រិតលទ្ធផលសិក្សាថ្នាក់ទី ២ ដូចជាការវាយតម្លៃអំណាន សិស្សត្រូវអានឱ្យបានត្រឹមត្រូវនិងយល់ន័យ ដោយចៀសវាងការប្រកបក្នុងពេលអានអត្ថបទ ។ ចំណែកការវាយតម្លៃសំណេរត្រូវឱ្យសិស្ស**សរសេរតាមអានចម្លង** ដោយសរសេរអក្សរទាំងអស់នៃអក្ខរក្រម (ក ខ ...អ) សរសេរកន្សោមពាក្យងាយៗ និងសរសេរចំណងជើងរូបភាព ។ ល ។

## ៥ . ការដាក់កិច្ចការផ្ទះ

ការដាក់កិច្ចការផ្ទះ ជាមធ្យោបាយមួយសំខាន់ សម្រាប់ជួយសិស្សឱ្យឆាប់ចេះអាន សរសេរ និងជាទម្លាប់មួយឱ្យសិស្សចេះរៀនដោយខ្លួនឯង និងចូលចិត្តរៀន ។ គ្រូគប្បីដាក់កិច្ចការឱ្យសិស្សជាប្រចាំនិងរាល់ថ្ងៃ ។

កិច្ចការផ្ទះសម្រាប់សិស្សថ្នាក់ទី ២ក្នុងមេរៀនថ្មីអាចធ្វើបានដូចជា ៖

- លំហាត់ដែលមាននៅបញ្ចប់មេរៀននីមួយៗ
- មុខវិជ្ជាអក្សរផ្ចង់ដែលគ្រូដាក់ឱ្យតាមលំដាប់ មានព្យញ្ជនៈ ស្រៈ ព្យាង្គ ពាក្យ និងល្បះ
- ឱ្យសិស្សរៀនមេរៀនថ្មីត្រៀមទុកជាមុន
- ពាក្យ ឬឃ្លាណាដែលគ្រូមិនបានបង្រៀននៅក្នុងថ្នាក់ គ្រូត្រូវដាក់កិច្ចការផ្ទះបន្ថែមឱ្យសិស្សធ្វើ តែគ្រូមិនត្រូវភ្លេចកែឡើងវិញនៅថ្ងៃរៀនបន្ទាប់នោះឡើយ ។ គ្រប់កិច្ចការទាំងអស់ដែលដាក់ឱ្យសិស្សធ្វើ គ្រូត្រូវត្រួតពិនិត្យនិងកែឱ្យបានទៀងទាត់ ។

## ៦ . លំនាំបង្រៀន

### ៦.១ លំនាំបង្រៀនរំឭកស្រៈនិស្ស័យ

- គ្រូលើកស្រៈចល័តបង្ហាញសិស្ស ហើយសួរសិស្ស តើនេះជាស្រៈអ្វី ? គ្រូសរសេរស្រៈលើក្ដារខៀន ។
- ឱ្យសិស្សអានស្រៈនោះទាំងអស់គ្នា ។ ចំពោះស្រៈផ្សេងទៀតគ្រូធ្វើដូចស្រៈទី ១ដែរ ដោយមិនគិតពីលំដាប់ ។
- គ្រូបិទតារាងស្រៈនិស្ស័យ រួចគ្រូចង្អុលស្រៈតាមលំដាប់ ហើយឱ្យសិស្សអានឱ្យបានច្បាស់ៗ ។ គ្រូចង្អុលបញ្ច្រាសមកវិញ ហើយឱ្យសិស្សអានពីស្រៈ ◌ោះ ⟶ ◌ា ។
- គ្រូហៅស្រៈមិនតាមលំដាប់ឱ្យសិស្សសរសេរលើក្ដារឆ្នួន ។
- គ្រូចែកសិស្សជាក្រុមតូចៗ ។ ឱ្យសិស្សអានស្រៈដោយប្រើសៀវភៅរបស់គេ តាមក្រុមដោយដំបូងអានរួមគ្នា ។ លើកទី ២ម្នាក់ចង្អុលឆ្លាស់ចុះឡើង អ្នកឯទៀតអាន រួចដូរវេនគ្នាចង្អុល ។

### ៦.២ លំនាំបង្រៀនរំឭកព្យញ្ជនៈ

- គ្រូលើកព្យញ្ជនៈចល័តបង្ហាញសិស្ស ហើយសួរ តើនេះជាអក្សរអ្វី ?
- ឱ្យសិស្សអានព្យញ្ជនៈនោះ រួចសរសេរលើក្ដារឆ្នួន ។ ចំពោះព្យញ្ជនៈផ្សេងទៀត គ្រូធ្វើដូចព្យញ្ជនៈទី ១ ដែរ ។
- គ្រូបិទតារាងព្យញ្ជនៈ ហើយគ្រូចង្អុលឱ្យសិស្សអានតាមលំដាប់ រួចបញ្ច្រាសមកវិញ ។
- ហៅព្យញ្ជនៈឆ្លាស់ចុះឡើងឱ្យសិស្សសរសេរលើក្ដារឆ្នួន ។
- ចែកសិស្សជាក្រុមតូចៗ ហើយឱ្យពួកគេអានសៀវភៅដោយម្នាក់ចង្អុលព្យញ្ជនៈឆ្លាស់ចុះឡើង អ្នកឯទៀតអាន រួចដូរវេនគ្នាចង្អុល ។

### ៦.៣ លំនាំបង្រៀនរំឭកព្យញ្ជនៈ ពួក អ ពួក អ៊ ផ្សំនឹងស្រៈ

- គ្រូលើកអក្សរចល័ត ក រួចសួរ តើនេះជាអក្សរអ្វី ? គ្រូបង្ហាញស្រៈ ◌ា រួចសួរដូចមុន ។
- គ្រូយកស្រៈ ◌ា ផ្សំនឹង ក ឱ្យសិស្សអាន ។ គ្រូសួរតើ "កា" មានអក្សរអ្វីខ្លះ ?
- គ្រូបង្ហាញរូបភាពកោះ រួចសួរសិស្ស តើនេះជារូបភាពអ្វី ? ឱ្យសិស្សថាពាក្យនោះ ៣-៤នាក់ រួចថាទាំងអស់គ្នា ។
- គ្រូបង្ហាញបណ្ណពាក្យរួចសរសេរពាក្យលើក្ដារខៀន ឱ្យសិស្សអាន ។

- គ្រូសួរសិស្ស ៖ តើពាក្យ "កោះ" មានព្យញ្ជនៈនិងស្រៈអ្វីខ្លះ ? គ្រូប្រើអក្សរចល័តបំបែកពាក្យ រួចផ្សំពាក្យឱ្យសិស្សអាន ។
- គ្រូអានពាក្យឱ្យសិស្សអានតាម ។ ចំពោះពាក្យផ្សេងទៀត ធ្វើតាមលំនាំបង្រៀនពាក្យ "កោះ" ដែរ តែគ្រូចង្អុលពាក្យឱ្យសិស្សអានជាក្រុមរួម រួចក្រុមតូចៗ ។
- គ្រូឱ្យសិស្សសរសេរពាក្យលើក្ដារខៀន ។

**បញ្ជាក់ :** មេរៀននេះជាមេរៀនរំឭក គ្រូមិនគប្បីបង្រៀនព្យាង្គទៀតទេ ។ គ្រូគប្បីបង្រៀនតែពាក្យគន្លឹះមួយចំនួន ហើយឱ្យសិស្សហ្វឹកហាត់អានពាក្យ ល្បះ តែម្ដងមិនចាំបាច់បង្រៀនល្បះទេ ។

- គ្រូចែកសិស្សជាក្រុមតូចៗ ។ ឱ្យសិស្សហ្វឹកហាត់អានពាក្យ ល្បះក្នុងសៀវភៅតាមក្រុមដោយប្រើសៀវភៅអានរួមគ្នាសម្រាប់ក្រុមនីមួយៗ ។
- ឱ្យសិស្សអានសៀវភៅជាដៃគូ ដោយម្នាក់ចង្អុល ម្នាក់អាន រួចដូរវេនគ្នា ។
- ឱ្យសិស្សអានសៀវភៅជាបុគ្គល គ្រូដើរជួយសិស្សដែលជួបការលំបាក ។

## ៦.៤ លំនាំបង្រៀនរំឭក ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉

- គ្រូយកផ្ទាំងព្យញ្ជនៈដាក់ផ្គូគ្នា រួចចង្អុលអក្សរ ង ញ ប ម យ រ វ ម្ដងមួយតួៗ រួចសួរសិស្ស ៖ តើនេះជាអក្សរអ្វី ?

| | |
|---|---|
| ង | ង៉ |
| ញ | ញ៉ |
| ប | ប៉ |
| ម | ម៉ |
| យ | យ៉ |
| រ | រ៉ |
| វ | វ៉ |

- គ្រូចង្អុលម្ដងមួយតួៗ ង ង៉ និងបញ្ចេញសំឡេងឱ្យសិស្សស្ដាប់ ។ គ្រូនិងសិស្សអានជាមួយគ្នា រួចសិស្សអានខ្លួនឯងជាក្រុមតូចៗ ។ *ឧទាហរណ៍ :* ង ង៉ ... ។
- គ្រូបង្រៀនពាក្យដោយធ្វើតាមលំនាំបង្រៀនពាក្យក្នុងមេរៀនព្យញ្ជនៈផ្សំស្រៈមុនៗដែរ ។
- គ្រូឱ្យសិស្សសរសេរពាក្យលើក្ដារឆ្នួន ។
- ឱ្យសិស្សហ្វឹកហាត់អានសៀវភៅជាដៃគូ ដោយដំបូងអានរួមគ្នា បន្ទាប់មកអានម្ដងម្នាក់ ។
- ឱ្យសិស្សអានសៀវភៅជាបុគ្គល ។

*ចំណាំ :*

- មូសិកទន្ត ឬធ្មេញកណ្ដុរ (៉) ជាវណ្ណយុត្ត សម្រាប់ប្រើសម្លាប់បំបែរសំឡេងព្យញ្ជនៈ ពួក អ៊ ឱ្យទៅជាពួក អ ។
- ចំពោះស្រៈ ◌ួ ◌ើ ◌ៀ មិនចាំបាច់ប្រើសញ្ញាមូសិកទន្ត (៉)ទេ ព្រោះការប្រើសញ្ញានេះ ក៏សូរមិនដូរដែរ គឺដូចសំឡេងពួក អ៊ ជានិច្ច ។

## ៦.៥ លំនាំបង្រៀនរំពូក ប៊ ស៊ ហ៊ អ៊

- គ្រូត្រូវយកផ្ទាំងព្យញ្ជនៈដាក់ផ្គូគ្នា រួចចង្អុលអក្សរ ប ស ហ អ ម្ដងមួយគូ រួចសួរសិស្ស ៖ តើនេះជាអក្សរអ្វី ?

| | |
|---|---|
| ប | ប៊ |
| ស | ស៊ |
| ហ | ហ៊ |
| អ | អ៊ |

- គ្រូចង្អុលម្ដងមួយតួៗ (អ អ៊) និងបញ្ចេញសំឡេងឱ្យសិស្សស្ដាប់ ។ គ្រូនិងសិស្សអានជាមួយគ្នា រួចសិស្សអានខ្លួនឯងជាក្រុមតូចៗ ។ *ឧទាហរណ៍* ប ប៊ ។
- គ្រូបង្រៀនពាក្យ ដោយធ្វើតាមលំនាំបង្រៀនព្យញ្ជនៈពួក អ៊ ផ្សំស្រៈ ។
- គ្រូនាំសិស្សអានពាក្យ ៖ សាប៊ូ កៅស៊ូ ប៉ាហ៊ី ភាស៊ី ដោយប្រកប ។
  សា+ប៊ អ៊ូ ប៊ូ សាប៊ូ កៅ+ស៊ អ៊ូ ស៊ូ កៅស៊ូ ប៉ា+ហ៊ អ៊ី ហ៊ី ប៉ាហ៊ី ភា+ស៊ អ៊ី ស៊ី ភាស៊ី
- គ្រូឱ្យសិស្សសរសេរពាក្យលើក្ដារឆ្នួន បន្ទាប់មកអានដោយមិនបាច់ប្រកប ។
- ឱ្យសិស្សហ្វឹកហាត់អានជាដៃគូដោយប្រើសៀវភៅតែមួយរួមគ្នា រួចម្នាក់ចង្អុលម្នាក់អាន ហើយដូរវេនគ្នាចង្អុល ។ គ្រូតាមដាននិងជួយសិស្ស ។
- ឱ្យសិស្សអានសៀវភៅជាបុគ្គល ។ គ្រូគប្បីដើរជួយសិស្សជួបការលំបាក ។

*ចំណាំ :*

- ត្រីសព្ទ ឬសញ្ញាសក់ក ឬសញ្ញាអ៊ិ (៊)ជាវណ្ណយុត្ត សម្រាប់ប្រើលើព្យញ្ជនៈ ៤តួគឺ ៖ ប ស ហ អ ឱ្យទៅជាពួក អ៊ ។
- ចំពោះស្រៈ ួ ឿ ៀ មិនចាំបាច់ប្រើសញ្ញាត្រីសព្ទ (៊)ទេ ព្រោះការប្រើសញ្ញានេះ ក៏មិនបានធ្វើឱ្យសូរដូរដែរ ។

## ៦.៦ លំនាំបង្រៀនរំឭកពាក្យប្រកប ( ពួក អ និងពួក អ៊ )

- គ្រូបង្ហាញរូបភាព ឬសម្ភារៈជាក់ស្ដែង រួចសួរ តើនេះជាអ្វី ?
- គ្រូបង្ហាញបណ្ណពាក្យរួចសរសេរពាក្យលើក្ដារខៀនឱ្យសិស្សអាន ។
- គ្រូសួរសិស្ស ៖ តើពាក្យ ... មានព្យញ្ជនៈនិងស្រៈអ្វីខ្លះ ? គ្រូប្រើអក្សរចល័តបំបែកផ្សំពាក្យខ្លះៗឱ្យសិស្សអាន ។ ចំពោះពាក្យផ្សេងទៀតធ្វើតាមលំនាំពាក្យទី ១ដែរ ប៉ុន្តែគ្រូមិនគប្បីបង្រៀនគ្រប់ពាក្យទេ តែគប្បីបង្រៀនពាក្យគន្លឹះដែលមានក្នុងល្បះ ដើម្បីឱ្យសិស្សអាចអានល្បះបាននៅពេលឱ្យគេហ្វឹកហាត់អានតាមក្រុម ។

  *ឧទាហរណ៍ :* កា មកផ្សំជាមួយនឹង ក រួចបញ្ជាក់ ៖

  - កា និង ក ⟶ កាក
  - ច និង ក ⟶ ចក

- គ្រូអានពាក្យទាំងអស់ដែលបានរៀនរួចឱ្យសិស្សអានតាម ។
- ឱ្យសិស្សអានពាក្យនីមួយៗឡើងវិញ ។
- ឱ្យសិស្សធ្វើអក្ខរាវិរុទ្ធ គ្រប់ពាក្យដែលបានរៀនរួច ។
- គ្រូឱ្យសិស្សសរសេរពាក្យលើក្ដារឆ្នួន ។
- ឱ្យសិស្សហ្វឹកហាត់អានពាក្យ ល្បះតាមក្រុមតូចៗរួមគ្នា ដោយប្រើសៀវភៅតែមួយរួមគ្នា ។
- ឱ្យសិស្សអានសៀវភៅជាដៃគូដោយលើកទី ១ អានរួមគ្នា លើកទី ២ អានម្នាក់ម្ដង ។
- ឱ្យសិស្សអានសៀវភៅជាបុគ្គល ។ គ្រូគប្បីដើរជួយសិស្សរៀនយឺត ។

  *កំណត់សម្គាល់ :*

  - គ្រូត្រូវចៀសវាងចំពោះការបណ្ដោយឱ្យសិស្សថា ក អា កា នេះទៀត ពីព្រោះបើបង្រៀនមកដល់មេរៀននេះ សិស្សបានរៀនផ្សំព្យញ្ជនៈជាមួយនឹងស្រៈរួចស្រេចទៅហើយមិនចាំបាច់ថាម្ដងទៀតទេ គឺទម្លាប់ឱ្យថា កា ចិ លោ វៀ ...តែម្ដង (មានប្រយោជន៍ដល់ពេលអានអត្ថបទសិស្សមិនបាច់ប្រកបទៀត) ។

## ៦.៧ លំនាំបង្រៀនវំពុកស្រះពេញតួ

- គ្រូបង្ហាញស្រះពេញតួចល័តម្ដងមួយៗ ដោយមិនតាមលំដាប់ រួចឱ្យសិស្សអានរហូតដល់គ្រប់ ១៥តួ។ គ្រូបិទតារាងស្រះពេញតួ ឬសរសេរលើក្ដារខៀន។
- គ្រូចង្អុលស្រះពេញតួមិនតាមលំដាប់ រួចឱ្យសិស្សអាន រួចសរសេរលើក្ដារឆ្នួន។ គ្រូអានស្រះពេញតួតាមលំដាប់ឱ្យសិស្សអានតាម។
- គ្រូបង្ហាញរូបឪពុក រួចសួរសិស្សថារូបអ្វី ? គ្រូអាចសាកល្បងឱ្យសិស្សម្នាក់ឡើងសរសេរពាក្យក្រោមរូបឪពុក សិស្សឯទៀតសរសេរលើក្ដារឆ្នួន។ បើសិស្សសរសេរមិនបានគ្រូសរសេរ។ គ្រូអាចបិទរូបផ្សេងទៀត ប្រសិនបើមាន រួចធ្វើរបៀបនេះដដែល។
- ឱ្យសិស្សបើកសៀវភៅអានពាក្យ ល្បះ តាមក្រុមតូចៗ ឬដៃគូ។
- ហៅសិស្សរៀនយឺត អានពាក្យ ឬល្បះខ្លះៗដោយប្រើសៀវភៅរបស់គេ។

## ៦.៨ លំនាំបង្រៀនអាននិងសរសេរព្យញ្ជនៈផ្ញើជើង

- គ្រូបង្ហាញអក្សរចល័ត ខ រួចសួរ ៖ តើនេះជាអក្សរអ្វី ? គ្រូបង្ហាញជើង ◌្ជ រួចសួរតើនេះជាជើងអក្សរអ្វី ? គ្រូយក ខ ដាក់លើជើង ◌្ជ រួចឱ្យសិស្សអាន ឬគ្រូអាន (ខ ◌្ជ ខ្ជ)ឱ្យសិស្សថាតាមទាំងអស់គ្នា។ សិស្សថាតាមជាក្រុមតូចៗ។
- គ្រូយកស្រះ ◌ា ◌ិ ◌ី ◌ឹ ◌ឺ មកផ្សំជាមួយ ខ្ជ ម្ដងមួយៗ ហើយឱ្យសិស្សអានជាក្រុម ឬជាបុគ្គល។

  ចំពោះព្យញ្ជនៈ ខ ផ្សំនឹងជើងផ្សេងទៀត គ្រូគប្បីធ្វើដូច ខ ផ្សំនឹងជើង ◌្ជ ដែរ។
- គ្រូលើករូបភាព ឬសម្ភារៈជាក់ស្ដែងបង្ហាញសិស្ស ដើម្បីបង្រៀនពាក្យ ខ្ជាយ។ ឱ្យសិស្សប្រាប់ឈ្មោះរូបភាព ឬវត្ថុនោះ។
- គ្រូបង្ហាញបណ្ណពាក្យ និងអានពាក្យឱ្យសិស្សថាតាម។
- នាំសិស្សវិភាគពាក្យដោយប្រើអក្សរចល័ត ហើយសួរថា ៖ តើពាក្យ ខ្ជាយ មានអក្សរអ្វីខ្លះ ? គ្រូសរសេរពាក្យនៅលើក្ដារខៀន ៖
- ឱ្យសិស្សសរសេរពាក្យ "ខ្ជាយ"នៅលើក្ដារឆ្នួន។ ចំពោះពាក្យផ្សេងទៀត គ្រូត្រូវបង្រៀនដូចពាក្យ ខ្ជាយ ដែរ។ គ្រូគប្បីបង្រៀនពាក្យថ្មីដែលមានក្នុងល្បះ ហើយមិនបាច់បង្រៀនល្បះទេ។
- គ្រូអានពាក្យឱ្យសិស្សអានតាម។ គ្រូអានពាក្យ ឱ្យសិស្សចង្អុលពាក្យនៅក្នុងសៀវភៅរបស់ពួកគេ និងអានពាក្យនោះ។

- ឱ្យសិស្សអានសៀវភៅតាមក្រុមតូចៗ ឬជាដៃគូ ។ (បើអានតាមក្រុម ត្រូវឱ្យសិស្សម្នាក់ចង្អុល អ្នកឯទៀតអាន រួចដូរគ្នាចង្អុល) ។ គ្រូតាមដាននិងជួយសិស្ស ។
- ឱ្យសិស្សអានសៀវភៅជាបុគ្គល ។ គ្រូជួយសិស្សជួបការលំបាក ។

## ៦.៩ លំនាំបង្រៀនអាននិងសរសេរពាក្យព្យាង្គតម្រួត

- គ្រូបង្ហាញសម្ភារៈជាក់ស្តែង ឬរូបភាពដើម្បីបំផុសរកពាក្យ ។
- គ្រូថាពាក្យឱ្យសិស្សថាតាមចំនួន ២-៣ដង ។ គ្រូបង្ហាញបណ្ណពាក្យ ហើយសួរថា តើនេះជាពាក្យអ្វី ?
- គ្រូសរសេរពាក្យនោះនៅក្តារខៀនដោយប្រើដីសពណ៌ ។ គ្រូអានពាក្យនោះឱ្យសិស្សថាតាមជាក្រុមតូចៗ ។
- គ្រូអានពាក្យ "កង្កែប" ដោយបំបែកជាពីរព្យាង្គយឺតៗ ។ ***ឧទាហរណ៍*** [ កង់-កែប ] ២-៣ដង ។ គ្រូសួរសិស្ស តើពាក្យ "កង្កែប" មានប៉ុន្មានម៉ាត់ ឬប៉ុន្មានព្យាង្គ ? អ្វីខ្លះ ? បើសិស្សមិនអាចឆ្លើយបាន គ្រូប្រាប់ថា "កង្កែប" មាន ២ព្យាង្គ គឺ [ កង់ ] និង [ កែប ] ។

  កង្កែប = [ កង់ ] [ កែប ] ព្យាង្គទី ១ កង់ , ព្យាង្គទី ២ កែប ,
- គ្រូនាំសិស្សអាន ក និង ង ត្រូវអានថា កង់ ជើង ្ក ត្រូវអានដូចជាព្យញ្ជនៈ ក ដែរ ។ ដូចនេះ កង្កែប ត្រូវអានថា ក និង ង កង់ ជើង ក ស្រៈ ែ◻ និង ប អានថា កែប ។ សួរសិស្សថា ៖ តើពាក្យ កង្កែប មានអក្សរអ្វីខ្លះ ? ***ចម្លើយ :*** កង្កែប មាន ក ង ជើង ្ក ស្រៈ ែ◻ និង ប ។
- ឱ្យសិស្សសរសេរពាក្យ កង្កែប នៅលើក្តារឆ្នួន ។
- គ្រូបន្តបង្រៀនពាក្យគន្លឹះផ្សេងទៀតដែលមាន ង្ខ ង្គ ង្ឃ មួយពាក្យៗដោយមិនចាំបាច់បង្រៀនគ្រប់ពាក្យដែលមានក្នុងសៀវភៅនោះទេ ។
- គ្រូអានពាក្យឱ្យសិស្សអានតាម ។
- គ្រូចង្អុលពាក្យឱ្យសិស្សអានជាក្រុមតូចៗ រួចអានទាំងអស់គ្នា ។
- គ្រូចែកសិស្សជាក្រុមតូចៗ ឬដៃគូ ។ ឱ្យសិស្សអានសៀវភៅនៅតាមក្រុម ដោយម្នាក់ចង្អុល អ្នកឯទៀតអានរួចដូរវេនគ្នា ។ គ្រូដើរមើល និងជួយសិស្សជួបការលំបាក ។
- គ្រូហៅពាក្យក្នុងសៀវភៅឱ្យសិស្សចង្អុលនិងអានពាក្យនោះ រួចសរសេរលើក្តារឆ្នួនម្តងមួយៗ ។ គ្រូហៅល្បះឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅដោយយឺតៗ រួចឱ្យសិស្សអានល្បះនោះឡើងវិញនៅពេលសរសេររួច ។

*ចំណាំ :*

- គ្រប់មេរៀនបើមានពាក្យ ឬឃ្លាច្រើន គ្រូមិនត្រូវបង្រៀនទាំងអស់នោះទេ គឺដកយកតែពាក្យគន្លឹះ ដូចជា ពាក្យមាន ង្ក ង្ខ ង្គ ង្ឃ មួយពាក្យៗ ហើយបន្ថែមពាក្យថ្មីក្នុងល្បះ ដើម្បីឱ្យសិស្សមានពេលហ្វឹកហាត់ ។ ពាក្យ ឬឃ្លានៅសល់ ត្រូវទុកឱ្យសិស្សហ្វឹកហាត់អានបន្ថែម ។
- គ្រប់មេរៀនមិនត្រូវបង្រៀនអាននិងសរសេរនៅថ្ងៃផ្សេងគ្នាទេ គឺត្រូវបង្រៀននៅថ្ងៃជាមួយគ្នា ។ គ្រូគប្បីបង្រៀនអាន រួចសរសេរពាក្យនោះតែម្ដង ។

*សម្គាល់ :* ន្ត្រ ន្ទ្រ ត្រូវអានដូចខាងក្រោម ៖

- ន ជើង ត ជើង រ  ន ជើង ទ ជើង រ ។
- ទន្ទ្រាន = ទ និង ន ទន់ ទ ជើង ្រ ទ្រ ទ្រ អា ទ្រា និង ន ទ្រាន ⟶ ទន្ទ្រាន ។
- កន្ត្រៃ = ក និង ន កន់ ត ជើង ្រ ត្រ ត្រ អៃ ត្រៃ ⟶ កន្ត្រៃ ។

## ៦.១០ លំនាំបង្រៀនអានអត្ថបទ

លំនាំបង្រៀនអានមានបំណងបណ្ដុះបណ្ដាលសិស្សលើបំណិនអាន ពាក្យ ឃ្លា ល្បះ រហូតដល់ការអានអត្ថបទបានត្រឹមត្រូវមិនទាក់ ឬរដាក់រដុបនិងដើម្បីជួយដល់ការសរសេរបានត្រឹមត្រូវច្បាស់លាស់ថែមទៀតផង ។

### ក. ការចាប់ផ្ដើមមេរៀន

- ការប្រើសំណួរបំផុស : គ្រូសួរសំណួរបំផុសមួយចំនួន ដើម្បីស្ទាបស្ទង់ចំណេះដឹងឬបទពិសោធរបស់សិស្សទាក់ទងនឹងមេរៀនថ្មី ។
- គ្រូឱ្យសិស្សមើលរូបភាព រួចគ្រូសួរសំណួរលើរូបភាព ។
- ការអានលើកទី ១ :
  - គ្រូឱ្យសិស្សអានអត្ថបទរៀងៗខ្លួនដោយស្ងៀមស្ងាត់ ។
  - គ្រូឱ្យសិស្សម្នាក់ៗរកពាក្យដែលគេមិនទាន់ចេះអាននិងពិបាកយល់ន័យ ហើយប្រាប់គ្រូឱ្យសរសេរពាក្យទាំងនោះនៅលើក្ដារខៀន ។
- ការរៀនពាក្យ : គ្រូនាំសិស្សរៀនពាក្យពិបាកក្នុងសៀវភៅសិស្សរួមមាន ៖
  - អំណានពាក្យ
  - ពន្យល់ពាក្យ
  - ពាក្យផ្ទុយ
  - ពាក្យន័យដូច

*បញ្ជាក់ :* ចំពោះមេរៀនដំបូង នៅពេលសិក្សាពាក្យផ្ទុយ និងពាក្យន័យដូច គ្រូត្រូវប្រាប់បញ្ញត្តិពាក្យផ្ទុយ និងពាក្យន័យដូចទៅសិស្សជាមុន ៖

- ពាក្យផ្ទុយ គឺជាពាក្យដែលមានន័យផ្ទុយគ្នា ។
- ពាក្យន័យដូច គឺជាពាក្យដែលមានន័យដូចគ្នា តែសរសេរខុសគ្នា ។

- ក្នុងករណីមានពាក្យពិបាកផ្សេងទៀតនៅក្នុងអត្ថបទ ហើយមិនមានប្រាប់ក្នុងការរៀនពាក្យ គ្រូគប្បីបង្រៀនដោយអានពាក្យទាំងនោះឱ្យសិស្សស្ដាប់និងអានតាម ។
- គ្រូហៅពាក្យម្ដងមួយៗឱ្យសិស្សសរសេរលើក្ដារឆ្នួន ។
- គ្រូពន្យល់ន័យរបស់ពាក្យ ដោយប្រើប្រាស់រូបភាព វត្ថុជាក់ស្ដែងជាជំនួយ លើកឧទាហរណ៍ ធ្វើការប្រៀបធៀប ឬធ្វើកាយវិការ ដើម្បីបញ្ជាក់ន័យរបស់ពាក្យទៅតាមប្រភេទពាក្យនីមួយៗ ។
- ការអានលើកទី ២ :
  - គ្រូអានអត្ថបទមួយចប់ដោយមានការលើកដាក់សំឡេងជាគំរូ ។ សិស្សម្នាក់ៗផ្ទៀងតាមដោយប្រើអត្ថបទនៅក្នុងសៀវភៅរបស់គេ ។
  - គ្រូនិងសិស្សអានអត្ថបទជាមួយគ្នា ។
  - ចែកសិស្សជាក្រុមតូចៗ ។ ឱ្យសិស្សតាមក្រុមអានរួមគ្នាដោយប្រើសៀវភៅតែមួយ ។
  - ឱ្យសិស្សអានសៀវភៅជាដៃគូរួមគ្នា ។
  - ឱ្យសិស្សអានសៀវភៅជាបុគ្គល ។
  - ឱ្យសិស្សអានសំណួរក្នុងសៀវភៅជាមុនសិន មុននឹងអានអត្ថបទ ។
  - ឱ្យសិស្សអានអត្ថបទដោយស្ងៀមស្ងាត់ម្ដងទៀត ដើម្បីយល់ខ្លឹមសារមេរៀន ។
  - ឱ្យសិស្សឆ្លើយសំណួរនៅក្នុងសៀវភៅ (ពេលឆ្លើយសំណួរត្រូវឱ្យសិស្សបិទសៀវភៅ) ។ បើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបាន គ្រូត្រូវឱ្យសិស្សអានត្រង់វគ្គដែលទាក់ទងនឹងសំណួរទាំងនោះឡើងវិញដោយស្ងៀមស្ងាត់ ឬដោយឮៗ ដើម្បីយល់ន័យ ពាក្យនិងអាចឆ្លើយបាន ។
  - សួរសំណួរទាក់ទងបទពិសោធដែលសិស្សយល់បានពីខ្លឹមសារ និងន័យនៃអត្ថបទផ្សារភ្ជាប់នឹងការរស់នៅរបស់គេជាក់ស្ដែង ។

## ខ. ការបញ្ចប់មេរៀន

ហៅសិស្សរៀនយឺតអានបណ្ដាក់គ្នា ២-៣ល្បះម្នាក់ រួចគ្រូសរសើរលើកទឹកចិត្តសិស្ស ។

*បញ្ជាក់* : ចំពោះមេសូត្រ និងចម្រៀង គ្រូច្រៀង ឬសូត្រឱ្យឮៗ តាមបែបបទនៃបទនីមួយៗជាគំរូ ។ គ្រូអាចឱ្យសិស្សដែលចេះសូត្រ ឬច្រៀង ឱ្យច្រៀង ឬសូត្រជាគំរូ សិស្សដទៃទៀតស្ដាប់តាមដោយស្ងៀមស្ងាត់ ។ គ្រូសូត្រ ឬច្រៀងមួយឃ្លាម្ដងៗ មួយវគ្គម្ដងៗ រួចឱ្យសិស្សថាតាមជាក្រុម ជាបុគ្គល ។

## គ .ការវាយតម្លៃ

- ឱ្យសិស្សហ្វឹកហាត់អានពាក្យដោយមិនបាច់ផ្សំនិងប្រកប ឬធ្វើលំហាត់ផ្សេងទៀតក្នុងសៀវភៅតាមក្រុម ឬដៃគូ ។ គ្រូសម្របសម្រួលចម្លើយតាមក្រុមនីមួយៗ
- ហៅសិស្សរៀនយឺត ឬមធ្យមឱ្យអានអត្ថបទឡើងវិញ ។ សិស្សដទៃទៀតជួយកែលម្អ ។

## ៦.១១ លំនាំបង្រៀនសំណេរ

លំនាំបង្រៀនសំណេរ មានបំណងបណ្ដុះស្មារតីនិងការចងចាំក្នុងការសរសេរពាក្យ ចម្លងពាក្យ បំពេញល្បះនឹងពាក្យ តែងល្បះតាមរូបភាព សរសេរពាក្យតាមរូបភាព សំណេរបំពេញល្បះ សរសេរតាមអានរៀបចំ សរសេរតាមអានចម្លង សរសេរតាមអានត្រួតពិនិត្យ ដើម្បីឱ្យសិស្សមានបំណិនសំណេរយ៉ាងប៉ិនប្រសប់ ឈ្លាសវៃ មិនមានកំហុសអក្ខរាវិរុទ្ធ ។

## ៦.១២ លំនាំបង្រៀនអក្សរផ្ចង់

- គ្រូគូសបន្ទាត់ផ្ដេកនៅលើក្ដារខៀនតាមទម្រង់ ១/២ដូចគំរូខាងក្រោម ៖



- គ្រូណែនាំសិស្សអំពីរបៀបគូសបន្ទាត់តាមគំរូខាងលើ ។ នៅក្នុងសៀវភៅសិស្សមានក្រឡាបន្ទាត់ស្រេចហើយ គ្រូគ្រាន់តែនាំសិស្សគូសបន្ទាត់ទ្រេតតាមក្រឡាបន្ទាត់ក្នុងសៀវភៅសិស្សតែប៉ុណ្ណោះ ។
- គ្រូសរសេរគំរូនៅលើក្ដារខៀនយឺតៗតាមចលនានីមួយៗឱ្យសិស្សសង្កេតតាម ។ ដំបូងគ្រូសរសេរអក្សរ **"ឈ"** ដោយកំណត់យកកម្ពស់ ៤/៤ ទទឹង ២/៣ជួរទី ១ បន្ទាប់មកសរសេរតួអក្សរ **"ឈ"** ដោយកំណត់យកកម្ពស់ ២/៤ ទទឹង ១/៣ ជួរទី ២ ។
- គ្រូឱ្យសិស្សហាត់សរសេរអក្សរនៅលើក្ដារឆ្នួនតាមគំរូនៅលើក្ដារខៀន ។ គ្រូត្រួតពិនិត្យនិងកែលម្អ ។
- គ្រូឱ្យសិស្សហាត់សរសេរអក្សរផ្ចង់នៅក្នុងសៀវភៅរៀងៗខ្លួន ។ គ្រូប្រមូលមកកែដាក់ពិន្ទុ ។

## ៦.១៣ លំនាំបង្រៀនបំពេញពាក្យក្នុងល្បះ

- គ្រូឱ្យសិស្សម្នាក់ៗអានល្បះក្នុងសៀវភៅឬគ្រូចម្លងលំហាត់ដាក់លើក្ដារខៀន ឬបិទបណ្ណលំហាត់ រួចឱ្យសិស្ស ២- ៣នាក់អាន ឯសិស្សដទៃទៀតតាមដានស្ដាប់ដោយយកចិត្តទុកដាក់ ។ គ្រូគប្បីណែនាំសិស្សបន្ថែមពីរបៀបធ្វើលំហាត់បំពេញល្បះនឹងពាក្យ ។ បើលំហាត់នេះមានរូបភាពផងគ្រូត្រូវបង្ហាញ ឬបិទរូបភាពនៅលើក្ដារខៀនពីលើល្បះនីមួយៗឱ្យសិស្សយល់ ។
- គ្រូឱ្យសិស្សអានល្បះទី ១ រួចសួរ ៖ តើអ្នកយល់ល្បះនេះឬទេ ? តើអ្នកធ្វើដូចម្ដេចដើម្បីយល់ល្បះនេះ ? (ចម្លើយ ត្រូវបំពេញពាក្យក្នុងចន្លោះល្បះ) ។
- គ្រូឱ្យសិស្សម្នាក់អានពាក្យក្នុងប្រអប់មុននឹងបំពេញ ដើម្បីដឹងថាត្រូវជ្រើសរើសយកពាក្យណាមួយមកបំពេញឱ្យត្រូវន័យនៃល្បះនិងរូបភាពនីមួយៗនោះ ។
- គ្រូឱ្យសិស្សម្នាក់ឡើងសរសេរពាក្យនោះត្រង់ចន្លោះល្បះ រួចឱ្យសិស្សអានល្បះនោះឡើងវិញ ។
- គ្រូណែនាំសិស្សឱ្យបំពេញល្បះបន្តបន្ទាប់រហូតដល់ចប់តាមក្រុម ជាដៃគូ ឬជាបុគ្គល ដោយប្រើសៀវភៅរបស់គេ រួចដាក់ក្នុងសៀវភៅកិច្ចការ ។
- តំណាងក្រុមបង្ហាញចម្លើយដោយប្រាប់តែពាក្យតាមលំដាប់ល្បះនៅលើក្ដារខៀន ។
- សិស្សទាំងអស់ចូលរួមវាយតម្លៃនិងជួយកែលម្អ ។
- គ្រូឱ្យសិស្សអានល្បះដែលបំពេញបានត្រឹមត្រូវឡើងវិញ រួចចម្លងល្បះដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ៦.១៤ លំនាំបង្រៀនតែងល្បះតាមរូបភាព

- គ្រូឱ្យសិស្សអានការណែនាំធ្វើលំហាត់ក្នុងសៀវភៅ រួចគ្រូសួរ ៖ តើលំហាត់នេះតម្រូវឱ្យប្អូនធ្វើអ្វី ? (តែងល្បះតាមរូបភាព) ។ គ្រូពន្យល់សិស្សបន្ថែមអំពីរបៀបតែងល្បះតាមរូបភាព ដែលមានក្នុងលំហាត់នីមួយៗ ប្រសិនបើចាំបាច់ ។
- គ្រូឱ្យសិស្សសង្កេតរូបភាពនីមួយៗ រួចសួរ ៖ តើនេះជារូបអ្វី ?តើពាក្យនេះ ឬល្បះនេះមានន័យដូចម្ដេច ? បន្ទាប់មកឱ្យសិស្សធ្វើអក្ខរាវិរុទ្ធ ... សរសេរលើក្ដារឆ្នួន ហើយឱ្យសិស្សឡើងសរសេរពាក្យនេះចំពីក្រោមរូបភាព ។
- គ្រូឱ្យសិស្សហាត់បង្កើតល្បះផ្សេងៗដោយមាត់ទទេ ទាក់ទងនឹងរូបភាពទី ១ ។ គ្រូកែលម្អខ្លឹមសារពាក្យពេចន៍ក្នុងល្បះនោះឱ្យបានត្រឹមត្រូវ ។
- គ្រូឱ្យសិស្សតាមក្រុម ជាដៃគូ តែងល្បះតាមរូបភាពដាក់ក្នុងសៀវភៅ ឬលើក្រដាស ។ តំណាងក្រុមឡើងបង្ហាញចម្លើយ ។ គ្រូកែលម្អកិច្ចការសិស្សតាមក្រុម ។
- គ្រូឱ្យសិស្សអានល្បះត្រឹមត្រូវឡើងវិញ រួចចម្លងដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ៦.១៥ លំនាំបង្រៀនសរសេរតាមអាន

### ក. សរសេរតាមអានចម្លង(ពាក្យ កន្សោមពាក្យ ល្បះ និងអត្ថបទ)

- គ្រូឱ្យសិស្សម្នាក់ៗអានពាក្យក្នុងសៀវភៅ ឬគ្រូបិទបណ្ណពាក្យដែលត្រូវបង្រៀនដាក់លើក្ដារខៀន ។
- គ្រូអាននិងចង្អុលពាក្យម្ដងមួយឱ្យច្បាស់ៗ រួចសិស្សម្នាក់ៗចង្អុលនិងអានពាក្យនោះនៅក្នុងសៀវភៅសិស្ស ។
- គ្រូចង្អុលពាក្យទី ១ ហើយអានម្ដងទៀត ។ គ្រូឱ្យសិស្សថាតាម រួចធ្វើអក្ខរាវិរុទ្ធពាក្យនោះ ។
- គ្រូឱ្យសិស្សសរសេរពាក្យនោះនៅលើក្ដារឆ្នួនទាំងអស់គ្នា ។ គ្រូពិនិត្យនិងកែតម្រូវសិស្សដែលសរសេរខុស ឱ្យកែឱ្យត្រូវឡើងវិញ ។
- គ្រូចង្អុលពាក្យទី ២ ទី ៣ រហូតគ្រប់ពាក្យ ដោយធ្វើតាមលំនាំបង្រៀនពាក្យទី ១ដែរ ។
- គ្រូហៅពាក្យឆ្លាស់គ្នាឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរបស់គេ ។ គ្រូអានពាក្យទាំងនោះឡើងវិញ ឱ្យសិស្សផ្ទៀង ។ គ្រូទុកពេលសមល្មមឱ្យសិស្សពិនិត្យនិងកែកំហុស ។
- គ្រូប្រមូលសៀវភៅសិស្សកែដាក់ពិន្ទុ ឬឱ្យសិស្សប្ដូរគ្នាកែដោយផ្ទៀងជាមួយពាក្យក្នុងសៀវភៅ ។
- គ្រូណែនាំសិស្សឱ្យប្រគល់សៀវភៅទៅម្ចាស់ដើមវិញ ហើយឱ្យម្ចាស់សៀវភៅឆូតពាក្យខុសនឹងខ្មៅដៃ ហើយសរសេរពាក្យត្រូវនៅខាងលើពាក្យនោះវិញ ។
- គ្រូឱ្យសិស្សដែលសរសេរខុសលើសពីប្រាំពាក្យ ចម្លងពាក្យនោះឱ្យត្រូវទាំងអស់ឡើងវិញ ។

## ខ. សរសេរតាមអានរៀបចំ

- គ្រូបិទបណ្ណអត្ថបទដាក់លើក្ដារខៀន ។
- គ្រូអានពាក្យពិបាក ឬពាក្យគន្លឹះ រួចឱ្យសិស្សអានតាម ។
- គ្រូអានអត្ថបទដោយយឺតៗច្បាស់ៗ រួចឱ្យសិស្សអានឡើងវិញ ។
- គ្រូឱ្យសិស្សពន្យល់ពាក្យពិបាកៗ រួចឱ្យសិស្សធ្វើអក្ខរាវិរុទ្ធ ។
- គ្រូហៅពាក្យពិបាកៗឱ្យសិស្សសរសេរនៅលើក្ដារឆ្នួន ។
- គ្រូលាក់អត្ថបទ រួចហៅឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅមួយឃ្លាម្ដងៗ រហូតដល់ចប់ ។ បន្ទាប់មកហៅសំណួរឱ្យសិស្សសរសេរ ។
- គ្រូអានអត្ថបទឡើងវិញឱ្យសិស្សស្ដាប់និងផ្ទៀងផ្ទាត់ រួចទុកពេលឱ្យសិស្សពិនិត្យនិងកែ កំហុសរៀងៗខ្លួន ។
- គ្រូឱ្យសិស្សពន្យល់ពាក្យ រួចឆ្លើយនឹងសំណួរ ។
- គ្រូឱ្យសិស្សដូរសៀវភៅគ្នាកែតាមអត្ថបទបង្ហាញនៅលើក្ដារខៀន ។
- គ្រូប្រមូលសៀវភៅកិច្ចការសិស្សកែដាក់ពិន្ទុ ។

## គ. សរសេរតាមអានត្រួតពិនិត្យ

- គ្រូអានពាក្យ កន្សោមពាក្យ កថាខណ្ឌ ឬអត្ថបទឱ្យសិស្សស្ដាប់ ។
- គ្រូហៅពាក្យ កន្សោមពាក្យ ឃ្លាខ្លីៗចំនួនបីដងឱ្យសិស្សសរសេរតាមម្ដងមួយៗ រហូតដល់ចប់ ។
- គ្រូអាចឱ្យសិស្ស ២ នាក់ថាតាមក្រោយពីគ្រូអាន ដោយសិស្សម្នាក់ថា មុននឹងខ្លួនសរសេរ ហើយម្នាក់ទៀតថាបន្ទាប់ពីខ្លួនសរសេររួច ។
- គ្រូអានឱ្យសិស្សស្ដាប់ឡើងវិញដោយយឺតៗនិងច្បាស់ៗ ដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់ និងទុកពេលឱ្យសិស្សកែកំហុស
- គ្រូប្រមូលកិច្ចការសិស្សកែដាក់ពិន្ទុ ។

# ៦.១៦ លំនាំបង្រៀននិយាយ

## ក. ការចាប់ផ្ដើមមេរៀន

- ការប្រើសំណួរបំផុស :

គ្រូសួរសំណួរបំផុសដើម្បីស្ទាបស្ទង់ចំណេះដឹងសិស្សដែលមានស្រាប់ ដោយឱ្យសិស្សនិយាយ ឬបង្ហាញពីអ្វីដែលពួកគេធ្លាប់ដឹងរួចមកហើយទាក់ទងនឹងមេរៀនថ្មី ។

- ការបង្ហាញ ៖
  - គ្រូឱ្យសិស្សពិនិត្យរូបភាពក្នុងសៀវភៅសិស្ស រួចនិយាយអំពីរូបភាពនោះទៅតាមសំណួររបស់គ្រូ ៖ តើប្អូនឃើញអ្វីខ្លះនៅលើរូបភាពនេះ ? តើនេះជារូបភាពអ្វី ? តើរូបភាពនេះបង្ហាញពីអ្វី ?
  - គ្រូឱ្យសិស្សប្រាប់ពីស្ថានភាពនិងតួអង្គនៅក្នុងអត្ថបទសន្ទនា *ឧទាហរណ៍ :* អ្នកណាខ្លះកំពុងធ្វើអ្វីនៅឯណា ?
  - គ្រូឱ្យសិស្សអានអត្ថបទពណ៌នា ឬអត្ថបទសន្ទនានៅក្នុងសៀវភៅសិស្សជាដៃគូឬបុគ្គល ។
  - គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្ស ដើម្បីបញ្ជាក់ការយល់ដឹងរបស់សិស្ស ។
  - គ្រូសួរសំណួរទាក់ទងនឹងរបៀបនិយាយ ឬពាក្យ ឃ្លាចាំបាច់

(គ្រូគប្បីសរសេរពាក្យ ឬឃ្លាចាំបាច់មួយចំនួនសម្រាប់ប្រើក្នុងអត្ថបទដាក់លើក្ដារខៀន ដើម្បីឱ្យសិស្សចងចាំនិងងាយឆ្លើយនឹងសំណួរ ។)

## ខ. ការបញ្ចប់មេរៀន

- គ្រូឱ្យសិស្សបញ្ជាក់ឡើងវិញអំពីពាក្យ ឬឃ្លាដែលត្រូវប្រើ ឬនិយាយក្នុងអត្ថបទនោះ ។
- គ្រូឱ្យសិស្សហាត់និយាយតាមក្រុមតូចៗ ដោយប្រើឈ្មោះខ្លួនឯងនិងមិត្តភក្តិ ។ គ្រូសម្របសម្រួលនិងសរសើរលើកទឹកចិត្តសិស្ស ។

## គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សអានលំហាត់សន្ទនាក្នុងសៀវភៅសិស្សជាក្រុម ជាដៃគូ ជាបុគ្គល រួចត្រៀមគំនិតឡើងនិយាយ ។
- គ្រូឱ្យសិស្សឡើងនិយាយ ឬសន្ទនានៅមុខសិស្សឯទៀត ។ គ្រូសរសើរលើកទឹកចិត្តសិស្ស ។

# ៦.១៧ លំនាំបង្រៀនស្ដាប់

លំនាំបង្រៀនស្ដាប់មានបំណងបណ្ដុះស្មារតីសិស្សឱ្យយកចិត្តទុកដាក់ស្ដាប់ពាក្យពេចន៍ ឃ្លា ល្បះនិងខ្លឹមសារអត្ថបទ ហើយអាចឆ្លើយសំណួរ និទានរឿងឡើងវិញ ឬសំដែងតួតាមផ្នែកណាមួយនៃរឿងបានត្រឹមត្រូវ ពោលគឺសិស្សមានបំណិនក្នុងការស្ដាប់យល់ ។

## ក. ការចាប់ផ្ដើមមេរៀន

- ការប្រើសំណួរបំផុស ៖
  - គ្រូឱ្យសិស្សឆ្លើយសំណួរបំផុសទាក់ទងពីអ្វីដែលពួកគេធ្លាប់ដឹង ។
  - គ្រូឱ្យសិស្សមើលរូបភាព រួចគ្រូសួរសំណួរលើរូបភាព ។

- គ្រូឱ្យសិស្សអានចំណងជើងរឿង ពិនិត្យរូបភាព រួចឱ្យសិស្សទាយ ឬប៉ាន់ស្មានខ្លឹមសាររឿង ដោយគ្រូសួរថា តើអ្នកគិតថា រឿងនេះនិយាយពីអ្វី ?

• ការស្តាប់ :

- គ្រូឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សជាមុនសិន ។
- គ្រូនិទានរឿងឱ្យសិស្សស្តាប់ដោយយឺតៗនិងប្រើសំឡេងច្បាស់ៗ ។

## ខ. ការបញ្ចប់មេរៀន

- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្ស ។ បើសិស្សឆ្លើយសំណួរណាមួយមិនបាន គ្រូត្រូវនិទានរឿងត្រង់ផ្នែកនោះឡើងវិញ ដើម្បីឱ្យសិស្សស្តាប់ឡើងវិញនិងអាចឆ្លើយបាន ។
- គ្រូសួរសំណួរថ្មីបន្ថែម ដើម្បីផ្សារភ្ជាប់បទពិសោធដែលសិស្សរៀនរួចទៅនឹងបទពិសោធជាក់ស្តែងដែលសិស្សជួបប្រទះក្នុងការរស់នៅ ។

## គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សនិទានរឿងតាមក្រុមតូចៗ ឬសំដែងតួតាមផ្នែកណាមួយនៃរឿង ឬគូររូបភាព ។
- គ្រូឱ្យសិស្សធ្វើលំហាត់ក្នុងសៀវភៅសិស្សតាមក្រុម ដៃគូ ឬបុគ្គល ។
- តំណាងក្រុមឡើងរាយការណ៍ចម្លើយ ។

### អត្ថបទស្តាប់ : រឿង ក្អែកការកូន

មានសេចក្តីតំណាលថា មានស្តេចក្អែកមួយនៅអាស្រ័យលើចុងត្នោតយ៉ាងខ្ពស់ ។ ថ្ងៃមួយក្អែកនេះបានរៀបចំការកូនឱ្យមានគូស្រករ ។ ស្តេចក្អែកបានចាត់ឱ្យពួកពលទៅអញ្ជើញភ្ញៀវមកស៊ីការ ។ លុះដល់ថ្ងៃកំណត់រៀបចំផ្សំផ្គុំកូនប្រុសស្រីទាំងពីរហើយ ពួកសត្វទាំងអស់ដែលក្អែកបានអញ្ជើញក៏បានមកជួបជុំ ផឹកស៊ីយ៉ាងគគ្រឹកគគ្រេង ។ និយាយពីស្តេចអណ្តើកដែលស្តេចក្អែកអញ្ជើញមក ខំវារទៅនឹងគេដែរ តែដោយហេតុជើងវាខ្លីពេក ក៏មកដល់ក្រោយគេ ។ លុះទៅដល់ដើមត្នោត សត្វអណ្តើកដកកមើលទៅខាងលើ ក៏ឃើញសត្វជាច្រើនកំពុងស៊ីផឹក ។ អណ្តើកនឹកឃ្លានណាស់ តែមិនដឹងធ្វើដូចម្តេចនឹងឡើងទៅលើចុងត្នោតបាន ។ ពេលនោះស្រាប់តែមានពស់មួយលូនមកដល់ ។ អណ្តើកក៏សួរទៅពស់ ៖ “បងពស់ទៅណាដែរ ?” ពស់ឆ្លើយ ៖ “ខ្ញុំបម្រុងនឹងទៅស៊ីការកូនបងក្អែក ។ ចុះបងអណ្តើកឯងមកទីនេះធ្វើអ្វីដែរ ?” ។ អណ្តើកឆ្លើយ ៖ “ខ្ញុំបម្រុងទៅស៊ីការកូនបងក្អែកដែរ” ។ ពស់ប្រាប់អណ្តើក ៖ “បើដូច្នោះសូមបងអណ្តើកខាំកន្ទុយខ្ញុំមក ខ្ញុំនឹងលូនយោងឡើងទៅលើ តែសូមប្រយ័ត្នមាត់បន្តិច” ។ អណ្តើកត្រេកអរក៏ខាំកន្ទុយពស់ភ្លាម ពស់ក៏ឡើងទៅលើចុងត្នោត ។ លុះទៅដល់លើចុងត្នោត ស្តេចក្អែកក្រឡេកឃើញអណ្តើក ក៏ស្រែកសួរជាការគួរសម ៖ “យី ! បងអណ្តើកអញ្ជើញមកដែរ ?” ។ អណ្តើកភ្លេចខ្លួនឆ្លើយទទួលពាក្យគួរសមនេះវិញ ៖ “បាទ !” ។ មួយរំពេចនោះ អណ្តើកក៏របូតមាត់ពីកន្ទុយពស់ ធ្លាក់ខ្ពោកមកលើដី បណ្តាលឱ្យស្រាំស្នូកនៅជាប់ស្នាម រហូតមកដល់សព្វថ្ងៃនេះឯង ។

## អត្ថបទស្តាប់ ៖ រឿង កញ្ជ្រោងនិងកូនពពែ

មានមេពពែមួយរស់នៅជាមួយនឹងកូនក្នុងផ្ទះមួយក្បែរមាត់ព្រៃ។ រាល់ថ្ងៃមុននឹងចេញទៅរកចំណី មេពពែតែងតែផ្ដែផ្ដាំកូន៖ "នៅពេលដែលម៉ែមិននៅផ្ទះ កូនកុំដើរលេងផ្ដេសផ្ដាសឱ្យសោះ។ ម្យ៉ាងទៀត បើមាននរណាគោះទ្វារហៅកូនឱ្យបើកទ្វារ ចូរកូនកុំបើក ព្រោះនៅក្នុងព្រៃនេះមានសត្វសាហាវច្រើនណាស់។ នៅពេលម៉ែត្រឡប់មកវិញ ម៉ែនឹងគោះទ្វារហៅកូន រួចលូកជើងមុខចូលចន្លោះក្រោមទ្វារបង្ហាញកូនជាសញ្ញា"។ មេពពែផ្ដែផ្ដាំកូនរួចហើយក៏ចេញទៅរកចំណីបាត់ទៅ ឯកូនពពែក៏បិទទ្វារជិតធ្វើតាមបណ្ដាំមេ។ ពេលនោះ ជាឱកាសល្អសម្រាប់កញ្ជ្រោងមួយ ដែលបានចូលលួចស្ដាប់ការផ្ដែផ្ដាំរបស់មេពពែ។ មួយសន្ទុះធំក្រោយមក កញ្ជ្រោងក៏ចូលទៅគោះទ្វារតុកៗ តុកៗ តុកៗ។ កូនពពែក៏សួរ៖ "នរណាហ្នឹង ? ម៉ែឬ ? "។ កញ្ជ្រោងក៏ឆ្លើយធ្វើសំឡេងដូចមេពពែ៖ "គឺម៉ែណាកូន។ កូនបើកទ្វារឱ្យម៉ែផង ម៉ែមកវិញហើយ"។ កូនពពែ៖ "សូមម៉ែលូកជើងបង្ហាញកូនមក"។ កញ្ជ្រោងក៏លូកជើងតាមចន្លោះក្រោមទ្វារបង្ហាញកូនពពែ។ កូនពពែស្រែកឡើង៖ "ទេៗ ទេៗ មិនមែនម៉ែខ្ញុំទេ ជើងធំខ្មៅព្រឹកដូចនេះ ពិតជាជើងកញ្ជ្រោង"។

## អត្ថបទស្តាប់ ៖ រឿង ដឹងសងដឹង អំបែងសងអំបែង

មាននិទានមួយថា មានបុរសប្ដីប្រពន្ធ មានកូនប្រុសម្នាក់។ បុរសជាប្ដីនោះទៅខ្ចីដឹងពីសេដ្ឋីម្នាក់យកទៅកាប់អុស។ នៅពេលបុរសនោះលើកដឹងឡើងកាប់ ស្រាប់តែដឹងរង្គោះខ្ទាតទៅត្រូវប្រើសមួយ ហើយប្រើសនោះក៏បោលចូលក្នុងព្រៃបាត់ទៅ។ បុរសនោះបានទៅអង្វរសេដ្ឋីសុំសងដឹងថ្មីមួយជាពីររហូតដល់ដប់ ក៏សេដ្ឋីនៅតែមិនព្រមយក។ បុរសនិងប្រពន្ធបានព្រមព្រៀងគ្នាយកកូនកំលោះឱ្យទៅបម្រើសេដ្ឋីជាសំណងដឹងនោះ ទើបសេដ្ឋីព្រមទទួល។

ថ្ងៃក្រោយមក បុរសបានរកឃើញដឹងនៅជាប់នឹងខ្លួនសត្វប្រើសមួយងាប់រលួយ។ គាត់មានសេចក្ដីត្រេកអរខ្លាំងណាស់ក៏យកផ្លែដឹងមកលាងទឹកឱ្យស្អាត រួចយកទៅឱ្យសេដ្ឋី ហើយសុំយកកូនប្រុសមកវិញ។

ថ្ងៃមួយបុរសប្ដីប្រពន្ធនាំគ្នាដាល់អំបុកហូប។ កូនសេដ្ឋីធុំក្លិនអំបុក និកចង់ហូប។ សេដ្ឋីក៏ទៅខ្ចីអំបែងបុរសនោះ។ លុះដាល់អំបុករួច ស្រាប់តែមានឆ្កែប្រខាំគ្នាពារលើអំបែងនោះបែកខ្ទេចអស់។ សេដ្ឋីទៅប្រាប់បុរសនោះ បុរសនោះយំគក់ទ្រូង ទោះសេដ្ឋីសុំសងអំបែងថ្មីមួយជាដប់ ក៏ពុំព្រមយកដែរ។ រឿងនេះមានការប្ដឹងផ្ដល់គ្នាដល់ព្រះមហាក្សត្រ។ ព្រះអង្គក៏កាត់ក្ដីឱ្យសេដ្ឋីយកកូនស្រីខ្លួនទៅនៅបម្រើគ្រួសារបុរសនោះវិញ។

# មេរៀនទី ១ ស្រៈនិស្ស័យនិងព្យញ្ជនៈ

## ស្រៈនិស្ស័យ

ា ិ ី ឹ ឺ ុ ូ ួ

ើ ឿ ៀ េ ែ ៃ ោ ៅ

ុំ ំ ាំ ះ ុះ េះ ោះ។

## ព្យញ្ជនៈនិងជើងព្យញ្ជនៈ



| ព្យញ្ជនៈ ពួក អ | ព្យញ្ជនៈ ពួក អ៊ |
|---|---|
| ក្ក ខ្ខ | គ្គ ឃ្ឃ ង្ង |
| ច្ច ឆ្ឆ | ជ្ជ ឈ្ឈ ញ្ញ |
| ដ្ដ ឋ្ឋ ណ្ណ | ឌ្ឌ ឍ្ឍ |
| ត្ត ថ្ថ | ទ្ទ ធ្ធ ន្ន |
| ប្ប ផ្ផ | ព្ព ភ្ភ ម្ម |
| ស្ស ហ្ហ ឡ្ឡ អ្អ | យ្យ រ្រ ល្ល វ្វ |



# មេរៀនទី ២ រំឭកព្យញ្ជនៈផ្សំស្រៈ

ក ខ ច ឆ ដ ឋ ណ ត ថ ប ផ ស ហ ឡ អ

កោះ ខោ ចុះ ឆៅ ដេរ តោ តឿ ថា

ប៊ី បោ ផុះ សេះ ហើរ ហោះ ឡូ អុំ

កកូរ ខះក ចរចា ដំណាំ ចំណី តាខេ បបរ ដំបៅ

កាផា សរសេរ សរសើរ ហួរហែ កីឡា អាហារ

កុំឆីចំណីឆៅ ។

បងចំណានខំដេរខោ ។

ចែអាំសរសើរបុប្ផាថា ចេះថែដំណាំ ។



ដាំ



បងចំណានខំដេរខោ ។

# មេរៀនទី ៣ រំឭកព្យញ្ជនៈផ្សំស្រៈ

គ ឃ ង ជ ឈ ញ ឌ ឍ ទ ធ ន ព ភ ម យ រ ល វ

គោ គោះ ឌី ឃុំ ងំ ជូរ ជោរ ឈឺ ឈើ ញី ទា ទំ

ធូរ ធំ នៅ ពោះ ភរ ភេ មេ យួរ យំ រៃ រាំ លី លើ វះ

គគីរ សាគរ ឃោរឃៅ គឃៀរ ជំងឺ ឈូឆរ ញញួរ គោញី ឈាមរា

ដំបៅងា ទទា ធានា ពុះពារ យោធា វេលា នាវា រទេះ រលំ ទីលំនៅ

គោញីតាឃុំឈឺ ។

ពូទីចុះពីលើនាវា ។

សេះចៅងីជាសះដំបៅងា ។

តាឌីដើរសំដៅសាលាឃុំគគីរ ។



តាឌីដើរសំដៅសាលាឃុំគគីរ ។



ពូទីចុះពីលើនាវា ។

# មេរៀនទី ៤ រំពូក ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉

ង៉ា ញ៉ុំ ប៊ី ប៉ះ ម៉ែ ម៉ុំ ម៉ៅ យ៉ា យ៉ុំ វ៉ា វ៉ែ រ៉ វ៉ៃ វ៉ែន

អាយ៉ៃ ឆៃយ៉ុំ រយ៉ា ចំប៊ី ម្ជម៉ៅ រ៉ុំរ៉ៃ រ៉ែរ៉

ញ៉េះញ៉ោះ រយ៉ៃ ហៅប៉ៅ រណារវ៉ វ៉ែនតា

តាម៉ឺលីចាប៊ី ។

បូណាឈឺរ៉ុំរ៉ៃ ។

ពូម៉ៅពូកែញ៉េះញ៉ោះ ។



បូណា ឈឺរ៉ុំរ៉ៃ ។

## លំហាត់

ចូរសរសេរអក្សរផ្ដុំអំពីព្យញ្ជនៈ “ប” ។

មេរៀនទី
៥

# រំឭក ប៊ ស៊ ហ៊ អ៊

ប៊ ស៊ុាំ ហ៊ូ ហ៊ោ អ៊ូ

សាប៊ូ ប៊ីដុង កៅស៊ូ ទ្រអ៊ូ ប៉ាហ៊ី

តៅហ៊ូ រអ៊ូ ហ៊ីហា អ៊ូអរ ភាស៊ី

ថៅស៊ូទះដៃហ៊ោ ។

អាវ៉ាញុាំតៅហ៊ូ ។

តាហ៊ីលីកៅស៊ូ ។

ពូប៊ីថា ទីនេះអ៊ូអរ ។

អ៊ំៗមមាញឹកចៀរជ័រកៅស៊ូ ។



ទ្រអ៊ូ



អ៊ំៗមមាញឹកចៀរជ័រកៅស៊ូ ។

# មេរៀនទី ៦ រំឭកពាក្យប្រកបនឹង

ក ខ គ ឃ ច ជ ត ថ ទ ព ប ស

កាច់ ទឹក ដេក មុខ រូប មេឃ នាច សាច់ ខូច ពូជ ជូត ប៉ោត ឆើត រត់ គូថ បាទ បិទ សេព ទាប ហើប គប់ ចាប់ រៀប លើស

អំណាច ទឹកកក ជដែក រោគា មេឃា នាគរាជ ងងឹត គំនិត សំប៉ែត កាំបិត របើក ជំនួស កំពឹស សុភាព ឡិកឡក់

ចៅជុំផឹកទឹកកក ។

តាភាពជូតប៉ី ។

បងអ៊ុតដុតពោតហូប ។

មីងប៉ានរើសយកទៀបធំៗទៅទុកហូប ។



បងអ៊ុតដុតពោតហូប ។



តាភាពជូតប៉ី ។

មេរៀនទី ៧

# រំឭកពាក្យប្រកបនឹង

## ន ណ ង ញ ម យ ល វ

បាន ហ៊ាន កាន់ គុណ កង់ កោង រឹង ប៉ើង ដូង ចេញ វេញ
ចាញ់ សូម រោម ហើយ វាយ ចាយ មើល ពេល កែវ

រលួយ ជំនួយ អំបិល រដូវ រំដួល សាវម៉ាវ រសៀល ងងឹត
ចំនួន ចំណេញ ននោង រុងរឿង ចំណង ផាងដូង ឡិកឡក់

មីងពេញទិញននោង ។

ពូពយទិញភួយមួយ ។

កុមារជិះទោងនៅសាលារៀន ។

ពេលទំនេរ បងកែវទៅរៀនហែលទឹក ។



កុមារជិះទោងនៅសាលារៀន ។

# មេរៀនទី ៨ រំឭកស្រះពេញតួ

អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ

អគារ អាហារ ឥសី ឧកញ៉ា ឪទិន

ឪពុក ឫស្សី រឭក ឱសថ ឮដ៏

ឪពុកឯងរស់នៅឯណា ?

ពូឱមដកក្រឳឈូកនៅឯបឹង ។

ឥឡូវនេះ ជំនោរបក់ពីទិសឦសាន ។



ពូឱមដកក្រឳឈូកនៅឯបឹង ។

## លំហាត់

ចូរសរសេរអក្សរផ្គង់អំពីស្រះពេញតួ "ឥ" ។

មេរៀនទី ៩

# ព្យញ្ជនៈផ្ញើជើង

## ខ្ញ ខ្ម ខ្ព ស្ត ស្គ ស្ព

ខ្ញាយ ខ្ញាក់ ខ្ញិល ខ្មះ ខ្មម ខ្មឹង ខ្មឹម ខ្ពស់ ខ្ពើម ស្តោ ស្គង ស្ពិន ស្ពោះ

ខ្មីខ្មា ខ្ញាប់ខ្ជួន ខ្មេចខ្មី ស្គាំស្គង ខ្ពង់ខ្ពស់ ខ្ពង់រាប

សុភានិយាយមិនដែលស្គាំស្គង ។

ពូនួនដាំខ្ញឹមលើទួលខ្ពស់ ។

សុភីខំរៀនយ៉ាងខ្ជាប់ខ្ជួន ។

ត្រីស្ពិនហែលឆ្ពោះទៅ ពេលឃើញត្រីស្តោ ។



ខ្ទម



ត្រីស្ពិន

## លំហាត់

ចូរសរសេរអក្សរផ្តង់អំពីព្យញ្ជនៈ "ខ" ។

*រយៈពេល ០៣ ម៉ោងសិក្សា*

មេរៀនទី
១០

# ព្យញ្ជនៈផ្ញើជើង

## ត្ន ត្ល ត្អ ថ្ក ថ្គ ថ្ន ថ្ព ថ្ម ថ្ល

ត្នោត ត្លុក ត្លុម ត្អូញ ត្អើក ថ្កូវ ថ្គាម ថ្នាំ ថ្នាល ថ្ពក់ ថ្ពាល់ ថ្មី ថ្លា ថ្លៃ

ដើមត្នោត ចាក់ត្លុក ត្អូញត្អែរ ថ្គាមខ្លា ថ្នាក់ថ្នម ថ្ពាល់ខ្ជួច ថ្លៃថ្លា

មីងសនថ្ពក់ផ្លែថ្កូវ ។

មុខសុខាមានរាងថ្គាមខ្លា ។

ក្មេងៗលោតចាក់ត្លុកក្បែរដើមត្នោត ។

ពូសឿនផឹកទឹកត្នោតជូររួចត្អូញថាឈឺពោះ ។



មុខសុខាមានរាងថ្គាមខ្លា ។



មីងសនថ្ពក់ផ្លែថ្កូវ ។

មេរៀនទី
១១

# ព្យញ្ជនៈផ្ញើជើង

## ធ្យ ធ្ល ធ្វ ផ្ក ផ្គ ផ្ច ផ្ទ

ធ្យូង ធ្លា ធ្លាក់ ធ្លុះ ធ្វើ ធ្វេស ផ្កា ផ្កាយ ផ្គរ ផ្គាក់ ផ្ចុំ ផ្ចិត ផ្ទី ផ្ទុះ

ទីធ្លា ធ្លុះធ្លាយ ធ្យូងថ្ម ផ្គួផ្គង ផ្គត់ផ្គង់ ផ្ចិតផ្ចង់ ផ្ទៀងផ្ទាត់ ផ្ទីថ្ម

បាវធ្យូងធ្លុះធ្លាយ ។
ឪពុកខ្ញុំខំរកប្រាក់ផ្គត់ផ្គង់គ្រួសារ ។
ផ្គរលាន់គ្រឹមៗផ្ទួនគ្នាស្ទួរដូចគ្រាប់ផ្ទុះ ។
ក្មេងខ្លះធ្វើកិច្ចការនៅក្រោមដើមឈើក្នុងទីធ្លា ។


ផ្គាក់


ក្មេងខ្លះធ្វើកិច្ចការនៅក្រោមដើមឈើក្នុងទីធ្លា ។

# មេរៀនទី ១២ ព្យញ្ជនៈផ្ញើជើង

## ផ្ង ផ្វ ផ្ដ ផ្ត ផ្ទ ផ្ស ផ្អ

ផ្ការ ផ្លូត ផ្ញើ ផ្ញៀវ ផ្ដើម ផ្ដាំ ផ្ដិល ផ្ទុក ផ្ទូរ

ផ្លិត ផ្លែ ផ្សាយ ផ្សារ ផ្សិត ផ្អាប់ ផ្អូម ផ្អែម

ផ្ដាំផ្ញើ ផ្ដែផ្ដាំ ផ្ទុកខ្សាច់ ផ្លេកផ្លោះ ផ្សះផ្សា ផ្អៀងផ្អង

តាផ្លួយបេះផ្លែផ្ញៀវផ្ញើមកផ្ទះ ។

ចៅប៉ុនដើរផ្អៀងផ្អងក្បែរផ្ទុកខ្សាច់ ។

កុំផ្អាប់អាហារ នាំឱ្យជូរផ្អូម ។



ផ្សិត



ផ្ញៀវ

## លំហាត់

ចូរសរសេរអក្សរផ្ចង់អំពីព្យញ្ជនៈ "ផ" ។

មេរៀនទី ១៣

# ព្យញ្ជនៈផ្ញើជើង

## ្ព ្យ ្រ ្ឈ ្ញ ្ត ្ល

ព្ទង ញ្ចៅ ព្យួរ ព្យុះ ព្រឹក ព្រៃ ព្រួន ភ្នួរ ភ្នំ

ភ្ញាក់ ភ្ញៀវ ភ្ញែក ភ្នំ ភ្លាត់ ភ្លើង ភ្លៅ

ព្រៃព្រេច ព្យាយាម ភ្នំភ្លើង ភ្នំភ្នួរ ផ្កាភ្ញី ភ្លេចភ្លាំង

មីងពៅភ្លេចពន្លត់ភ្នក់ភ្លើង ។

ការផឹកទឹកឆៅនាំឱ្យកើតព្រូន ។

ពូភុំទៅបេះញ្ចៅក្នុងព្រៃទាំងព្រឹក ។

អុំឱុកភ្ញាក់ពីព្រលឹមទៅភ្ជួរដីក្បែរជើងភ្នំ ។



ភ្នំភ្លើង



ព្យុះ

# មេរៀនទី ១៤ មេរៀនសាឡើងវិញ ព្យញ្ជនៈផ្ញើជើង

## ថ្គ ថ្ត ធ្យ ធ្ល ធ្វ ផ្គ ផ្ទុ

ថ្គាម ថ្តក់ ថ្ពាល់ ធ្យូង ធ្លា ធ្លាក់ ធ្វើ ធ្មេស ផ្គាក់ ផ្គាប់ ផ្ទឹម ផ្ទុយ

ថ្គាមខ្លា ថ្ពាល់ខ្ទួច ធ្យូងថ្ម ធ្លុះធ្លាយ ផ្គត់ផ្គង់ ផ្ទៀងផ្ទាត់ ឆ្គាំឆ្គង

ចាក់ត្លុក ត្អូញត្អែរ ទីធ្លា ផ្គូផ្គង ផ្ចិតផ្ចង់ ផ្ទឹថ្ម

បាវធ្យូងធ្លុះធ្លាយ ។

ផ្ការលាន់គ្រឹមៗផ្ទួនគ្នាដូចគ្រាប់ផ្ទុះ ។

សុភានិយាយមិនដែលឆ្គាំឆ្គង ។

មុខសុខាមានរាងថ្គាមខ្លា ហើយថ្ពាល់ខ្ទួច ។

## លំហាត់

១. ចូរសរសេរពាក្យខាងក្រោមនេះឱ្យបានត្រឹមត្រូវ ។

ក. ឆ្គាំឆង : ............... ខ. ត្អូញតែ : ...............

២. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| ផ្ទួន | ថ្គាម | ថ្ពាល់ |
|---|---|---|

ក. ផ្ការលាន់គ្រឹមៗ..........គ្នាដូចគ្រាប់ផ្ទុះ ។

ខ. មុខសុខាមានរាង.......ខ្លា ហើយ......ខ្ទួច ។

មេរៀនទី ១៥

# ព្យញ្ជនៈផ្ញើជើង

## ម្ក ម្ខ ម្ង ម្ជ ម្ដ ម្ន ម្ន

ម្កាក់ ម្ខាង ម្ងាស់ ម្ជុល ម្ជូរ ម្ដាយ ម្ដេច ម្តុំ ម្ទេស ម្នាក់ ម្នាស់

ម្ដេចម្ដា ម្នីម្នា ម្នាងសិលា ម្ចាស់ផែនដី

ណារីចូលចិត្តហូបម្ជូរ ។
តាស៊ូខំប្រឹងដាំម្ទេសនិងម្នាស់ ។
ម្ដាយស៊ីថាម្នីម្នាទៅបេះផ្លែម្កាក់ ។



ម្នាស់



ម្ទេស

លំហាត់

ចូរសរសេរអក្សរផ្ចង់អំពីព្យញ្ជនៈ “ម” ។

មេរៀនទី
១៦

# ព្យញ្ជនៈផ្ញើជើង

## ម្យ ម្រ ម្ល ម្យ ម្ហ ម្អ

ម្យ៉ាង ម្រាម ម្រេច ម្រះ ម្លប់ ម្លេះ ម្លូ ម្សាញ់ ម្សិល ម្សៅ ម្ហូប ម្អម

ម្រាមដៃ ម្រះព្រៅ ម្លូព្រៃ ម្សិលមិញ ឆ្នាំម្សាញ់ ម្ហេបម្ហូប ម្អមក្តាម

ក្អួយខ្ញុំកើតឆ្នាំម្សាញ់ ។
តាឪមដាំម្រះ ម្លូ និងម្រះព្រៅ ។
ត្រីឆ្អិនផ្ញើមាត់ម្ហូបៗក្បែរគល់ម្អម ។
ម្សិលមិញម្តាយខ្ញុំទិញត្បាល់កិនម្សៅ ។



ត្បាល់កិនម្សៅ



ម្រេច

មេរៀនទី
១៧

# ព្យញ្ជនៈផ្ញើជើង

## ល្ខ ល្ង ល្ប ល្ព ល្ម ល្វ ល្ហ ល្អ

ល្ខោន ល្ង ល្ងាច ល្ងង់ ល្បី ល្បែង ល្ពៅ

ល្មុត ល្មម ល្វា ល្វីង ល្ហុង ល្ហើយ ល្អី ល្អិត

ល្វាចេក ល្វីងល្វើយ ល្ហល្ហាច ល្អិតល្អន់ ល្ខោនបាសាក់

ទឹកឡើងល្ហល្ហាចលិចដើមល្ហុង ។

ល្ខោនបាសាក់មានឈ្មោះល្បីល្បាញ ។

ពេលល្ងាច មីងផានបេះល្ពៅ ល្មុត និងល្ហុងដាក់ក្នុងល្អី ។



ល្ខោនបាសាក់



ល្ពៅ

## លំហាត់

ចូរសរសេរអក្សរផ្ចង់អំពីព្យញ្ជនៈ "ល" ។

មេរៀនទី ១៨

# ព្យញ្ជនៈផ្ញើជើង

## ស្ក ស្គ ស្ង ស្ញ ស្ដ

ស្ករ ស្ការ ស្គរ ស្គម ស្ងាប ស្ងៀម ស្ញើប ស្ញែង ស្ដាយ ស្ដាំ

ស្ករស ស្គមស្គាំង ស្គុសស្គាយ ស្ងាត់ស្ងៀម ស្ញប់ស្ញែង សោកស្ដាយ

ផ្ការីកស្គុសស្គាយនៅក្នុងសួនច្បារ ។

ប្រាសាទព្រះវិហារគួរឱ្យស្ញប់ស្ញែង ។

ពូស្ដឹងនៅស្ងៀមស្ងាត់ ព្រោះស្ដាយស្គរ ។

មីងសានមានរាងស្គម តែចូលចិត្តហូបស្ករ ។



ប្រាសាទព្រះវិហារ



ស្គរ

មេរៀនទី
១៩

# ព្យញ្ជនៈផ្ញើជើង

## ស្ល ស្ម ស្ន ស្ប ស្ត

ស្ថិត ស្ទឹង ស្ងួច ស្ងួង ស្អប់ ស្នែង ស្និត ស្បែក ស្បៃ ស្ពាន ស្តែ

ស្ថិតស្ថេរ ស្ងួចត្រី ស្នែងខ្ទឹង ស្និតចេក
ស្បែកជើង ស្បៃរឿង ស្តែក្តោប ស្ពានអាកាស

រាជធានីភ្នំពេញមានស្ពានអាកាស ។
ម្សិលមិញ ខ្ញុំស្ទុះស្ទាទៅស្ទូចត្រីឯស្ទឹងក្បែរស្ពានថ្ម ។
នារីកាន់ស្បៃ ពាក់ស្បែកជើង ទៅបេះស្បៃរឿង និងដកស្តៃ ។



រាជធានីភ្នំពេញមានស្ពានអាកាស ។



ស្ទូង

## លំហាត់

ចូរសរសេរអក្សរផ្ទង់អំពីព្យញ្ជនៈ "ស" ។

# មេរៀនទី ២០ ព្យញ្ជនៈផ្ញើជើង

## ស្ម ស្រ ស្ល ស្វ ស្អ

ស្មា ស្មៅ ស្មោះ ស្រក់ ស្រែ ស្រេក ស្លាប ស្លូត

ស្លេក ស្វា ស្វាយ ស្វិត ស្អាត ស្អុយ ស្អែក

ស្មោះត្រង់ ស្រុកស្រែ ស្រេកឃ្លាន ស្លេកស្លាំង ស្លូតបូត

ស្វាហាប់ ស្វិតស្វាញ ស្អាតស្អំ ស្អុះស្អាប់

ស្វាស៊ីផ្លែស្វាយទុំ ។

ថ្ងៃនេះ មេឃក្តៅស្អុះស្អាប់ ។

អ៊ុំស្មាញបោចស្មៅដាក់ក្នុងស្បោង ។

ថ្ងៃស្អែក ពូស្វិតទៅច្រូតស្រូវនៅឯស្រែ ។



ស្វា



ស្វាយ

# មេរៀនទី ២១ មេរៀនសាឡើងវិញព្យញ្ជនៈផ្ញើជើង

## ម្យ ម្ហ ម្អ ល្ង ល្ព ល្យ ស្គ ស្ង ស្ន ស្ព

ម្សិល ម្សៅ ម្ហូប ម្អម ល្ងង់ ល្ងាច ល្ពៅ ល្មុត ល្មម ល្មើង ល្វា

ស្គរ ស្គម ស្ទើប ស្វែង ស្មឹង ស្ងួច ស្ពាន ស្ពៃ

ឆ្នាំម្សាញ់ ម្ទេសម្ហូប ម្អមក្តាម ល្ងង់ខ្លៅ ផ្លែល្ពៅ ល្មុតថ្ម ល្វាចេក

ស្គមស្គាំង ស្ងប់ស្ងែង ស្មុះស្មា ស្ពានអាកាស

ត្រីឆ្អិនធ្វើមាត់ម្ហូបៗក្បែរគល់ម្អម ។

ប្រាសាទព្រះវិហារគួរឱ្យស្ងប់ស្ងែង ។

រាជធានីភ្នំពេញមានស្ពានអាកាស ។

ពេលល្ងាច សុខាដងទឹកស្រោចល្ពៅ និងកូនល្មុត ។

## លំហាត់

ចូរគូសសញ្ញាព្រួញភ្ជាប់ពាក្យទៅនឹងរូបភាព រួចអាន ។

| ក្តាម |
| --- |
| ល្ពៅ |
| ល្មុត |
| ស្ពៃក្តោប |



មេរៀនទី
២២

# ព្យាង្គតម្រួត

## ង្ក ង្ខ ង្គ ង្ឃ

បង្កាត់ បង្កង កង្កែប អង្កុរ អង្កាម ដង្ខៅ បង្ខិត បង្ខំ បង្ខូច

បង្គន់ គង្គា បង្គី គីង្គក់ អង្គុយ សង្ឃឹម មង្ឃុត សង្ឃរា

បង្កបង្កើត បង្ខិតបង្ខំ

ពូគីបង្ខំកូនឱ្យហូបមង្ឃុត ។

មីងយ៉ានកើបអង្កុរ និងអង្កាម ។

ពូភោគចាប់គីង្គក់ និងកង្កែបដាក់ក្នុងបង្គី ។



កង្កែប



មង្ឃុត

## លំហាត់

ចូរសរសេរអក្សរផ្តុំអំពីព្យញ្ជនៈ “ង” ។

មេរៀនទី
២៣

# ព្យាង្គតម្រួត

## ង្រ ង្វ ង្ស ង្គ ង្ក

ពង្រីក បង្រួម អង្រួន ចង្វា ចង្វាក់ បង្វិល អង្វរ បង្វែរ
សង្ស័យ កង្ហារ បង្ហាញ សង្ហា ចង្អេរ ចង្កុល បង្អួច

ត្រីចង្វា ជ្រោយចង្វា ចង្កុលដៃ បង្រួមបង្រួម

សុខាអង្វរម្ដាយសុំទិញកង្ហារ ។
តាគង់ត្បាញចង្អេរក្រោមដើមពង្រ ។
មីងព្រឹមបង្ហាញអំពីរបៀបកាត់ត្រីចង្វា ។



កង្ហារ



ចង្អេរ

មេរៀនទី ២៤

# ព្យញ្ជនៈតម្រួត

ញ្ច ញ្ជ ញ្ឆ ញ្ឈ ញ្ញ

កញ្ចែ ចិញ្ចឹម បញ្ចុក កញ្ឆែត បញ្ឆិត បញ្ឆោត កញ្ជើ អញ្ជើញ
ជញ្ជាត់ ជញ្ជាំង បញ្ឈរ បញ្ឈប់ បញ្ញើ កញ្ញា បញ្ញា សញ្ញា

កញ្ចាញ់ច្រាស នំបញ្ចុក បញ្ឆិតបញ្ឆៀង ភ្លើងសញ្ញា ជញ្ជាំងថ្ម ខែកញ្ញា

បញ្ញាបេះកញ្ឆែតដាក់កញ្ជើ ។
យើងគោរពភ្លើងសញ្ញាចរាចរណ៍ ។
កញ្ញាជញ្ជាត់បានត្រីកញ្ចាញ់ច្រាសដាក់ក្នុងកញ្ជើ ។



នំបញ្ចុក



សញ្ញាចរាចរណ៍

មេរៀនទី
២៥

# ព្យាង្គតម្រួត

## ណ្ដ ណ្ឌ ណ្ណ

កណ្ដាល កណ្ដាប់ បណ្ដូល កណ្ដៀត កណ្ដោល
អណ្ដើក សណ្ឋាន សណ្ឋិត បណ្ណាល័យ

កណ្ដៀតក្អម កណ្ដោចកណ្ដែង ឯកសណ្ឋាន សណ្ឋាគារ

កងទ័ពស្លៀកពាក់ឯកសណ្ឋាន ។
បណ្ដូលកំពុងអានសៀវភៅក្នុងបណ្ណាល័យ ។
តាជុំអង្គុយកណ្ដោចកណ្ដែងក្រោមដើមកណ្ដោល ។


បណ្ណាល័យ


សណ្ឋាគារ

# មេរៀនទី ២៦ មេរៀនសាឡើងវិញព្យាង្គតម្រួត

ង្ក ង្គ ង្រ ង្វ ង្ហ ង្ស ញ្ក ញ្ឈ ញ្ជ ញ្ញ ណ្ត

បង្កង កង្កែប គីង្គក់ អង្គុយ ពង្រីក បង្រួម ចង្វា បង្វិល កង្ហារ បង្ហាញ

ចង្កេរ បង្ស៊ច កញ្ចែ ចិញ្ចឹម កញ្ជែត បញ្ឈិត ជញ្ជាត់ អញ្ជើញ បញ្ឈប់

កញ្ញា សញ្ញា កណ្ដាប់ កណ្ដៀត កណ្ដោល អណ្ដើក

បង្កបង្កើត បង្រួបបង្រួម ត្រីចង្វា ចង្កូលដៃ កញ្ចាញ់ច្រាស

បញ្ជិតបញ្ជៀង ភ្លើងសញ្ញា កណ្ដោចកណ្ដែង

ត្រីចង្វាហែលបង្វិលខ្លួនក្នុងគង្គា ។

យើងគោរពភ្លើងសញ្ញាចរាចរណ៍ ។

កញ្ញាជញ្ជាត់បានត្រីកញ្ចាញ់ច្រាសដាក់ក្នុងកញ្ជើ ។

តាជុំអង្គុយកណ្ដោចកណ្ដែងក្រោមដើមកណ្ដោល ។

លំហាត់

ចូរសរសេរពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. ....ង្កែប ៖ ..................

២. ចិញ្ច.... ៖ ..................

៣. ....ញ្ញ.... ៖ ..................

មេរៀនទី ២៧

# ព្យញ្ជនៈតម្រួត

## ន្ត ន្ទ ន្ធ ន្ថ ន្ល ន្យ

កន្ទឹប បន្ត បន្តិច កន្តោរ បន្ថយ បន្ថែម កន្ទុយ បន្ទាត់ អន្ទង់ កន្លាយ

បន្ទូរ សន្លោ កន្លង់ ទន្លេ បន្លែ កន្សែង ទន្សាយ សន្សើម

បន្តិចបន្តួច ឋានន្តរ បន្ថែមបន្ថយ កន្ទុយអន្ទង់

សន្លោសន្លៅ បន្លែបង្ការ កន្ទុំរុយ

គេដាំបន្លែនៅតាមមាត់ទន្លេ ។

ទន្សាយផឹកទឹកសន្សើម ។

មីងខុមលក់កន្ទក់យកលុយទិញអន្ទង់ ។



អន្ទង់



ទន្សាយ

## លំហាត់

ចូរសរសេរអក្សរផ្ទង់អំពីព្យញ្ជនៈ "ន" ។

មេរៀនទី
# ២៨ ព្យញ្ជនៈតម្រួត

## ម្ក ម្ច ម្ទ ម្ប ម្ល ម្ស ម្អ

តម្កល់ ចម្ការ ចម្ងាយ ចម្ងល់ កម្ចាត់ កម្ចី សម្បក សម្បុរ សម្បូរ
សម្បុក សម្បត្តិ សម្លស្ស កម្សាន្ត កម្សត់ កម្ពុត ចម្អិន សម្អាត

ចម្ការល្មុត ចម្ងាយផ្លូវ សម្បកចេក កម្ចាត់កម្ចាយ

សម្លស្សទៅកម្សាន្តឯចម្ការ ។
នារីសម្អាតបន្ទប់រៀន ។
ប្រទេសយើងសម្បូរសម្បត្តិធម្មជាតិ ។



នារីសម្អាតបន្ទប់រៀន ។



ចម្ការ

មេរៀនទី
២៩

# ព្យាង្គតម្រួត

## ម្ត ម្ភ ម្ម ម្រ ម្ល

កម្ពុជា ជម្ពូ គម្ពីរ សម្ពាយ សម្ភារៈ សម្ភាស កម្មករ កម្រើក សម្រាក
បម្រើ គម្រប កម្លាំង សម្ល សម្លាញ់ សម្លក់ ចម្លង ចម្លាក់

កម្សត់កម្រ សម្ពោងសម្ពាយ សម្លក់សម្លឹង សម្លកកូរ

ពេលថ្ងៃ កម្មករសម្រាកយកកម្លាំង ។
ពូឈុំយួរសម្ភារៈសម្ពោងសម្ពាយ ។
កែវ និងកន ជាសម្លាញ់កម្សត់កម្រនឹងគ្នា ។



ជម្ពូ



សម្លកកូរ

លំហាត់

ចូរសរសេរអក្សរផ្តង់អំពីព្យញ្ជនៈ "ជ" ។

មេរៀនទី
៣០

# ព្យាង្គតម្រួត

## ង្ក្រ ង្គ្រ ញ្ច្រ ន្ត្រ ន្ទ្រ

ចង្ក្រង់ អង្ក្រង បង្ក្រាប សង្គ្រាម បង្គ្រប់ អង្គ្រង កញ្ច្រែង
បញ្ច្រុក បញ្ច្រាស កញ្ជ្រឹល កញ្ជ្រូក កញ្ជ្រោង បញ្ជ្រាប
កន្ត្រប់ តន្ត្រី កន្ត្រៃ មន្ត្រី ឥន្ទ្រី ទន្ទ្រាន ចន្ទ្រា

ត្រីកន្ត្រប់ ទន្ទ្រានខេត្ត តន្ត្រីសម័យ ត្រីកន្ត្រងប្រេង

គេយកកុមារទៅចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹល ។
ចន្ទ្រាកាប់ចិញ្ច្រាំដើមទន្ទ្រានខេត្តទុកធ្វើជី ។
កញ្ជ្រោងសង្គ្រប់ទន្សាយនៅក្រោមដើមអង្គ្រង ។
ត្រីកន្ត្រប់ហែលដេញត្រីកន្ត្រងប្រេងនិងត្រីកញ្ជ្រូក ។



កញ្ច្រែង



កញ្ជ្រោង

# មេរៀនទី ៣១ មេរៀនសាឡើងវិញព្យាង្គតម្រួត

## ន្ត ន្ថ ន្ទ ន្ធ ន្ល ន្ស ង្ក្រ ង្គ្រ ញ្ច្រ ញ្ជ្រ ន្ត្រ ន្ទ្រ

បន្ត បន្តិច កន្ថោរ បន្ថែម អន្ទង់ បន្ធូរ

សន្ធោ កន្លង់ បន្លែ កន្សែង ទន្សាយ

អង្ក្រង សង្គ្រាម បង្គ្រប់ កញ្ច្រែង កន្ត្រប់ មន្ត្រី ឥន្ទ្រី

ត្រីកន្ត្រប់ កន្ទុំរុយ ទន្ទ្រានខេត្ត តន្ត្រីសម័យ

បន្តិចបន្តួច បន្ថែមបន្ថយ កន្ទុយអន្ទង់ សន្ធោសន្ធៅ បន្លែបង្ការ

ទន្សាយផឹកទឹកសន្សើម ។

គេយកកុមារទៅចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹល ។

ត្រីកន្ត្រប់ហែលដេញត្រីកន្ត្រង់ប្រែងនិងត្រីកញ្ច្រូក ។

### លំហាត់

ក. ចូរសរសេរពាក្យពីក្រោមរូបភាពឱ្យបានត្រឹមត្រូវ ។

   

................ ................ ................ ................

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។

កញ្ជ្រឹល　　កុមារ

គេយក ................ទៅចាក់ថ្នាំបង្ការជំងឺ ............. ។

មេរៀនទី
៣២

# បវេសនកាល

## អំណាន



ថ្ងៃនេះជាថ្ងៃចូលរៀនដំបូង ។

ព្រឹកនេះ ម្ដាយសុភីដាស់កូនពីព្រលឹម ។ គាត់ប្រាប់សុភីឱ្យរៀបចំខ្លួនទៅសាលារៀន ។ សុភីភ្ញាក់ពីដំណេក រួចងើបចេញពីគ្រែ ។ នាងនិយាយ ៖ អូ! ថ្ងៃនេះ ជាថ្ងៃបវេសនកាលផង ។ តើម៉ាក់អញ្ជើញទៅជាមួយកូនដែរឬទេ ? ទេកូន! ឆ្នាំនេះ កូនធំហើយ ។ កូនទៅជាមួយប្អូន ហើយមើលប្អូនផងណា៎! ។ សុភីនិងប្អូនទៅងូតទឹក រួចស្លៀកពាក់ រៀបចំកាតាប ទើបសំពះលាម្ដាយឪពុកទៅសាលារៀន ។

ពួកគេទៅសាលារៀនទាំងពីរនាក់ ដោយទឹកមុខរីករាយ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

អញ្ជើញ អានថា អាញ់-ជើញ

បវេសនកាល អានថា ប៉ះ-វេ៉-សះ-ន៉ះ-កាល

ខ. ពន្យល់ពាក្យ

បវេសនកាល : ថ្ងៃចូលរៀនដំបូងនៅដើមឆ្នាំសិក្សា ។

គ. ពាក្យន័យដូចនឹងពាក្យ "ម៉ាក់"

ម៉ាក់ ម៉ែ ម្ដាយ មាតា

ឃ. ពាក្យផ្ទុយ

បវេសនកាល ≠ វិស្សមកាល   រីករាយ ≠ កើតទុក្ខ

## សំណួរ

១. តើនៅថ្ងៃបវេសនកាល សុភីទៅរៀនជាមួយនរណា ?

២. តើម្ដាយសុភីផ្ដាំសុភីឱ្យធ្វើអ្វី ?

៣. មុននឹងទៅសាលារៀន តើសុភីនិងប្អូនធ្វើអ្វីខ្លះ ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទៀងនិងប្រកបឱ្យបានត្រឹមត្រូវ ។

ព្រលឹម សាលារៀន បវេសនកាល អញ្ជើញ ស្លៀកពាក់ ម្ដាយ ឪពុក

ខ. ចូរអានល្បះខាងក្រោមរួចប្រាប់ឈ្មោះមនុស្សនិងវត្ថុឱ្យបានត្រឹមត្រូវ ។

សុភីនិងប្អូន ទៅងូតទឹក រួចស្លៀកពាក់ រៀបចំកាតាប ទើបសំពះលាម្ដាយឪពុកទៅសាលារៀន ។

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យខាងក្រោម ។

| | | | | |
|---|---|---|---|---|
| ព្រលឹម | សាលារៀន | បរទេសនកាល | អញ្ជើញ | គ្រែ |
| ប្រញាប់ | ស្លៀកពាក់ | ម្ដាយ | សំពះ | ឪពុក |

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។

ធំៗ | ចម្រុះពណ៌ | ពណ៌ក្រហម

១. សាលារៀនខ្ញុំសង់អំពីឈើប្រក់ក្បឿង ................ ។

២. នៅជុំវិញសាលារៀន មានដើមឈើ ............ជាច្រើន ។

៣. នៅក្នុងសួនច្បារមានផ្កា ........................... ។

បក់រវិចៗ | ស | ខៀវ | ក្រហម | ទង់ជាតិ | ប្រាសាទ

១. នៅចំកណ្ដាលទីធ្លាសាលារៀន មានដង ............មួយខ្ពស់ ។

២. ទង់ជាតិ ..........................នៅពេលត្រូវខ្យល់ ។

៣. ទង់ជាតិមានពណ៌ ........និង .......ហើយមានរូប ....ពណ៌ ....... ។

ធំ | ញញឹម | ខ្ពស់ | ស្លូតបូត

១. លោកគ្រូខ្ញុំឈ្មោះសារិន ។ គាត់មានមាឌ ......ហើយ ........ ។

២. លោកគ្រូមានទឹកមុខ ............................ជានិច្ច ។

៣. គាត់ជាមនុស្ស .............ហើយចិត្តល្អណាស់ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ “សាលា”

# មេរៀនទី ៣៣ ពេលចេញលេង

## អំណាន



ម៉ឹង ! ម៉ឹង ! ម៉ឹង ជាស្នូរជួងចេញលេង។ សិស្សទាំងឡាយចេញពីបន្ទប់រៀនប្រកបដោយទឹកមុខរីករាយ ។

នៅក្នុងទីធ្លាដ៏ធំទូលាយ សិស្សានុសិស្សនាំគ្នាលេងល្បែងជាក្រុមៗ ។ ពួកគេលេងឃ្លី លេងមីក លោតអន្ទាក់ លេងត្រែះ លេងវែក លេងបាយខុំ លេងបាល់ និងទាត់សី ។ សិស្សខ្លះ អង្គុយជជែកគ្នាក្រោមដើមឈើដែលមានម្លប់ត្រឈឹងត្រឈៃ ។ សិស្សខ្លះទៀត រត់ប្រឡែងគ្នាលេងយ៉ាងសប្បាយ ។ នៅក្នុងបណ្ណាល័យ មានសិស្សជាច្រើនកំពុងអានសៀវភៅ ។

កុមារា កុមារីទាំងឡាយ គួរលេងល្បែងណាដែលមានប្រយោជន៍និងមិនបណ្ដាលឱ្យមានគ្រោះថ្នាក់ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

| | | |
|---|---|---|
| សិស្សានុសិស្ស | អានថា | សឹស-សា-នុ-សឹស |
| ត្រែះ | អានថា | ត្រែស |
| បណ្ណាល័យ | អានថា | ប៉ុន-ណា-ឡៃ |

ខ. ពន្យល់ពាក្យ

សិស្សានុសិស្ស : សិស្សទាំងឡាយ សិស្សតូចនិងសិស្សធំ ។

បណ្ណាល័យ : កន្លែងសម្រាប់តម្កល់ទុកសៀវភៅ គម្ពីរ ក្បួនច្បាប់ ។

ត្រែះ : ឈ្មោះល្បែងលេងដោយប្រើខ្នាច់ ចង្កឹះ ឬគ្រាប់អ្វីៗ ។

កុមារាកុមារី : ក្មេងប្រុសស្រី ។

គ. ពាក្យផ្ទុយ

ទូលាយ ≠ ចង្អៀត សប្បាយ ≠ កើតទុក្ខ

## សំណួរ

១. តើសិស្សមានទឹកមុខដូចម្ដេច នៅពេលចេញលេង ?

២. តើពួកគេលេងអ្វីខ្លះ នៅពេលចេញលេង ?

៣. តើនៅក្នុងបណ្ណាល័យ សិស្សកំពុងធ្វើអ្វី ?

៤. តើសិស្សគួរលេងល្បែងដូចម្ដេច ?

## លំហាត់

ក. ចូរអានអត្ថបទឡើងវិញដោយបណ្ដាក់គ្នា ។

ខ. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

បណ្ណាល័យ ត្រែះ សិស្សានុសិស្ស កុមារាកុមារី អង្គុយ ប្រយោជន៍ ស្ទូរ ម្លប់

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យខាងក្រោម ។

| បណ្ណាល័យ ក្រុម ម្លប់ កុមារា កុមារី ស្នូរ សិស្សានុសិស្ស ត្រែះ អង្គុយ |
|---|

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោម ។

| គ្រោះថ្នាក់ | រីករាយ | បណ្ណាល័យ | ប្រយោជន៍ | សិស្សានុសិស្ស |
|---|---|---|---|---|

១. សិស្សទាំងឡាយ ចេញពីបន្ទប់រៀនប្រកបដោយទឹកមុខ ........... ។

២. នៅក្នុងទីធ្លាដ៏ធំទូលាយ .............នាំគ្នាលេងល្បែងជាក្រុមៗ ។

៣. នៅក្នុង ..................មានសិស្សជាច្រើនកំពុងអានសៀវភៅ ។

៤. សិស្សានុសិស្សទាំងឡាយ គួរលេងល្បែងណាដែលមាន ........និង មិនបណ្ដាលឱ្យមាន .......ដល់ខ្លួន ។

គ. ចូរបំពេញល្បះតាមរូបខាងក្រោមឱ្យបានត្រឹមត្រូវ ។



១. កុមារីកំពុង ........... ។



២. កុមារាកំពុង ........... ។

មេរៀនទី
៣៤

# ឆ្មាចង់ទៅរៀន

## មេសូត្រ



(បទកាកគតិ)

ពេលព្រឹកព្រលឹម នារីញញឹម រៀបចំកាយា
ស្លៀកពាក់ស្អាតបាត ស្រស់ស្រូបអាហារ នាងលាម៉ាក់ប៉ា
ទៅសាលារៀន ។

ឆ្មាឃើញនារី លើកជើងមុខពីរ ផ្ញើប្ញកអៀនប្រៀន
ចង់សុំទៅដែរ តែឆ្មាមិនហ៊ាន រវល់តែអៀន
នាងទៅរៀនបាត់ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ឫកពា អានថា រឹក-ពា

កាយា អានថា កាយ-យ៉ា

ខ. ពន្យល់ពាក្យ

ឫកពា : បែបបទ សណ្ដាប់ធ្នាប់ ។

កាយា : រូប ខ្លួន ។

គ. ពាក្យន័យដូចនឹងពាក្យ "ស្រស់ស្រូប"

ស្រស់ស្រូប ទទួលទាន ហូប ពិសា ស៊ី ឆី ឆាន់ សោយ បរិភោគ

## សំណួរ

១. តើពេលព្រឹកព្រលឹមនរណារៀបចំខ្លួនទៅសាលារៀន ?

២. តើនារីធ្វើអ្វីខ្លះ មុនទៅសាលារៀន ?

៣. តើនរណាចង់ទៅរៀន ជាមួយនារី ?

៤. តើឆ្មាបានទៅរៀន ជាមួយនារីដែរឬទេ ? ព្រោះអ្វី ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោម ដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| ព្រលឹម | ស្លៀកពាក់ | កាយា | អាហារ | ស្អាតបាត | ស្រស់ស្រូប |
| ហ៊ាន | អៀនប្រៀន | | | | |

ខ. ចូរសូត្រមេសូត្រខាងលើតាមគ្រូរបស់អ្នកឱ្យបានត្រឹមត្រូវ ។

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យខាងក្រោម ។

| | | | | |
|---|---|---|---|---|
| ព្រលឹម | កាយា | អាហារ | ស្អាត | ហ៊ាន |
| ប្ញូក | ពីរ | រវល់ | ស្រស់ស្រូប | អៀនប្រៀន |

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។

អៀនប្រៀន | អាហារ | ព្រលឹម | ញញឹម | ហ៊ាន

ពេលព្រឹក ........... នារី ............... រៀបចំកាយា

ស្លៀកពាក់ស្អាតបាត ស្រស់ស្រូប .......... នាងលាម៉ាក់ប៉ា

ទៅសាលារៀន ។

ឆ្មាឃើញនារី លើកជើងមុខពីរ ធ្វើប្ញូក .............

ចង់សុំទៅដែរ តែឆ្មាមិន ........... រវល់តែអៀន

នាងទៅរៀនបាត់ ។

គ. ចូរមើលរូប រួចបំពេញល្បះខាងក្រោម ដើម្បីពណ៌នាអំពីមនុស្ស វត្ថុ និងទីកន្លែងក្នុងរូបនីមួយៗ ។

១. តុនេះធ្វើអំពី................. ។

២. នៅលើតុមាន................ ។

៣. អ្នកគ្រូខ្ញុំឈ្មោះ ............. ។

៤. ខ្ញុំស្រឡាញ់........... ណាស់ ។

៥. សាលារៀនខ្ញុំឈ្មោះ ......... ។

៦. សាលារៀននេះ .... ហើយស្អាត ។





មេរៀនទី ៣៥

# ការណែនាំមិត្តឱ្យស្គាល់គ្នា

## ការនិយាយ

ខាងក្រោមនេះជាការសន្ទនា ណែនាំឱ្យស្គាល់មិត្តនៅពេលជួបគ្នាដំបូង ។




បូណា : សួស្តីសុភី! នេះគឺតារា ។ គេជាមិត្តខ្ញុំ ។

សុភី : សួស្តីតារា ! ខ្ញុំរីករាយណាស់ដោយបានស្គាល់មិត្ត !

តារា : សួស្តីសុភី ! ខ្ញុំក៏រីករាយដូចមិត្តដែរ ។
តើសុភីរៀននៅថ្នាក់ណា ?

សុភី : ខ្ញុំរៀនថ្នាក់ទី ២ "ក" ។ តើឯងសុខសប្បាយឬទេ ?

តារា : អរគុណ ! ខ្ញុំសុខសប្បាយទេ ។

## សំណួរ

១. តើបូណាណែនាំនរណាឱ្យស្គាល់នរណា ?

២. តើតារាជាមិត្តរបស់អ្នកណា ?

៣. តើសុភីនិយាយដូចម្ដេចខ្លះទៅកាន់តារា ?

៤. តើសុភីសួរតារាដូចម្ដេច ?

## លំហាត់

ចូរនិយាយបំពេញសម្ដីសន្ទនាតាមរូបភាពខាងក្រោម ដោយប្រើឈ្មោះផ្ទាល់ខ្លួន ។



(ឈ្មោះ ...) ! នេះគឺ ........ ។ គេជាមិត្តរបស់ខ្ញុំ ។

សួស្ដី ..... ! ខ្ញុំរីករាយណាស់ដោយ ...... ។ តើ .....រៀននៅថ្នាក់ណា ?

ខ្ញុំរៀន ........... ។

ខ្ញុំក៏ ........ ។

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យខាងក្រោម ។

| |
|---|
| សួស្តី មិត្ត រីករាយ ឯង ធម្មតា រៀន ស្គាល់ ថ្នាក់ សុខសប្បាយ អរគុណ |

ខ. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញសម្ដីសន្ទនារវាងអ្នកទាំងបីខាងក្រោម ។

| | | | | |
|---|---|---|---|---|
| ល្អណាស់ | រៀន | លោកអ៊ំ | អរគុណ | ជម្រាបសួរ |

សានបានណែនាំសុភីស្គាល់ឪពុកខ្លួន ។

បូណា : សុភី ! នេះឪពុករបស់ខ្ញុំ ។

សុភី : ...........លោកអ៊ំ ។

ឪពុកបូណា : បាទ ! .......ក្មួយ ។ តើក្មួយ............ថ្នាក់ទីប៉ុន្មាន ?

សុភី : ចាស ! .....................ខ្ញុំរៀនថ្នាក់ទី ២ "ក"ជាមួយបូណាដែរ ។ តើលោកអ៊ំសុខសប្បាយឬទេ ?

ឪពុកបូណា : ..................... ! អ៊ំសុខសប្បាយទេ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ " រីករាយ " ។

មេរៀនទី ៣៦

# សត្វក្រសារ

## អំណាន



មានសត្វក្រសារមួយ ឈរចាំចឹកត្រីនៅមាត់បឹង ។

ពេលនោះ មានត្រីចង្វាមួយបានហែលពីមុខវា ។ ក្រសារគិតថា ត្រីចង្វានេះតូចណាស់ ស៊ីក៏មិនឆ្អែតដែរ រង់ចាំត្រីធំៗ ចឹកស៊ីតែមួយពីរឆ្អែតតែម្ដង ។ ត្រីចង្វាក៏ហែលបាត់ទៅ ។ បន្តិចមក មានកូនត្រីក្រាញ់មួយហែលមកទៀត វានៅតែមិនចឹកស៊ី ។ ក្រោយមក ក៏មានកូនត្រីផ្ទក់មួយហែលមកទៀត ក្រសារគិតថា បន្តិចទៀតនឹងបានជួបត្រីធំៗជាងនេះជាមិនខាន ។ ត្រីផ្ទក់ក៏ហែលទៅបាត់ទៀត ។ តាំងពីព្រឹកដល់ព្រលប់ ក្រសាររង់ចាំត្រីធំៗមិនឃើញសោះ ។

ក្រសារវិលរកទ្រនំវិញ ទាំងក្ដីស្រេកឃ្លាន ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ចង្វា អានថា ចង់-វ៉ា

បន្តិច អានថា បន់-តិច

ខ. ពន្យល់ពាក្យ

ចឹក : ខាំដោយចំពុះ ។

ទ្រនំ : ទីកន្លែងដែលសត្វស្លាបតែងទំ ។

គ. ពាក្យន័យដូចនឹងពាក្យ "ទ្រនំ"

ទ្រនំ សម្បុក លំនៅ

ឃ. ពាក្យផ្ទុយ

ធំ ≠ តូច ឃ្លាន ≠ ឆ្អែត

សំណួរ

១. តើសត្វក្រសាររង់ចាំចឹកត្រីនៅឯណា ?

២. តើក្រសារឃើញត្រីអ្វី មុនដំបូងគេ ?

៣. តើក្រសារឃើញត្រីអ្វីខ្លះ ហែលពីមុខខ្លួន ?

៤. តើក្រសារចឹកត្រីទាំងនោះស៊ីដែរឬទេ ? ព្រោះអ្វី ?

លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទួំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ត្រីចង្វា ត្រីក្រាញ់ ត្រីឆ្តោ ងងឹត ទ្រនំ ស្រេកឃ្លាន ក្រសារ ព្រលប់

សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យខាងក្រោម ។

គិត ស៊ី ក្រោយ ក្រសារ ងងឹត ទ្រនំ ឆ្អែត ព្រលប់ បន្តិច ស្រេកឃ្លាន

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។

| | | | | | |
|---|---|---|---|---|---|
| មាត់បឹង | តូច | ត្រីចង្វា | ហែល | ទ្រនំ | ស្រេកឃ្លាន |

១. មានក្រសារមួយឈរចាំចឹកត្រីនៅ ................ ។

២. ពេលនោះមាន ................. តូចមួយបានហែលពីមុខវា ។

៣. សត្វក្រសារគិតថា ត្រីចង្វានេះ ......... ណាស់ ស៊ីក៏មិនឆ្អែតដែរ ។

៤. ត្រីចង្វាក៏ .......... បាត់ទៅ ។

៥. ក្រសារវិលទៅរក ........... វិញ ទាំងក្តី ............ ។

គ. ចូរមើលរូប រួចបំពេញល្បះឱ្យបានត្រឹមត្រូវនិងបានសមស្របតាមរូប ។



១. នេះជាថ្ងៃ ......... ។ សាលារៀនមាន .,. ។

២. ខ្ញុំបាន ..................... និង ..................... ជាមួយមិត្តភក្តិខ្ញុំ ។

# មេរៀនទី ៣៧ ការខិតខំរៀនសូត្រ

## អំណាន



ការងារទីមួយរបស់កុមារ គឺការខិតខំសិក្សារៀនសូត្រ ។

កុមារត្រូវឆ្លៀតពេលខិតខំរៀនសូត្រឱ្យបានខ្ជាប់ខ្ជួន ។ ការរៀនសូត្របានល្អគឺដោយសារការព្យាយាម ។ បើការព្យាយាមនេះផ្ដល់លទ្ធផលល្អ អ្នកដែលសប្បាយចិត្តជាងគេ គឺខ្លួនឯងផ្ទាល់ ។ លទ្ធផលល្អនេះ ក៏អាចចាត់ទុកថា ជាការតបស្នងសងគុណមាតាបិតានិងលោកគ្រូអ្នកគ្រូរបស់ខ្លួនផងដែរ ។

ការខិតខំរៀនសូត្រនឹងធ្វើឱ្យកុមារមានអនាគតភ្លឺស្វាង ។

## ការរៀនពាក្យ

ក. អំណានពាក្យ

លទ្ធផល អានថា ឡាត់-ធៈ-ផល

មាតាបិតា អានថា មា-ដា-បិ-ដា

អនាគត អានថា អៈ-ណា-គត់

ខ. ពន្យល់ពាក្យ

លទ្ធផល : ផលដែលសម្រេចបាន ។

តបស្នង : សងគុណ ។

អនាគត : ពេលខាងមុខ ។

គ. ពាក្យន័យដូចនឹងពាក្យ “ព្យាយាម”

ព្យាយាម ខិតខំ ប្រឹងប្រែង អំណត់

ឃ. ពាក្យផ្ទុយ

គុណ ≠ ទោស ភ្លឺស្វាង ≠ ងងឹតងងល់

សំណួរ

១. តើការងារទីមួយរបស់កុមារគឺអ្វី ?

២. តើការសិក្សាទទួលបានលទ្ធផលល្អដោយសារអ្វី ?

៣. ដើម្បីតបស្នងសងគុណមាតាបិតានិងគ្រូ តើកុមារត្រូវធ្វើដូចម្តេច ?

៤. តើការខិតខំរៀនសូត្រនឹងធ្វើឱ្យកុមារមានអនាគតដូចម្តេច ?

លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទូំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ក្មេងខ្ចី ការងារ ដូច្នេះ ខ្ជាប់ខ្ជួន ព្យាយាម លទ្ធផល
សប្បាយ មាតាបិតា អនាគត ភ្លឺស្វាង

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម ។

| |
|---|
| ការងារ ខ្ជាប់ខ្ជួន លទ្ធផល មាតាបិតា ព្យាយាម<br>ការខិតខំរៀនសូត្រនឹងធ្វើឱ្យកុមារមានអនាគតភ្លឺស្វាង ។ |

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | |
|---|---|---|---|
| ភ្លឺស្វាង | រៀនសូត្រ | ជាងគេ | លោកគ្រូអ្នកគ្រូ |
| ការព្យាយាម | ចាត់ទុក | កុមារ | លទ្ធផល |

១. ការងារទីមួយរបស់ ........ គឺការខិតខំសិក្សារៀនសូត្រ ។

២. ដូច្នេះ កុមារត្រូវឆ្លៀតពេលខិតខំ ................ ឱ្យបានខ្ជាប់ខ្ជួន ។

៣. ការរៀនសូត្របានល្អគឺដោយសារ ................... ។

៤. បើការព្យាយាមនេះផ្ដល់នូវ ............... ល្អ អ្នកដែលសប្បាយចិត្ត ............... គឺខ្លួនឯងផ្ទាល់ ។

៥. លទ្ធផលល្អនេះ ក៏អាច .......... ថា ជាការតបស្នងសងគុណមាតាបិតា និង ...................... របស់ខ្លួនផងដែរ ។

៦. ការខិតខំរៀនសូត្រនឹងធ្វើឱ្យកុមារមានអនាគត ............. ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "ខិតខំ" ។

# មេរៀនទី ៣៨ រឿងស្ដេចក្អែកការកូន

## ការស្ដាប់



## សំណួរ

១. តើស្ដេចក្អែករៀបការកូននៅកន្លែងណា ?

២. ហេតុអ្វីបានជាអណ្ដើកមកដល់ក្រោយគេ ?

៣. ហេតុអ្វីបានជាអណ្ដើកធ្លាក់ចុះមកដល់ដីវិញ ?

## លំហាត់

ចូររៀបលំដាប់ព្រឹត្តិការណ៍រឿងដោយបង់លេខតាមលំដាប់ក្នុងប្រអប់ខាងក្រោម ។

☐ មួយរំពេចនោះ អណ្ដើកក៏របូតមាត់ពីកន្ទុយពស់ ធ្លាក់ខ្ពោកមកលើដីបណ្ដាលឱ្យស្រាំស្នូកនៅជាប់ស្នាមរហូតមកដល់សព្វថ្ងៃនេះ ។

☐ មានស្ដេចក្អែកមួយចាត់ឱ្យពួកពលទៅអញ្ជើញភ្ញៀវទាំងអស់មកស៊ីការកូន ។

☐ ពេលនោះ ពស់ក៏ឱ្យស្ដេចអណ្ដើកខាំកន្ទុយ ហើយលូនយោងអណ្ដើកឡើងទៅលើ ។



បោះពុម្ពផ្សាយ ឆ្នាំ ២០១៧PDH

☐ ស្តេចអណ្តើកខំវារទៅនឹងគេដែរ តែទៅដល់ក្រោយគេក៏ប្រទះឃើញពស់លូនបម្រុងនឹងទៅស៊ីការកូនស្តេចក្អែកដែរ ។

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យនិងល្បះខាងក្រោម ។

ភ្ញៀវ បម្រុង ផ្សំផ្គុំ អណ្តើក កន្ទុយ

អណ្តើករបូតមាត់ពីកន្ទុយពស់ធ្លាក់ខ្ពោកមកលើដី ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។

កន្ទុយ | អណ្តើក | ភ្ញៀវ | ស្នាម | ក្អែក | ហាម | ខំវារ | ឃើញ

១. មានស្តេច ....មួយចាត់ឱ្យពួកពលហើរហៅ ...ទាំងអស់មកស៊ីការកូន ។

២. ស្តេចអណ្តើក ..........ទៅនឹងគេដែរ តែទៅដល់ក្រោយគេក៏ប្រទះ .........ពស់លូនបម្រុងនឹងទៅស៊ីការកូនស្តេចក្អែកដែរ ។

៣. ពេលនោះ ពស់ក៏ឱ្យស្តេច ..........ខាំកន្ទុយ ហើយលូនយោងឡើងទៅលើដោយ ............ឱ្យប្រយ័ត្នមាត់ ។

៤. មួយរំពេចនោះ អណ្តើកក៏របូតមាត់ពី .......ពស់ធ្លាក់ ខ្ពោកមកលើដីបណ្តាលឱ្យស្រាំស្នូកនៅជាប់ ............រហូតមកដល់សព្វថ្ងៃនេះ ។



១. ពស់កំពុង ............. ។



២. អណ្តើកកំពុង ............ ។

# មេរៀនទី ៣៩ យើងទៅសាលារៀន

## ចម្រៀង



(លំនាំបទ ផ្កាយលើមេឃ)

មកមិត្តយើងអើយ កុំនៅកន្តើយទៅសាលារៀន
ដើរអែបខាងស្តាំតាមគ្រូបង្រៀន ទៅសាលារៀនឱ្យបានមុនគ្រូ ។(ពីរដង)
ដល់ពេលចេញលេង ពួកយើងក្មេងៗកុំបង្អង់យូរ
លេងល្បែងកម្សាន្តអារម្មណ៍បានធូរ កុំបង្អង់យូរលេងឱ្យសប្បាយ ។(ពីរដង)

## ការរៀនពាក្យ

ក. អំណានពាក្យ

អារម្មណ៍ អានថា អា-រ៉ម់

កន្ត្រៃយ		អានថា	កន់-តើយ

កម្សាន្ត		អានថា	កំ-សាន

ខ.	ពន្យល់ពាក្យ

កន្ត្រៃយ	:	ព្រងើយ មិនយកចិត្តទុកដាក់ ។

កម្សាន្ត	:	សម្រាកចិត្ត ធ្វើចិត្តឱ្យស្រាកស្រាន្ត ។

អារម្មណ៍	:	គ្រឿងទាក់ទាញចិត្ត គំនិត ការដឹង ។

គ.	ពាក្យន័យដូចនឹងពាក្យ "ដើរ"

ត្រាច់ យាង យាត្រា និមន្ត ធ្វើដំណើរ ចរ លីលា ប្រព្រឹត្ត

ឃ.	ពាក្យផ្ទុយ

មិត្ត ≠ សត្រូវ		ធូរ ≠ តឹង		យឺត ≠ ឆាប់

សំណួរ

១.	តើពួកគេនាំគ្នាទៅឯណា ?

២.	តើគេប្រញាប់ទៅសាលារៀនឱ្យបានមុនអ្នកណា ?

៣.	តើពេលចេញលេង ពួកគេនាំគ្នាធ្វើអ្វី ?

៤.	តើអ្នកចូលចិត្តរៀនផង លេងកម្សាន្តផងដែរឬទេ ? ព្រោះអ្វី ?

លំហាត់

ក.	ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| |
|---|
| កម្សាន្ត មិត្ត យើង អារម្មណ៍ ពាក្យ បង្រៀន កន្ត្រៃយ សាលារៀន ស្ដាំ |

ខ. ចូរប្រាប់ពាក្យចួនក្នុងបទចម្រៀង ឱ្យបានត្រឹមត្រូវ ។

១. ពាក្យ "អើយ" ចួននឹងពាក្យ ......................

២. ពាក្យ "សាលារៀន" ចួននឹងពាក្យ ...................

៣. ពាក្យ "យូរ" ចួននឹងពាក្យ...................

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យនិងល្បះខាងក្រោម ។

ដើរ យូរ បង្រៀន បង្គង់ មិត្ត

ល្បែងកម្សាន្ត ធ្វើឱ្យអារម្មណ៍យើងបានធូរ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| យើង | លោកគ្រូ | ស្តាំ | អារម្មណ៍ | ល្បែង |
|---|---|---|---|---|

១. យើងត្រូវដើរអែបខាង ................ ។

២. យើងត្រូវទៅដល់ថ្នាក់រៀនឱ្យបានមុន ............ ។

៣. ពេលចេញលេង យើងនាំគ្នាលេង ................កម្សាន្ត ។

៤. ល្បែងកម្សាន្តធ្វើឱ្យ ...................យើងបានធូរ ។

៥. នៅសាលារៀន ...........សប្បាយ ព្រោះបានរៀនផងលេងផង ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "ពេល" ។

# មេរៀនទី ៤០ ការធ្វេសប្រហែស

## អំណាន



ថ្ងៃនេះ អ្នកគ្រូបង្រៀនមេរៀនភាសាខ្មែរ ។ គាត់ប្រាប់ឱ្យសិស្សទាំងអស់បើកសៀវភៅអានមេរៀន ។ ធីតាបើកកាតាបរកសៀវភៅមិនឃើញសោះ ។ នាងងាកមើលឆ្វេងស្ដាំ រួចលូកវាវចុះឡើងៗ ។

ម៉ានី : ធីតា ! តើឯងកំពុងរកអ្វី ?

ធីតា : ខ្ញុំកំពុងរកសៀវភៅពុម្ពភាសាខ្មែរ ។

ម៉ានី : តើឯងទុកវានៅឯណា ?

ធីតា : ខ្ញុំទុកវានៅក្នុងកាតាប ។ តើឯងមានឃើញវាទេ ?

ម៉ានី : ទេ ! ខ្ញុំមិនឃើញវាទេ ។ ឯងរកនឹកមើល តើឯងទុកវានៅឯណា ?

ធីតា : ខ្ញុំទុកវាលើទូនៅផ្ទះឯនោះ! ខ្ញុំភ្លេចដាក់វាចូលក្នុងកាតាប។

ម៉ានី : បើអ៊ីចឹង! ឯងមើលសៀវភៅជាមួយខ្ញុំទៅ!

## ការរៀនពាក្យ

ក. អំណានពាក្យ

ពុម្ព អានថា ពុំ

ខ. ពន្យល់ពាក្យ

ធ្វេសប្រហែស : ភ្លេច ប្រហែស។

រាវ : ជ្រាវរកដោយដៃ។

ពុម្ព : រូបតំណាង សំណាក។

គ. ពាក្យន័យដូចនឹងពាក្យ "ឱ្យ"

ឱ្យ ជូន ប្រគេន ថ្វាយ ប្រទាន

ឃ. ពាក្យផ្ទុយ

ភ្លេច ≠ ចាំ

ប្រហែស ≠ ប្រយ័ត្ន

## សំណួរ

១. តើអ្នកគ្រូបង្រៀនមេរៀនអ្វី ?

២. តើធីតារកសៀវភៅអ្វី ?

៣. តើធីតាទុកសៀវភៅនៅឯណា ?

៤. តើប្អូនត្រូវធ្វើដូចម្តេច ដើម្បីកុំឱ្យភ្លេចសៀវភៅ ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទួនិងប្រកបឱ្យបានត្រឹមត្រូវ ។

ថ្ងៃ មេរៀន ប្រាប់ សៀវភៅ ឆ្វេង ស្ដាំ លូក រាវ អឺចឹង គុម្ព

## សំណេរ

ក. ចូរសរសេរតាមអានចម្លងកន្សោមពាក្យនិងល្បះខាងក្រោម ។

ធ្វេសប្រហែស គ្រូបង្រៀន សៀវភៅពុម្ព ឆ្វេងស្ដាំ

ខ្ញុំកំពុងរកសៀវភៅពុម្ពភាសាខ្មែរ ។ ខ្ញុំភ្លេចដាក់វាចូលក្នុងកាតាប ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបាន ត្រឹមត្រូវ ។

កាតាប ភាសា បង្រៀន សៀវភៅ ភ្លេច លើ ក្នុង

១. ថ្ងៃនេះអ្នកគ្រូ............មេរៀន........................ខ្មែរ ។

២. ធីតាបើក..................រក....................មិនឃើញសោះ ។

៣. ខ្ញុំទុកវា .......ទូនៅផ្ទះឯនោះ ! ខ្ញុំ ......ដាក់វាចូល .......កាតាប ។

គ. ចូរមើលរូប រួចបំពេញសំណួរខាងក្រោម ។







១. តើ ... នៅឯណា? ២. តើ ... នៅឯណា ? ៣. តើ .... កំពុងរៀននៅឯណា ?

មេរៀនទី ៤១

# ម្ដាយឪពុកខ្ញុំ

## មេសូត្រ



(បទកាកគតិ)

ខ្ញុំគោរពម៉ែ
ធ្វើការគ្មានល្ហែ
ថែទាំគ្រួសារ
ដេរប៉ះបោកគក់
ចម្អិនអាហារ
មើលសព្វកិច្ចការ
ក្នុងគេហដ្ឋាន ។

ខ្ញុំគោរពពុក
ទទួលបន្ទុក
គ្រួសារសុខសាន្ត
ធ្វើស្រែចម្ការ
ពុំគិតនឿយប្រាណ
រកប្រាក់កាសបាន
ចិញ្ចឹមកូនចៅ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

គោរព អានថា គោ-រប់

ចម្អិន អានថា ចំ-អិន

សព្វ អានថា សប់

កិច្ចការ អានថា កិច-កា

គេហដ្ឋាន អានថា គេ-ហាត់-ថាន

ខ. ពន្យល់ពាក្យ

បន្ទុក : ភារៈ ឬកិច្ចការធុរៈសព្វបែបយ៉ាងដែលទទួល ។

កិច្ចការ : ការដែលត្រូវធ្វើ ការរវល់ ។

សព្វ : គ្រប់ គ្រប់យ៉ាង ទាំងអស់ ទាំងស្រុង ទាំងមូល ។

គ. ពាក្យន័យដូចនឹងពាក្យ "ប្រាណ"

ប្រាណ ខ្លួន កាយ ព្រះកាយ

ឃ. ពាក្យផ្ទុយ

នឿយ ≠ ស្រណុក

សុខសាន្ត ≠ ទុក្ខព្រួយ

## សំណួរ

១. តើអ្នកណាដេរប៉ះបោកគក់និងចម្អិនអាហារ ?

២. តើអ្នកណាជាអ្នកធ្វើស្រែចម្ការនិងរកប្រាស់កាស ?

៣. តើប្អូនគោរពឪពុកម្ដាយប្អូនឬទេ ? ព្រោះអ្វី ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| គោរព | គ្រួសារ | ចម្អិន | អាហារ | សព្វ | កិច្ចការ |
| គេហដ្ឋាន | បន្ទុក | សុខសាន្ត | ចម្ការ | ចិញ្ចឹម | |

ខ. ចូរប្រាប់ពាក្យចួនក្នុងមេសូត្រ ។

១. ពាក្យ "ម៉ែ" ចួននឹងពាក្យ........................

២. ពាក្យ "អាហារ" ចួននឹងពាក្យ..........................

៣. ពាក្យ "ពុក" ចួននឹងពាក្យ................................

៤. ពាក្យ "ប្រាណ" ចួននឹងពាក្យ............................

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យនិងល្បះខាងក្រោម ។

> អាហារ កិច្ចការ គេហដ្ឋាន សុខសាន្ត ចម្ការ
>
> យើងត្រូវគោរពឪពុកម្ដាយ ព្រោះគាត់ជាអ្នកមានគុណ ។

ខ. ចូរសរសេររៀបរាប់ពីមនុស្សក្នុងគ្រួសាររបស់ប្អូនឱ្យបានត្រឹមត្រូវ ។

មនុស្សក្នុងគ្រួសាររបស់ខ្ញុំមាន ...............នាក់ គឺឪពុក .................

...................................................................... ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "អាហារ" ។

# មេរៀនទី ៤២ ពេលភ្ញៀវមកលេងផ្ទះ

## អំណាន



ថ្ងៃមួយ មានភ្ញៀវមកលេងផ្ទះម៉ានី ។

ក្រោយពីរាក់ទាក់ជាមួយភ្ញៀវរួច ម្ដាយម៉ានីក៏ហៅ ៖ "អឺកូន! លោកពូឯងអញ្ជើញមកលេង" ។ ម៉ានីស្ទុះស្ទាចេញពីក្នុងផ្ទះមកដោយត្រេកអរ ។ ម៉ានី ៖ "ជម្រាបសួរលោកពូ! ខ្ញុំនឹកលោកពូណាស់! តើលោកពូសុខសប្បាយឬទេ ? "

ពូរបស់ម៉ានីញញឹមហើយតបវិញ ៖"ក្មួយពូចេះណាស់ ! ពូក៏នឹកក្មួយណាស់ដែរ ។ ពូសុខសប្បាយជាធម្មតាទេ ។ នេះជារបស់ដែលពូយកមកផ្ញើក្មួយ!" ។ ម៉ានីសំពះទទួលដោយដៃពីរ រួចឆ្លើយថា អរគុណ ។ ពេលភ្ញៀវកំពុងនិយាយគ្នាជាមួយម្ដាយ ម៉ានីបានទៅចាក់ទឹកដាក់កែវកាន់ដើរមកជិត រួចជូនទឹកទៅភ្ញៀវដោយដៃទាំងពីរ ព្រមទាំងពោលតិចៗ ៖ "អញ្ជើញពិសាទឹកលោកពូ" ។ ពូរបស់ម៉ានីទទួលយកទឹករួចតប ៖ "អរគុណក្មួយ!" ។

មុនពេលត្រឡប់ទៅវិញ ពូរបស់ម៉ានីសរសើរម៉ានីថា ជាក្មេងល្អ ចេះគួរសម ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ជម្រាប    អានថា    ជំ-រាប

ខ. ពន្យល់ពាក្យ

ភ្ញៀវ : អ្នកដទៃដែលមកលេង មករក មកសួរនាំ ។

អញ្ជើញ : ជូនដំណឹង ឬហៅរកដោយគោរព ។

គួរសម : ការសម្ដែងឬកពាសុភាពរៀបរយ ត្រូវបែបបទ ។

ស្ទុះស្ទា : ការប្រញាប់ ។

គ. ពាក្យន័យដូចនឹងពាក្យ "ដៃ"

ដៃ ហត្ថា ព្រះហស្ត

ឃ. ពាក្យផ្ទុយ

ញញឹម ≠ ក្រៀមក្រំ    សរសើរ ≠ បង្អាប់

## សំណួរ

១. តើអ្នកណាមកលេងផ្ទះម៉ានី ?

២. តើម៉ានីធ្វើដូចម្ដេចខ្លះ ពេលជួបលោកពូដំបូង ?

៣. តើម៉ានីធ្វើដូចម្ដេចខ្លះ ពេលភ្ញៀវកំពុងនិយាយគ្នា ?

៤. តើអ្នកត្រូវធ្វើដូចម្ដេច ពេលមានភ្ញៀវមកលេងផ្ទះ ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| ភ្ញៀវ | ឯង | អញ្ជើញ | ស្ទុះស្ទា | ត្រេកអរ |
| ជម្រាបសួរ | សុខសប្បាយ | ក្មួយ | ពិសា | គួរសម |

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ កន្សោមពាក្យ និងល្បះខាងក្រោម ។

> ភ្ញៀវ អញ្ជើញ ស្ទុះស្ទា ជម្រាបសួរ ត្រេកអរ
> មុនពេលត្រឡប់ទៅវិញ ពូរបស់ម៉ានីសរសើរម៉ានីថា ជាក្មេងល្អ ចេះគួរសម ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | |
|---|---|---|---|
| ត្រឡប់ | អរគុណ | គួរសម | អញ្ជើញ |
| ជម្រាប | សប្បាយ | សំពះ | ជាមួយ |

១. ក្រោយពីរាក់ទាក់.......ភ្ញៀវរួច ម្ដាយម៉ានីក៏ហៅ "អឺកូន! លោកពូឯង ...........មកលេង" ។

២. ម៉ានី ៖ "...........សួរលោកពូ! ខ្ញុំនឹកលោកពូណាស់! តើលោកពូសុខ .............ឬទេ" ?

៣. ម៉ានី .............ទទួលដោយដៃពីរ រួចឆ្លើយថា ............. !

៤. មុនពេល ...ទៅវិញ ពូរបស់ម៉ានីសរសើរម៉ានីថា ជាក្មេងល្អ ចេះ ... ។

គ. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. កុមារល្អត្រូវចេះ .............ចាស់ទុំ ។

២. មុនពេលចេញទៅសាលារៀន កូនត្រូវ .........ឪពុកម្ដាយ ។

៣. ពេលទទួលអំណោយ រួចកុំភ្លេចនិយាយថា ............... !

# មេរៀនទី ៤៣ ការប្រើពាក្យ របស់ខ្ញុំ របស់ឯង របស់យើង

## ការនិយាយ





សំ : នេះជាសៀវភៅអ្វី ?

ស្រីម៉ៅ : នេះជាសៀវភៅភាសាខ្មែរថ្នាក់ទី ២ ។

សំ : តើវាជារបស់ឯងមែនឬទេ ?

ស្រីម៉ៅ : ចាស ! វាជារបស់ខ្ញុំ ។ តើខ្មៅដៃពណ៌មួយប្រអប់នេះជារបស់យើងមែនឬទេ ?

សំ : បាទ ! វាជារបស់យើង ។ អ្នកគ្រូឱ្យយើងប្រើជាមួយគ្នា ។

## សំណួរ

១. តើពាក្យ "របស់ខ្ញុំ" ប្រើចំពោះនរណា ?

២. តើពាក្យ "របស់ឯង" ប្រើចំពោះនរណា ?

៣. តើពាក្យ "របស់យើង" ប្រើចំពោះនរណា ?

## ចំណាំ

ពាក្យ "របស់ខ្ញុំ របស់ឯង របស់យើង របស់វា របស់គេ" សម្រាប់សម្គាល់ម្ចាស់វត្ថុ សត្វ រុក្ខជាតិដែលគេមាន ។

## លំហាត់

ចូរសង្កេតរូបភាព រួចជ្រើសរើសពាក្យក្នុងប្រអប់មកនិយាយបំពេញចន្លោះ ខាងក្រោមរូបភាពឱ្យបានត្រឹមត្រូវ ។

| | | | |
|---|---|---|---|
| របស់ខ្ញុំ | របស់ឯង | របស់យើង | របស់វា |



នេះជា .................. ។



នេះជា .................. ។



នេះជា .................. ។



នេះជា .................. ។

## សំណេរ

ក. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | |
|---|---|---|---|
| របស់វា | របស់យើង | របស់ខ្ញុំ | របស់ឯង |

១. តើឯងយកសៀវភៅ ..................ទៅទុកនៅឯណា ? ខ្ញុំរកវាពុំឃើញទេ ។

២. សុខា ! តើបន្ទាត់ .........................ជ្រុះបាត់ពីកាលណា ?

៣. នេះជាថ្នាក់រៀន ............................ទាំងអស់គ្នា ។

៤. កុមារីនេះស្រឡាញ់សៀវភៅ ..................ណាស់ ។

ខ. ចូររៀបពាក្យ កន្សោមពាក្យក្នុងប្រអប់ខាងក្រោមឱ្យទៅជាល្បះត្រឹមត្រូវរួចចម្លងឱ្យបានស្អាត ។

| | | | | |
|---|---|---|---|---|
| ១. | មួយប្រអប់ | នេះជា | របស់យើង ។ | ខ្មៅដៃពណ៌ |

| | | | | | |
|---|---|---|---|---|---|
| ២. | ភាសាខ្មែរ | របស់ខ្ញុំ ។ | នេះជា | ថ្នាក់ទី ២ | សៀវភៅ |

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "យើង" ។

# មេរៀនទី ៤៤ រឿងឪពុកនិងកូនដឹកលាទៅលក់

## អំណាន



កាលយូរលង់ណាស់មកហើយ មានបុរសម្នាក់និងកូនដឹកលាទៅលក់ឯផ្សារ។ ទៅដល់ភូមិមួយឮគេថា មានលាមិនជិះបែរជាដឹកទៅវិញ។ ឪពុកក៏ឱ្យកូនជិះ ហើយគាត់ជាអ្នកដើរ។ ទៅបានបន្តិចក៏ឮគេថា ខ្លួនចាស់ហើយមិនជិះបែរជាឱ្យកូនជិះទៅវិញ។ ឪពុកក៏ឡើងជិះលា ហើយឱ្យកូនដើរវិញ។ ដើរបានបន្តិចក៏ឮតាចាស់ម្នាក់និយាយថា កូននៅក្មេងមិនឱ្យជិះ បែរជាខ្លួនចាស់ជិះលាទៅវិញ។ ឪពុកនិងកូនក៏ឡើងជិះលាទាំងពីរនាក់។ អ្នកស្រុកឃើញក៏ថា លាមួយជិះគ្នាពីរនាក់ ធ្វើឱ្យលាដើរមិនចង់រួច។ ទាំងពីរនាក់ក៏នាំគ្នាសែងលាវិញម្តង។ លុះសែងដល់ស្ពានមួយ ទម្ងន់ក៏សង្កត់ខាងកូន។ កូនទ្រាំមិនបានក៏ទម្លាក់ស្នែងចោល លាក៏ធ្លាក់រមៀលចុះក្នុងទឹកបាត់ទៅ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ទម្ងន់ អានថា ទំ-ងន់

ទម្លាក់ អានថា ទំ-លាក់

សង្កត់ អានថា សង់-កត់

ខ. ពន្យល់ពាក្យ

ស្នែង : ប្រដាប់សម្រាប់សែង ដងស្នែង គ្រឿងសែង ។

ទ្រាំ : ខំអត់ អត់ធ្មត់ ។

ដឹក : នាំបណ្ដើរដោយកាន់ខ្សែ ។

គ. ពាក្យន័យដូចនឹងពាក្យ "បុរស"

បុរស ប្រុស

ឃ. ពាក្យផ្ទុយ

ចាស់ ≠ ក្មេង បាត់ ≠ ឃើញ

## សំណួរ

១. តើឪពុក និងកូនដឹកលាទៅណា ?

២. តើឪពុក និងកូនធ្វើដូចម្ដេច ពេលឮអ្នកស្រុកនិយាយ ?

៣. តើឪពុក និងកូនធ្វើដូចម្ដេច ពេលឮតាចាស់និយាយ ?

៤. ហេតុអ្វីបានជាឪពុក និងកូននាំគ្នាសែងលា ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| ឪពុក | បុរស | បន្តិច | ជិះ | បែរ | ដើរ |
| ស្អែង | ស្ពាន | ទម្លាក់ | ទម្ងន់ | ទ្រាំ | រមៀល |

ខ. ចូររៀបល្បះខាងក្រោមឱ្យត្រូវតាមលំដាប់លំដោយសាច់រឿង ។

១. ទៅបានបន្តិចក៏ឮគេថា ខ្លួនចាស់ហើយមិនជិះ បែរជាឱ្យកូនជិះទៅវិញ ។

២. ទៅដល់ភូមិមួយឮគេថា មានលាមិនជិះបែរជាដឹកដើរទៅវិញ ។

៣. កាលយូរលង់មកហើយ មានបុរសម្នាក់និងកូនដឹកលាទៅលក់ឯផ្សារ ។

៤. កូនទ្រាំមិនបានក៏ទម្លាក់ស្អែងចោល ។

៥. ឪពុក និងកូនក៏ឡើងជិះលាទាំងពីរនាក់ ។

៦. ទាំងពីរនាក់ក៏នាំគ្នាសែងលាវិញម្តង ។

# សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យនិងល្បះខាងក្រោម ។

> បុរស ស្អែង ជិះ ទម្ងន់ ទម្លាក់
>
> កាលយូរលង់ណាស់មកហើយ មានបុរសម្នាក់និងកូនដឹកលាទៅលក់ឯផ្សារ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| ដឹក | បន្តិច | ទម្ងន់ | គាត់ | ពីរ | រួច | មកហើយ | ជិះ |
|---|---|---|---|---|---|---|---|

១. កាលយូរលង់ណាស់ .........មានបុរសម្នាក់និងកូន .........លាទៅលក់ឯផ្សារ ។

២. ឪពុកក៏ឱ្យកូនជិះ ហើយ ............ជាអ្នកដើរ ។

៣. ទៅបាន .........ក៏ឮគេថា ខ្លួនចាស់ហើយមិនជិះបែរជាឱ្យកូន ........ទៅវិញ ។

៤. អ្នកស្រុកឃើញក៏ថា លាមួយជិះគ្នា ...នាក់ ធ្វើឱ្យលាដើរមិនចង់ ... ។

៥. លុះសែងដល់ស្ពានមួយ ............ក៏សង្កត់ខាងកូន ។

គ. ចូររកពាក្យមកបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. ម្ដាយខ្ញុំ ..........ត្រីនៅឯផ្សារ ។

២. កុមារនាំគ្នា ...........សៀវភៅក្នុងបណ្ណាល័យ ។

៣. តើ ..............នៅឯណា ?

៤. គាត់ជិះ ..............ទៅសាលារៀន ។

# មេរៀនទី ៤៥ មិត្តល្អរបស់កូនឆ្មាបូបូ

## អំណាន




ថ្ងៃនេះ ជាថ្ងៃចូលរៀនដំបូង។ ពេលទៅជិតដល់សាលារៀន កូនទន្សាយតូនីឃើញបូបូកំពុងឈរយំ។ តូនីក៏រត់មកសួរ ៖ "ហេតុអ្វីបានជាមិត្តយំ ?" បូបូឆ្លើយ ៖ "ខ្មៅដៃរបស់ខ្ញុំជ្រុះបាត់ហើយ! ខ្ញុំមិនហ៊ានចូលរៀនទេ ព្រោះគ្មានអ្វីសរសេរ"។

តូនីនិយាយ ៖"ឈប់យំទៅ! ខ្ញុំមានខ្មៅដៃពីរដើម ខ្ញុំនឹងឱ្យមិត្តមួយ។ លើកក្រោយឯងត្រូវដាក់សៀវភៅ ខ្មៅដៃ បន្ទាត់ ក្នុងកាតាប ឬថង់ឱ្យបានល្អ ទើបវាមិនជ្រុះ"។ បូបូឆ្លើយ ៖ "អរគុណ តែខ្ញុំគ្មានកាតាបទេ"។ តូនីនិយាយ ៖ "ខ្ញុំមានកាតាបមួយទៀត! ស្អែកខ្ញុំនឹងយកមកឱ្យឯង"។

បូបូញញឹមហើយនិយាយ ៖ "អរគុណតូនី! មិត្តមានចិត្តល្អណាស់!"។

## ការរៀនពាក្យ

ក. អំណានពាក្យ

ទន្សាយ អានថា ទន់-សាយ

ខ. ពន្យល់ពាក្យ

ស្អែក : ថ្ងៃបន្ទាប់ពីថ្ងៃនេះ ។

គ. ពាក្យន័យដូចនឹងពាក្យ "មិត្ត"

មិត្ត សម្លាញ់ ពួកម៉ាក ភ្លើ

ឃ. ពាក្យផ្ទុយ

បាត់ ≠ គង់ ឃើញ     ដំបូង ≠ ចុងក្រោយ

## សំណួរ

១. ហេតុអ្វីបានជាបូបូយំ ?

២. តើនរណាជាអ្នកឱ្យខ្មៅដៃទៅបូបូ ? តើគេសន្យាឱ្យអ្វីទៀត ?

៣. តើបូបូនិយាយដូចម្តេចនៅពេលទទួលបានខ្មៅដៃ ?

៤. តើពាក្យ "របស់ខ្ញុំ" ប្រើចំពោះនរណា ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំ និងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| មិត្ត | ចិត្ត | ដំបូង | ទន្សាយ | ខ្មៅដៃ | ហ៊ាន |
| ញញឹម | សៀវភៅ | អរគុណ | ល្អ | | |

# សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យក្នុងប្រអប់ខាងក្រោម ។

កន្លែង    សរសេរ    ខ្មៅដៃ    សួរ    ដំណើរ

បូបូញញឹមហើយនិយាយ ៖ “អរគុណតូនី! មិត្តមានចិត្តល្អណាស់!”។

ខ. ចូរបំពេញពាក្យក្នុងចន្លោះល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

ថ្ងៃនេះជាថ្ងៃចូលរៀនដំបូង ។ បូបូ ....សាលារៀន ។ លុះទៅដល់ជិតរបងសាលារៀនស្រាប់តែបូបូឈរយំ ។ កូនទន្សាយតូនីឃើញបូបូយំ ក៏រត់មកសួរ ៖ “ហេតុអ្វីបានជាមិត្ត ...... ?” បូបូឆ្លើយ ៖ “ខ្មៅដៃរបស់ខ្ញុំជ្រុះបាត់ហើយ”។ ខ្ញុំគ្មានអ្វី ....ទេ ។ តូនីនិយាយ ៖ “ឈប់យំទៅ ខ្ញុំមាន ..............ពីរដើម ខ្ញុំឱ្យមិត្តមួយដើម”។ បូបូញញឹមហើយ និយាយ ៖ “ខ្ញុំ ..........មិត្ត! មិត្តមាន ..........ល្អណាស់!”។

គ. ចូរតែងល្បះតាមន័យរបស់រូបភាពខាងក្រោមឱ្យបានសមស្រប ។




................ ។    ................ ។    ................ ។

# មេរៀនទី ៤៦ ការរៀនអក្សរផ្ចង់

## អំណាន




ពេលរៀនសរសេរអក្សរ យើងខំប្រឹងផ្ចិតផ្ចង់សរសេរឱ្យបានត្រឹមត្រូវល្អ ។ ដំបូងអ្នកគ្រូបានប្រាប់ពីរបៀបដាក់សៀវភៅលើតុ របៀបកាន់ខ្មៅដៃ និងរបៀបសរសេរ ។ យើងគូសបន្ទាត់តាមគាត់ក្នុងសៀវភៅសរសេររបស់យើង ។ យើងចាប់គូសតាមរាងអក្សរ ដោយយឺតៗតាមក្បូនខ្នាត ។ អ្នកគ្រូដើរជួយកែលម្អសំណេររបស់យើង ។ អ្នកគ្រូបានលើកកិច្ចការអក្សរផ្ចង់របស់សិស្ស ដែលសរសេរបានត្រឹមត្រូវល្អបង្ហាញសិស្សដទៃទៀតឱ្យយកគំរូតាម ។

យើងទាំងអស់គ្នាសប្បាយចិត្តនឹងសរសេរអក្សរបានស្មើស្អាតនិងត្រឹមត្រូវ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

បង្ហាញ អានថា បង់-ហាញ

ខ. ពន្យល់ពាក្យ

ផ្ចិតផ្ចង់ : យកចិត្តទុកដាក់ ប្រិតប្រៀន ។

ក្បួនខ្នាត : ការកំណត់ជាគោលសម្រាប់ធ្វើតាម ។

បង្ហាញ : ធ្វើឱ្យឃើញ ។

គ. ពាក្យផ្ទុយ

ផ្ចិតផ្ចង់ ≠ ខ្ជីខ្ជា

សប្បាយ ≠ ទុក្ខ

## សំណួរ

១. តើពេលរៀនអក្សរផ្ចង់ ដំបូងអ្នកគ្រូបានប្រាប់ពីអ្វីខ្លះ ?

២. បន្ទាប់ពីអ្នកគ្រូណែនាំរួចហើយ តើយើងត្រូវធ្វើដូចម្តេចខ្លះ ?

៣. ពេលកែលម្អសំណេរយើងហើយ តើអ្នកគ្រូធ្វើដូចម្តេចទៀត ?

៤. ហេតុអ្វីបានជាប្អូនចូលចិត្តរៀនសរសេរអក្សរផ្ចង់ ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទៀងនិងប្រកបឱ្យបានត្រឹមត្រូវ ។

អក្សរផ្ចង់ ផ្ចិតផ្ចង់ គូសបន្ទាត់ ក្បួនខ្នាត បង្ហាញ គំរូ សប្បាយ ស្មើ ស្អាត

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម ។

| | | | | |
|---|---|---|---|---|
| ស្មើ | បន្ទាត់ | កិច្ចការ | បង្ហាញ | សប្បាយ |

ពេលរៀនសរសេរអក្សរ យើងខំប្រឹងផ្ចិតផ្ចង់សរសេរឱ្យបានត្រឹមត្រូវ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបាន ត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| ប្រាប់ | ខ្មៅដៃ | ផ្ចិតផ្ចង់ | សៀវភៅ | សរសេរ |
| ត្រឹមត្រូវ | បន្ទាត់ | ក្នុង | សប្បាយ | |

១. ពេលរៀនអក្សរផ្ចង់ យើងខំប្រឹង ......សរសេរឱ្យបាន ......ល្អ ។

២. ដំបូងអ្នកគ្រូបាន ..........ពីរបៀបដាក់ ........លើតុ របៀបកាន់ .......និងរបៀប ........ ។

៣. យើងគូស .........តាមគាត់ .........សៀវភៅយើង ។

៤. យើងទាំងអស់គ្នា .............ចិត្តនឹងសរសេរ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "សរសេរ" ។

# មេរៀនទី ៤៧ ការរៀបរាប់សមាជិកក្នុងគ្រួសារ

## ការនិយាយ

ចូរអានសម្ដីរបស់ស្រីម៉ៅ ។ តើស្រីម៉ៅនិយាយពីនរណាខ្លះ ?



ខ្ញុំឈ្មោះស្រីម៉ៅ ។
ខ្ញុំរៀននៅថ្នាក់ទី ២ ។



ម្ដាយខ្ញុំឈ្មោះណារី ។
គាត់ជាអ្នកតម្បាញ ។



ឪពុកខ្ញុំឈ្មោះសុខខេង ។
គាត់ជា គ្រូបង្រៀន ។



គ្រួសារខ្ញុំមានមនុស្សប្រាំមួយនាក់ គឺជីដូន ជីតា ម្ដាយ ឪពុក ខ្ញុំ និងប្អូនប្រុសខ្ញុំ ។

### សំណួរ

១. តើឪពុកស្រីម៉ៅឈ្មោះអ្វី ?

២. តើគាត់ធ្វើការអ្វី ?

៣. តើម្ដាយស្រីម៉ៅឈ្មោះអ្វី ?

៤. តើគាត់ធ្វើការអ្វី ?

## សំណេរ

ក. ចូរមើលរូបភាព រួចសរសេរបំពេញល្បះខាងក្រោម ។



ម្ដាយខ្ញុំជា ............. ។



ឪពុកខ្ញុំជា ............. ។



បងស្រីខ្ញុំជា ............. ។



បងប្រុសខ្ញុំជា ............. ។

ខ. ចូរសរសេរឈ្មោះ និងមុខរបរសមាជិកក្នុងគ្រួសារអ្នក ឱ្យបានត្រឹមត្រូវ ។

១. គ្រួសារខ្ញុំមានមនុស្សចំនួន ........ នាក់ ។

២. ម្ដាយខ្ញុំឈ្មោះ ................ ។ គាត់ជា ................ ។

៣. ឪពុកខ្ញុំឈ្មោះ ................ ។ គាត់ជា ................ ។

៤. បងប្រុសខ្ញុំឈ្មោះ ............ ។ គាត់ជា ................ ។

៥. ជីតាខ្ញុំឈ្មោះ ................. ។ គាត់ជា ................ ។

៦. ជីដូនខ្ញុំឈ្មោះ ................ ។ គាត់ជា ................ ។

៧. ខ្ញុំឈ្មោះ ...................... ។ ខ្ញុំជា .................. ។

# មេរៀនទី ៤៨ រឿងកញ្ជ្រោងនិងកូនពពែ

## ការស្ដាប់

ចូរស្ដាប់គ្រូរបស់អ្នកនិទានរឿង រួចឆ្លើយនឹងសំណួរ ។



### សំណួរ

១. តើមេពពែនិងកូននៅឯណា ?

២. មុននឹងចេញទៅរកចំណី តើមេពពែផ្ដាំកូនដូចម្ដេចខ្លះ ?

៣. តើនរណាមកគោះទ្វារហៅកូនពពែ ?

៤. តើកូនពពែបើកទ្វារឱ្យឬទេ ? តើរូបភាពណាជាចម្លើយសមស្រប ?



កូនពពែបើកទ្វារឱ្យកញ្ជ្រោង ។



កូនពពែមិនបើកទ្វារឱ្យកញ្ជ្រោងទេ ។

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម ។

> កញ្ជ្រោង ផ្ដែផ្ដាំ សាហាវ ទ្វារ បង្ហាញ
>
> រាល់ថ្ងៃ មុននឹងចេញទៅរកចំណី មេពពែតែងតែផ្ដាំកូនថា នៅពេលដែលម៉ែមិននៅផ្ទះ កូនកុំដើរលេងផ្ដេសផ្ដាសឱ្យសោះ ។

ខ. តើរូបភាពខាងក្រោមបង្ហាញពីអ្វី ? ចូរសរសេរបំពេញល្បះក្រោមរូបភាពឱ្យបានត្រឹមត្រូវ ។



មេពពែនិងកូននៅក្នុង ..... នេះ ។



កូនពពែបិទ ..... ផ្ទះ ។



កញ្ជ្រោង ..... ទ្វារផ្ទះពពែ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "ពពែ" ។

# មេរៀនទី ៤៩ រឿងកូនទន្សាយនិងកូនឆ្មា

## អំណាន



ថ្ងៃអាទិត្យមួយ កូនទន្សាយតូនីបានទៅលេងផ្ទះឆ្មាបូបូ ។ តូនីឃើញបូបូកំពុងគូររូបលេងយ៉ាងសប្បាយជាមួយប្អូនរបស់គេ ។ តូនីក៏រត់សំដៅទៅរកពួកគេទាំងពីរនាក់ ។ បូបូទទួលរាក់ទាក់មិត្តយ៉ាងរីករាយ ។ ពេលនោះតូនីឮសំឡេងស្រែកហៅ ៖ "អើយបូបូ! មកនេះមួយភ្លែត" ។ តូនីសួរបូបូ ៖ "តើនរណាហៅឯង ?" បូបូឆ្លើយ ៖ "គឺម្ដាយខ្ញុំ! គាត់កំពុងដាក់ក្របសៀវភៅឱ្យពួកខ្ញុំ ។ ប្រហែលជាគាត់មានការអ្វីហើយ! ប៉ុន្តែយើងគូររូបបន្តិចទៀតសិន!" ។ តូនីនិយាយ ៖ "មិនល្អទេ! គាត់ប្រាកដជាមានការអ្វីហើយ! អ៊ីចឹង! យើងប្រញាប់ទៅជួបគាត់" ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ប្រាកដ អានថា ប្រា-កត់

សប្បាយ អានថា ស័ប-បាយ ឬ សះបាយ

ខ. ពន្យល់ពាក្យ

ប្រាកដ : ជាក់ច្បាស់មែន ។

សប្បាយ : ដំណើរនៅជាសុខរីករាយ ។

គ. ពាក្យន័យដូចនឹងពាក្យ "និទាន"

និទាន និយាយ រៀបរាប់

ឃ. ពាក្យផ្ទុយ

មិត្ត ≠ សត្រូវ

ល្អ ≠ អាក្រក់

សំណួរ

១. នៅថ្ងៃអាទិត្យ តើតូនីទៅលេងផ្ទះនរណា ?

២. តើបូបូកំពុងធ្វើអ្វី ?

៣. តើម្ដាយរបស់បូបូកំពុងធ្វើអ្វី ?

៤. តើតូនីនិយាយដូចម្ដេចជាមួយបូបូ ?

លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

អាទិត្យ មិត្ត ដើរ គួរ បន្តិច កំពុង ប្រញាប់ ដំណើរ ប្រាកដ

ខ. តើតូនីជាកូនទន្សាយដូចម្ដេច ? ចូរជ្រើសរើសចម្លើយសមស្រប ។

១. តូនីជាកូនទន្សាយខ្ជិល ។

២. តូនីជាកូនទន្សាយល្អ ។

៣. តូនីជាកូនទន្សាយខិលខូច ។

គ. តើឃ្លីមសារនិងរូបភាពណាត្រូវគ្នា ?







តូនីនិងបូបូកំពុងអានសៀវភៅ ។ តូនីនិងបូបូច្រៀងលេង ។ ពួកគេលេងលោតអន្ទាក់ ។

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម ។

អាទិត្យ ទន្សាយ សប្បាយ មិត្ត ជីតា ប្រាកដ បន្តិច
គាត់ប្រាកដជាមានការអ្វីហើយ ! អីចឹងយើងប្រញាប់ទៅជួបគាត់ !

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោមរូបភាព ។

កាត់ | បោស | ដាំ | បេះ



១. ជីតាខ្ញុំកំពុង ..... ស្មៅ ។ ម្តាយខ្ញុំ ............. ផ្លែបេងប៉ោះ ។

២. ឪពុកខ្ញុំកំពុង .......... កូនឈើ ។ ជីដូនខ្ញុំ .......... សំរាម ។

មេរៀនទី
៥០

# គ្រួសាររីករាយ

## ចម្រៀង



(លំនាំបទឱស្វាយចន្ទី)

| | | |
|---|---|---|
| ឱស្វាយចន្ទី | កូនចៅសាមគ្គី | ជួបជុំរីករាយ |
| ពុកម៉ែតាយាយ | លោកមិនរាយមាយ | ចិញ្ចឹមមើលថែ ។(ពីរដង) |
| ពុកម៉ែធ្វើការ | កូនទៅសាលា | សិក្សាពូកែ |
| មកផ្ទះជួយថែ | មិនឱ្យពុកម៉ែ | ពិបាកទូន្មាន ។(ពីរដង) |
| ទំនេរការងារ | ព្រលប់ជុំគ្នា | ស្តាប់តានិទាន |
| យាយប្រដៅប្រៀន | ចៅៗខំរៀន | គ្រួសាររីករាយ ។(ពីរដង) |

## ការរៀនពាក្យ

ក. អំណានពាក្យ

សាមគ្គី អានថា សាម-ម៉ុក-គី

ទូន្មាន អានថា ទូន-មាន

ខ. ពន្យល់ពាក្យ

សាមគ្គី : សេចក្ដីព្រមព្រៀង ដំណើរស្រុះគ្នា ។

ទូន្មាន : ប្រៀនប្រដៅ អប់រំណែនាំ ។

រាយមាយ : ចាប់នេះចាប់នោះ មិនឆ្ពោះត្រង់ណា ។

គ. ពាក្យន័យដូចនឹងពាក្យ "សិក្សា"

សិក្សា រៀនសូត្រ រៀន

ឃ. ពាក្យផ្ទុយ

ទំនេរ ≠ រវល់ ពូកែ ≠ ខ្សោយ

## សំណួរ

១. តើនរណាខ្លះជាអ្នកចិញ្ចឹមគ្រួសារ ?

២. តើនរណាជាអ្នកនិទានរឿង ?

៣. តើយាយប្រដៅចៅៗឱ្យធ្វើអ្វី ?

## លំហាត់

ក. ចូរប្រាប់ពាក្យចួនក្នុងចម្រៀង ។

១. តើពាក្យ "ចន្ទ្រ" ចួននឹងពាក្យអ្វី ?

២. តើពាក្យ "រីករាយ" ចួននឹងពាក្យអ្វី ?

៣. តើពាក្យ "ធ្វើការ" ចួននឹងពាក្យអ្វី ?

ខ. ចូរអានទំនុកច្រៀងខាងលើឡើងវិញ រួចច្រៀងតាមគ្រូ ។

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យវគ្គចម្រៀងខាងក្រោម ។

| | | |
|---|---|---|
| ឱស្វាយចន្ទី | កូនចៅសាមគ្គី | ជួបជុំរីករាយ |
| ពុកម៉ែតាយាយ | លោកមិនរាយមាយ | ចិញ្ចឹមមើលថែ ។ |

ខ. ចូរជ្រើសរើសពាក្យចូនក្នុងប្រអប់ ទៅបំពេញបទចម្រៀងខាងក្រោម ។

| យាយ | សាលា | ម៉ែ | គ្នា | ប្រៀន |
|---|---|---|---|---|

| | | |
|---|---|---|
| ឱស្វាយចន្ទី | កូនចៅសាមគ្គី | ជួបជុំរីករាយ |
| ពុកម៉ែតា ....... | លោកមិនរាយមាយ | ចិញ្ចឹមមើលថែ ។ (ពីរដង) |
| ពុកម៉ែធ្វើការ | កូនទៅ...... | សិក្សាពូកែ |
| មកផ្ទះជួយថែ | មិនឱ្យពុក... | ពិបាកទូន្មាន ។ (ពីរដង) |
| ទំនេរការងារ | ព្រលប់ជុំ.... | ស្តាប់តានិទាន |
| យាយប្រដៅ..... | ចៅៗខំរៀន | គ្រួសាររីករាយ ។(ពីរដង) |

គ. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. កូនចៅត្រូវស្តាប់ ............ចាស់ទុំ ។

២. សុខកំពុងធ្វើ .............ផ្ទះដែលគ្រូដាក់ឱ្យ ។

៣. ជីតាខ្ញុំតែង ..............រឿងឱ្យខ្ញុំស្តាប់រៀងរាល់យប់ ។

រយៈពេល ០៨ ម៉ោងសិក្សា

មេរៀនទី
៥១

# ចម្ការរបស់ជីតាខ្ញុំ

## អំណាន



ជីតាខ្ញុំមានចម្ការមួយនៅក្រោយផ្ទះ ។

គាត់ដាំដំណាំហូបផ្លែនិងបន្លែគ្រប់មុខដូចជាឪឡឹក ត្រសក់ ល្ពៅ ជីរ ស្លឹកគ្រៃជាដើម ។ ពេលទំនេរ ខ្ញុំជួយដកស្មៅ ពូនគល់ និងស្រោចទឹកដំណាំ ។ ជីដូនខ្ញុំសប្បាយចិត្តណាស់ ព្រោះឃើញខ្ញុំចូលចិត្តធ្វើការងារ ។ គាត់មានប្រសាសន៍ថា ខ្ញុំឧស្សាហ៍ដូចជីតាខ្ញុំដែរ ។

ខ្ញុំពេញចិត្តនឹងចម្ការជីតាខ្ញុំណាស់ ព្រោះវាផ្តល់ផលប្រយោជន៍ដល់គ្រួសារខ្ញុំហូបចុកបានគ្រប់គ្រាន់ ។

### ការរៀនពាក្យ

ក. អំណានពាក្យ

ឧស្សាហ៍ អានថា អ៊ុស-សា

ប្រសាសន៍ អានថា ប្រ-សាស

ខ. ពន្យល់ពាក្យ

ឧស្សាហ៍ : ការខំប្រឹងមិនខ្ជិល ។

ប្រសាសន៍ : ពាក្យបង្គាប់ ពាក្យផ្ដាំផ្ញើ ។

គ. ពាក្យន័យដូចនឹងពាក្យ “ប្រសាសន៍”

ប្រសាសន៍ សម្ដី ភាសា និយាយ សង្ឃដីកា ពុទ្ធដីកា

ឃ. ពាក្យផ្ទុយ

ឧស្សាហ៍ ≠ ខ្ជិល

## សំណួរ

១. តើចម្ការជីតារបស់គេស្ថិតនៅឯណា ?

២. តើចម្ការនេះមានដំណាំអ្វីខ្លះ ?

៣. តើពេលទំនេរ គេជួយធ្វើអ្វីខ្លះ ?

៤. តើជីដូនរបស់គេសរសើរគេដូចម្ដេច ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទាំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ជីវ ផលប្រយោជន៍ ចម្ការ ទំនេរ ឪឡឹក ស្លឹកគ្រៃ ឧស្សាហ៍ ប្រសាសន៍

ខ. ចូរតម្រូវល្បះជាមួយនឹងរូបភាពខាងក្រោម ដោយចុះលេខល្បះនៅក្នុងប្រអប់រូបឱ្យបានត្រឹមត្រូវ ។

១. បងស្រីខ្ញុំជាគ្រូពេទ្យ ។

២. ម្ដាយខ្ញុំជាគ្រូបង្រៀន ។

៣. ជីតាខ្ញុំតែងនិទានរឿងឱ្យខ្ញុំស្តាប់ ។

៤. សែយ៉ាធ្វើលំហាត់នៅផ្ទះ ។

៥. ជីដូនយោលអង្រឹងចៅ ។

៦. ម៉ុកបោសសំរាម ។



## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យនិងល្បះខាងក្រោម ។

ចម្ការ ផ្ទះ ប្រសាសន៍ ទំនេរ ឪឡឹក

ខ្ញុំពេញចិត្តនឹងចម្ការជីតាខ្ញុំណាស់ ព្រោះវាផ្តល់ប្រយោជន៍ដល់គ្រួសារខ្ញុំ ។

ខ. ចូរបំពេញល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ ។







ឪពុកខ្ញុំកំពុង ..... ។ ម្ដាយខ្ញុំជា ..... ។ បងស្រីខ្ញុំជា ..... ។

គ. ចូរមើលរូបភាពខាងក្រោម រួចតែងល្បះអំពីរូបភាពនោះឱ្យបានសមស្រប ។







........................ ។ ........................ ។ ........................ ។







........................ ។ ........................ ។ ........................ ។

មេរៀនទី
៥២

# មេមាន់និងកូន

## អំណាន



មានមេមាន់មួយ បណ្ដើរកូនរកចំណីនៅក្រោយផ្ទះ ។

ពេលមកដល់គុម្ពោតព្រៃមួយ កូនមាន់បានដើរឃ្លាតឆ្ងាយពីមេវា ។ ពេលនោះ មេមាន់ភ័យណាស់ ព្រោះខ្លាចកូនមានគ្រោះថ្នាក់ ។ វារត់ឆ្វេឆ្វា ស្រែកហៅកូនៗឱ្យមកជិត ។ ក្រោយពេលកូនមកជុំគ្នា មេមាន់បានត្រដាងស្លាបគ្របកូនទាំងអស់ ។ មេមាន់បាននិយាយប្រដៅកូនកុំឱ្យដើររកចំណីឆ្ងាយពីខ្លួន ខ្លាចជួបនឹងសត្វសាហាវ ។ តាំងពីពេលនោះមក កូនមាន់មិនដែលដើររកចំណីឆ្ងាយពីមេរបស់វាឡើយ ។

ដោយសារការស្ដាប់តាមដំបូន្មានរបស់មេ កូនមាន់ទាំងអស់រស់នៅជាមួយមេវាប្រកបដោយភាពសុខសាន្ត ។

## ការរៀនពាក្យ

ក. អំណានពាក្យ

គុម្ពោត អានថា គុំ-ពោត

ភ័យ អានថា ភៃ

សុខសាន្ត អានថា សុក-សាន

ខ. ពន្យល់ពាក្យ

គ្រោះថ្នាក់ : គ្រោះកាច មានគ្រោះ ។

សុខសាន្ត : សេចក្ដីស្រណុក ដំណើរស្រួល ។

គ. ពាក្យន័យដូចនឹងពាក្យ "សាហាវ"

សាហាវ កាច ឃោរឃៅ

ឃ. ពាក្យផ្ទុយ

ខ្លាច ≠ ហ៊ាន    រស់ ≠ ស្លាប់

## សំណួរ

១. តើមេមាន់បណ្ដើរកូនរកចំណីនៅឯណា ?

២. តើមេមាន់ប្រដៅកូនដូចម្ដេច ?

៣. នៅពេលស្ដាប់តាមដំបូន្មានរបស់មេ តើកូនមាន់រស់នៅដូចម្ដេច ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| បណ្ដើរ | ផ្ទះ | ឃ្លាត | ភ័យ | ឆ្លេឆ្លា |
| សាហាវ | ត្រដាង | គុម្ពោត | ភាពសុខសាន្ត | |

ខ. តើកូនមាន់ទាំងអស់ធ្វើអ្វី នៅពេលឮម្ដាយហៅ ? តើរូបភាពណាដែលមានចំណងជើងត្រឹមត្រូវ ?



កូនមាន់រត់ចេញពីមេ ។



កូនមាន់រត់មករកមេវា ។



កូនមាន់ក្រាបក្នុងស្មៅពួនមេវា ។

គ. តើកូនមាន់ទាំងអស់ជាសត្វដូចម្ដេច ? ចូរជ្រើសរើសចម្លើយសមស្រប ។

១. កូនមាន់ទាំងអស់ជាសត្វដើរច្រើន ។

២. កូនមាន់ទាំងអស់ជាសត្វបំផ្លាញដំណាំ ។

៣. កូនមាន់ទាំងអស់ជាសត្វស្ដាប់ដំបូន្មាន ។

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យអត្ថបទខាងក្រោម ។

### មេមាន់

មេមាន់បាននិយាយប្រដៅកូនកុំឱ្យដើររកចំណីឆ្ងាយពីខ្លួន ខ្លាចជួបនឹងសត្វសាហាវ ។ តាំងពីពេលនោះមក កូនមាន់មិនដែលដើររកចំណីឆ្ងាយពីមេរបស់វាឡើយ ។

ដោយសារការស្ដាប់តាមដំបូន្មានរបស់មេ កូនមាន់ទាំងអស់រស់នៅជាមួយមេវាប្រកបដោយភាពសុខសាន្ត ។

សំណួរ

១. តើមេមាន់ប្រដៅកូនដូចម្ដេច ? ព្រោះអ្វី ?

២. តើកូនមាន់ធ្វើដូចម្ដេច ?

៣. តើកូនមាន់និងមេរស់នៅដូចម្ដេច ?

លំហាត់

១. ចូរពន្យល់ពាក្យ "សុខសាន្ត សាហាវ"។

២. ចូររកពាក្យន័យដូចនឹងពាក្យ "និយាយ"។

៣. ចូររកពាក្យផ្ទុយនឹងពាក្យ " ឃ្លាន "។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបាន ត្រឹមត្រូវ ។

| ភ័យ | សុខសាន្ត | ចំណី | ដើរ |
|---|---|---|---|

១. មេបណ្ដើរកូនរក ..........នៅក្រោយភូមិ ។

២. ពេលកូនទៅឆ្ងាយពីខ្លួនមេមាន់ ..........រត់ស្លេស្លា ។

៣. កូនមាន់មិន ...............រកចំណីឆ្ងាយពីមេវាទេ ។

៤. កូនមាន់រស់នៅប្រកបដោយភាព .............ព្រោះវាស្ដាប់ដំបូន្មាន របស់ម្ដាយ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "មេមាន់"។

# មេរៀនទី ៥៣ ការរៀបរាប់អំពី រូប ក្លិន ពណ៌ សំឡេង រសជាតិ

## ការនិយាយ



បូណា : អូ ! នារី តើឯងឮអ្វីជ្រុះដែរឬទេ ?

នារី : ខ្ញុំឮសូរស្វាយទុំជ្រុះខ្ពោកនៅក្បែររបងនេះ ។

បូណា : មើលនេះន៏ ! សម្បកវាមានពណ៌លឿងទុំ ឯងកាន់វាមើល សាច់វាទន់ល្មើយ ។

នារី : អូ! វាមានក្លិនក្រអូបគួរឱ្យចង់ហិតណាស់ ។

បូណា : ស្វាយទុំដើមអីចឹង មានរសជាតិផ្អែមឆ្ងាញ់ណាស់ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

រសជាតិ អានថា រស់-ជាត

ខ. ពន្យល់ពាក្យ

រសជាតិ : ជាតិរបស់អាហារ ដែលមានជាតិ ផ្អែម ប្រៃ ល្វីង ជូរ ចត់ ជាដើម ។

ក្លិន : ចំហាយដែលភាយចេញពីវត្ថុផ្សេងៗ ក្រអូប ឬស្អុយ ជាដើម ។

គ. ពាក្យន័យដូចនឹងពាក្យ "មើល"

មើល ទស្សនា ទត

ឃ. ពាក្យផ្ទុយ

ស្អុយ ≠ ក្រអូប ទន់ ≠ រឹង ទុំ ≠ ខ្ចី

## សំណួរ

១. តើបូណានិងនារីឮសូរអ្វីជ្រុះ ?

២. តើស្វាយទុំមានក្លិនដូចម្ដេច ?

៣. តើផ្លែស្វាយទុំមានរសជាតិដូចម្ដេច ?

## លំហាត់

ក. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. ផ្លែចាន់ទុំមានក្លិន .....គួរឱ្យចង់ញ៉ាំណាស់ ។

២. សត្វឆ្មាយំឮសូរ .......... ។

៣. ទឹកអំពៅមានរសជាតិ ........ឆ្ងាញ់ណាស់ ។

២. ចូររៀបរាប់អំពី រូបរាង ក្លិន ពណ៌ និងរសជាតិផ្លែក្រូច ល្ហុង និងស្វាយប្រាប់ដៃគូអ្នកឱ្យបានត្រឹមត្រូវ ។

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ កន្សោមពាក្យ និងល្បះខាងក្រោម ។

ខ្ចាក ពណ៌លឿង ក្រអូប លឿងទុំ ហិតក្លិន ផ្អែមឆ្ងាញ់
ស្វាយទុំដើមអ៊ីចឹង មានរសជាតិផ្អែមឆ្ងាញ់ណាស់ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | |
|---|---|---|
| រសជាតិ | ទុំ | ក្រអូប |

១. ស្វាយ .............. មានពណ៌លឿងទុំ ។

២. ស្វាយទុំមានក្លិន .................. ។

៣. ស្វាយទុំមាន ............ ផ្អែមឆ្ងាញ់ ។

គ. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. ក្រូចឆ្មារមានរសជាតិ ................................ ។

២. ការចោលសំរាមផ្តេសផ្តាសនាំឱ្យមានក្លិន ........... ។

៣. ល្ហុងខ្ចីមានពណ៌ ....................................... ។

មេរៀនទី
៩៤

# អាត្នោតគោខ្ញុំ

## អំណាន



ខ្ញុំមានគោឈ្មោលមួយក្បាលឈ្មោះអាត្នោត ។

គោខ្ញុំមានសម្បុរត្នោត ។ វាមានមាឌធំខ្ពស់ ស្នែងស្រួចកោងខុបចូលគ្នា ។ ជើងទាំងបួនរបស់អាត្នោតមាំៗ ។ កន្ទុយរបស់វាវែង ហើយបក់ចុះបក់ឡើង ។ អាត្នោតមានកម្លាំងខ្លាំង ។ វាចេះណាស់ហើយឧស្សាហ៍ទៀត ។ គ្រួសារខ្ញុំទឹមវាដើម្បីភ្ជួររាស់ និងអូសរទេះ ។ ជីតាខ្ញុំតែងច្រូតស្មៅឱ្យវាស៊ី និងលាងទឹកវារៀងរាល់ថ្ងៃ ។ រាល់ព្រឹកខ្ញុំតែងកើបអាចម៍វាយកទៅដាក់ក្នុងរណ្ដៅសម្រាប់ធ្វើជី ។

ខ្ញុំស្រឡាញ់អាត្នោតណាស់ ព្រោះវាមានប្រយោជន៍ចំពោះគ្រួសារខ្ញុំ ។

## ការរៀនពាក្យ

### ក. អំណានពាក្យ

សម្បុរ អានថា សំ-បុល

ប្រយោជន៍ អានថា ប្រ-យ៉ោច

អាចម៍ អានថា អាច់

ខ. ពន្យល់ពាក្យ

សម្បុរ : ពណ៌សម្រាប់ប្រើចំពោះមនុស្ស និងសត្វ ។

ប្រយោជន៍ : ផលដែលសម្រេចអំពីការធ្វើអ្វីមួយ ។

គ. ពាក្យន័យដូចនឹងពាក្យ "ឧស្សាហ៍"

ឧស្សាហ៍ ព្យាយាម ខិតខំ

ឃ. ពាក្យផ្ទុយ

ស្រួច ≠ ទាល ខ្ពស់ ≠ ទាប មាំ ≠ ទន់ជ្រាយ

## សំណួរ

១. តើគោនោះឈ្មោះអ្វី ? ញីឬឈ្មោល ?

២. តើគោនោះមានរូបរាងដូចម្ដេច ?

៣. តើគោនោះជាសត្វដូចម្ដេច ?

៤. តើអ្នកចូលចិត្តចិញ្ចឹមគោដែរឬទេ ? ហេតុអ្វី ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទៀងនិងប្រកបឱ្យបានត្រឹមត្រូវ ។

អាត្មោត សម្បុរ មាឌ កន្ទុយ កម្លាំង

ភ្នួរវាស់ ឧស្សាហ៍ អាចម៍ ប្រយោជន៍ គ្រួសារ

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ និងល្បះខាងក្រោម ។

មាឌ សម្បុរ ឧស្សាហ៍ ស្រឡាញ់ ប្រយោជន៍

រាល់ព្រឹក ខ្ញុំតែងកើបអាចម៍វាយកទៅដាក់ក្នុងរណ្ដៅសម្រាប់ធ្វើជី ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

ប្រយោជន៍ | រទេះ | ស្រឡាញ់ | ធំ | ភ្ជួររាស់ | មួយ

១. ខ្ញុំមានគោឈ្មោល ............................ក្បាលឈ្មោះអាត្នោត ។

២. វាមានមាឌ ........................ខ្ពស់ ស្វែងស្រួចកោងឱបចូលគ្នា ។

៣. គ្រួសារខ្ញុំទឹមវា ដើម្បី ......................និងអូស .................. ។

៤. ខ្ញុំ ........អាត្នោតណាស់ ព្រោះវាមាន ...........ចំពោះគ្រួសារខ្ញុំ ។

គ. ចូរបំពេញល្បះខាងក្រោមរូបឱ្យបានត្រឹមត្រូវ ។



ខ្ញុំមាន ............ ។



ខ្ញុំស្រឡាញ់ ............ ។



គោ ...ចំពោះគ្រួសារខ្ញុំ ។

# មេរៀនទី ៥៥ ពាក្យបង្ហាញលក្ខណៈ វត្ថុ មនុស្ស សត្វ រុក្ខជាតិ

## ការនិយាយ



តុមូល



ឆ្មាតូច



ស្វាយខ្ចី



គោធាត់



មនុស្សតឿ



មនុស្សស្គម

## លំហាត់

ចូរមើលរូប រួចបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។



ខ្ទង ...........



ដំរី ...... ឆ្កែ ......



ខោ ............

*រយៈពេល ០៨ ម៉ោងសិក្សា*

មេរៀនទី ៥៦

# ទេសភាពវាលស្រែនៅរដូវវស្សា

## អំណាន



នៅរដូវវស្សា វាលស្រែមានពណ៌ខៀវស្រងាត់ ។

សន្ទូងបែកគុម្ពដុះតជាប់គ្នា ឆ្ងាយដាច់កន្ទុយភ្នែក ហាក់ដូចជាកម្រាលព្រំពណ៌បៃតង ។ ពេលខ្យល់បក់ ស្លឹកស្រូវញ័ររញ្ជួយ ទោរទន់ ឱនងើបៗប្រៀបបាននឹងទឹករលករលេញ ក្នុងបឹងមួយដ៏ធំ ។ លើផ្ទៃមេឃមានកុក ក្រសារ រនាលក្រៀល ហើរទទះស្លាបទាំងហ្វូងៗ ។ កសិករជួតក្បាលនឹងក្រមាចម្រុះពណ៌កំពុងបោចស្មៅនិងដាក់ជីក្នុងស្រែ ។ យូរៗម្ដង គេឮសូរចម្រៀងប្រជាប្រិយយ៉ាងពីរោះ លន្លង់លន្លោច ។

គ្មានអ្វីគួរឱ្យចង់គយគន់ជាងទេសភាពវាលស្រែដ៏ស្រស់ត្រកាលនារដូវវស្សានេះឡើយ ។

## ការរៀនពាក្យ

### ក. អំណានពាក្យ

| | | |
|---|---|---|
| ញ៉ូវរញ្ជួយ | អានថា | ញ៉ូវ-រញ់-ជួយ |
| ប្រជាប្រិយ | អានថា | ប្រជា-ប្រី |
| គុម្ព | អានថា | គុំ |
| លន្លង់លន្លោច | អានថា | លន់-លង់-លន់-លោច |
| ទេសភាព | អានថា | ទេសៈ-ភាប |

### ខ. ពន្យល់ពាក្យ

ប្រជាប្រិយ : ដែលជាទីស្រឡាញ់របស់ប្រជាជន ។

លន្លង់លន្លោច : ស្រងេះស្រងោច ។

ទេសភាព : ភាពប្រកបដោយធម្មជាតិមានទឹក ដី ព្រៃព្រឹក្សា ។

### គ. ពាក្យន័យដូចនឹងពាក្យ " ទឹក "

ទឹក គង្គា វារី

### ឃ. ពាក្យផ្ទុយ

យឺត ≠ លឿន ឱន ≠ ងើប

## សំណួរ

១. តើវាលស្រែនៅរដូវវស្សាមានពណ៌ដូចម្ដេច ?

២. តើគេប្រៀបធៀបវាលស្រែទៅនឹងអ្វី ?

៣. តើនៅលើផ្ទៃមេឃមានសត្វអ្វីខ្លះ ?

៤. តើប្អូនពេញចិត្តទេសភាពវាលស្រែនៅរដូវវស្សាដែរឬទេ ? ព្រោះអ្វី ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទាំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| រដូវវស្សា | លន្លង់លន្លោច | ទេសភាព | គុម្ព | សន្ទូង | |
| កន្ទុយ | ញ័ររញ្ជួយ | ទោរទន់ | ចម្រុះ | ក្រមា | ប្រជាប្រិយ |

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម ។

កម្រាល ខ្យល់បក់ គ្រៀល ទោរទន់ រលក

គ្មានអ្វីគួរឱ្យចង់គយគន់ជាងទេសភាពវាលស្រែល្អស្រស់នារដូវវស្សានេះឡើយ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| ស្មៅ | ជួត | ស្គូរ | កន្ទុយ | ប្រជាប្រិយ | កម្រាល |
|---|---|---|---|---|---|

១. សន្ទូងបែកគុម្ពដុះតជាប់គ្នាឆ្ងាយដាច់ ................ ភ្នែកហាក់ដូចជា .......ព្រំពណ៌បៃតង ។

២. កសិករ ....ក្បាលនឹងក្រមាចម្រុះពណ៌កំពុងបោច ... និងដាក់ជីស្រែ ។

៣. យូរៗម្តងគេឮ .... ចម្រៀង .......... យ៉ាងពីរោះលន្លង់លន្លោច ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ “ រនាល ” ។

មេរៀនទី ៥៧

# អ្នកលក់មួកនិងសត្វស្វា

## អំណាន



ថ្ងៃមួយ មានជាងដេរមួកម្នាក់បានយកមួកទៅលក់តាមភូមិ ។ វេលាថ្ងៃត្រង់ គាត់ឈប់សម្រាកនៅក្រោមដើមឈើមួយដែលមានម្លប់ត្រជាក់ ។ គាត់ក៏សម្រាន្តលក់ទៅ ។ មួយសន្ទុះក្រោយមកមានសំឡេងចេចចាចៗ ធ្វើឱ្យគាត់ភ្ញាក់ ។ គាត់ងើយមើលទៅលើដើមឈើ ឃើញស្វាមួយហ្វូងកំពុងពាក់មួក ។ គាត់រើសដុំដីគប់ស្វាទាំងនោះ ។ ស្វាបេះផ្លែឈើគប់វិញ ។ ពេលនោះ គាត់នឹកឃើញថា សត្វស្វាចូលចិត្តធ្វើត្រាប់តាមណាស់ ។ គាត់ដោះមួកពីក្បាលគប់ទៅស្វា ។ ស្វាក៏ដោះមួកពីក្បាលគប់តបវិញ ។ គាត់រើសមួកទាំងអស់ រួចធ្វើដំណើរបន្តទៅទៀត ។

## ការរៀនពាក្យ

ក. អំណានពាក្យ

សម្រាន្ត  អានថា  សំ-រ៉ាន

ខ. ពន្យល់ពាក្យ

សម្ទុះ : កម្លាំង ទំហឹងល្បឿនដែលស្ទុះ(មួយភ្លែត ឬមួយរយៈពេលខ្លី) ។

ចេចចាច : សូរភាសាសត្វ មានគ្រលេងគ្រលោងជាដើម ។

គ. ពាក្យន័យដូចនឹងពាក្យ " សម្រាន្ត "

សម្រាន្ត ដេក គេង និទ្រា សិង ផ្ទុំ

ឃ. ពាក្យផ្ទុយ

ត្រជាក់ ≠ ក្តៅ

ត្រង់ ≠ វៀច

## សំណួរ

១. តើអ្នកលក់មួក សម្រាកនៅឯណា ?

២. តើសត្វអ្វីយកមួកគាត់ទៅពាក់ ?

៣. តើគាត់ធ្វើដូចម្តេច ទើបយកមួកទាំងអស់បានមកវិញ ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទៀងនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| សម្រាក | សម្រាន្ត | ហ្វូង | ចេចចាច | ម្លប់ |
| សត្វ | ដំណើរ | សំទុះ | បន្ត | ភ្ញាក់ |

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម ។

> ដេរ សម្រាក ម្លប់ សម្រាន្ត សម្ទុះ
> គាត់ងើយមើលទៅលើដើមឈើ ឃើញស្វាមួយហ្វូងកំពុងពាក់ម្លូក ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។

| សត្វស្វា | ចេចចាចៗ | ដំណើរ | សម្រាក |
|---|---|---|---|

១. វេលាថ្ងៃត្រង់គាត់ឈប់ ............... នៅក្រោមដើមឈើមួយ ដែលមានម្លប់ត្រជាក់ ។

២. មួយសម្ទុះក្រោយមក មានសំឡេង ............ ធ្វើឱ្យគាត់ភ្ញាក់ ។

៣. ពេលនោះគាត់ នឹកឃើញថា ......... ចូលចិត្តធ្វើត្រាប់តាមណាស់ ។

៤. គាត់រើសម្លូកទាំងអស់រួចធ្វើ .............. បន្តទៅទៀត ។

គ. ចូរមើលរូប រួចបំពេញល្បះតាមរូបឱ្យបានសមស្រប ។



ពូសំជា ...... ។ គាត់ជា ...... ។ បងស្រីខ្ញុំជា ...... ។ មីងបុប្ផាជា ...... ។

ឃ. ចូររកពាក្យទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. ខ្ញុំជា ................. ។

២. ឪពុករបស់ខ្ញុំជា ...................... ។

៣. ម្ដាយរបស់ខ្ញុំជា ...................... ។

មេរៀនទី
៥៨

# ការងារពុកម៉ែខ្ញុំ

## ចម្រៀង



(លំនាំបទ ខ្ញុំមានមាត់សម្រាប់និយាយ)

ខ្ញុំមានម៉ែពូកែកាត់ដេរ ពេលទំនេរថែកូនប្រុសស្រី
ទ្រព្យក្នុងផ្ទះទាំងចាស់ទាំងថ្មី ទោះហត់នឿយក្ដីម៉ែមិនត្អូញត្អែរ

បន្ទរ ៖ មែនហើយម៉ែមិនត្អូញត្អែរ ។

ខ្ញុំមានពុកជាអ្នកចម្ការ ពុកឧស្សាហ៍ថែមទាំងពូកែ
ដាំដំណាំបានប្រាក់ហូរហែ ដើម្បីពុកម៉ែខ្ញុំត្រូវខំរៀន

បន្ទរ ៖ មែនហើយយើងត្រូវខំរៀន ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ទ្រព្យ អានថា ទ្រ័ប

ត្អូញត្អែរ អានថា ត្អូញ-ត្អែ

ខ. ពន្យល់ពាក្យ

ទ្រព្យ : វត្ថុ ធនធាន សម្បត្តិ

ត្អូញត្អែរ : ត្អូញហើយ ត្អូញទៀត

គ. ពាក្យន័យដូចនឹងពាក្យ " កូន "

កូន បុត្រ

ឃ. ពាក្យផ្ទុយ

ត្រជាក់ ≠ ក្ដៅ

ក្រៅ ≠ ក្នុង

## សំណួរ

១. តើពេលទំនេរ ម្ដាយធ្វើអ្វីខ្លះ ?

២. តើឪពុកធ្វើការងារអ្វី ?

៣. តើឪពុកម្ដាយមានទឹកចិត្តដូចម្ដេចចំពោះកូន ?

៤. តើអ្នកគួរធ្វើដូចម្ដេច ដើម្បីឱ្យពុកម៉ែរបស់អ្នកសប្បាយចិត្ត ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។ តើមានតួអក្សរណាដែលមិនអាន ?

| |
|---|
| ទំនេរ ត្អូញត្អែរ ចម្ការ ឧស្សាហ៍ ដំណាំ ហូរហែ ទ្រព្យ |

ខ. ចូរអានវគ្គចម្រៀងខាងក្រោមឱ្យបានច្បាស់លាស់និងត្រឹមត្រូវ ។

ខ្ញុំមានម៉ែពូកែកាត់ដេរ ពេលទំនេរថែកូនប្រុសស្រី
ទ្រព្យក្នុងផ្ទះទាំងចាស់ទាំងថ្មី ទោះហត់នឿយក្តីម៉ែមិនត្អូញត្អែរ
ខ្ញុំមានពុកជាអ្នកចម្ការ ពុកឧស្សាហ៍ថែមទាំងពូកែ
ដាំដំណាំបានប្រាក់ហូរហែ ដើម្បីពុកម៉ែខ្ញុំត្រូវខំរៀន ។

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យនិងវគ្គចម្រៀងខាងក្រោម ។

| |
|---|
| ទំនេរ ទ្រព្យ ត្អូញត្អែរ ចម្ការ ឧស្សាហ៍ ហូរហែ |
| ខ្ញុំមានម៉ែពូកែកាត់ដេរ ពេលទំនេរថែកូនប្រុសស្រី ។ |
| ទ្រព្យក្នុងផ្ទះទាំងចាស់ទាំងថ្មី ទោះហត់នឿយក្តីម៉ែមិនត្អូញត្អែរ ។ |

២. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះតាមរូបភាពឱ្យបានត្រឹមត្រូវ ។

| លក់ដូរ | រាំរបាំ | គ្រូបង្រៀន | ជួសជុល |
|---|---|---|---|



ឪពុកខ្ញុំកំពុង .................. ទូរទស្សន៍ ។



ឪពុកខ្ញុំជា .............................. ។



ម្ដាយខ្ញុំជាអ្នក ............................ ។



ពួកគេកំពុង ............................ ។

# មេរៀនទី ៥៩ មុខរបរអ្នកភូមិខ្ញុំ

## អំណាន



នៅភូមិខ្ញុំ ប្រជាជនភាគច្រើនប្រកបរបរតម្បាញ ។

ពួកគេត្បាញហូល ផាមួង សារុងសូត្រ និងក្រមាសូត្រ ។ កាលណាត្បាញបានច្រើន គេយកវាទៅលក់នៅឯទីក្រុង ។ ហូល ផាមួងនៅទីនោះ មានគុណភាពល្អ ហើយលក់ដាច់ណាស់ ។ គ្រួសារអ្នកតម្បាញ ទាំងចាស់ទាំងក្មេង មានការងាររៀងៗខ្លួន ។ មនុស្សធំជួយថ្កុរនិងជ្រលក់សូត្រ ។ ឯក្មេងៗ ពេលទំនេរជួយរវៃនិងការសូត្រ ។

អ្នកភូមិខ្ញុំពេញចិត្តនឹងរបរនេះណាស់ ព្រោះវាធ្វើឱ្យជីវភាពពួកគេបានធូរធារ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

តម្បាញ អានថា ដំ-បាញ

ជីវភាព អានថា ជី-វៈ-ភាព

ថ្កូវ អានថា ថ្កូ

ខ. ពន្យល់ពាក្យ

តម្បាញ : គ្រឿងប្រដាប់សម្រាប់ត្បាញ ។

ថ្កូវ : ចង្កៀងខ្សែអំបោះឆ្វាក់សម្រាប់ត្បាញ ។

ការស្ងួត : មួរសរសៃសូត្រ អំបោះជាដើមដោយខ្នារ ។

គ. ពាក្យន័យដូចនឹងពាក្យ " មុខរបរ"

មុខរបរ អាជីព

ឃ. ពាក្យផ្ទុយ

ក្មេង ≠ ចាស់ ធូធារ ≠ ក្រខ្សត់

## សំណួរ

១. តើប្រជាជននៅភូមិនោះ គេច្រើនប្រកបមុខរបរអ្វី ?

២. តើគេត្បាញអ្វីខ្លះនៅទីនោះ ?

៣. តើគេយករបស់ទាំងនោះទៅលក់នៅទីណា ?

៤. តើប្រជាជននៅភូមិនោះ មានទឹកចិត្តដូចម្ដេចចំពោះមុខរបរពួកគេ ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ក្រមាសូត្រ តម្បាញ គុណភាព ជ្រលក់ ការស្ងួត ថ្កូវ សារុងសូត្រ ផាមួង

## សំណេរ

ក. ចូរសរសេរតាមអានរៀបចំអត្ថបទខាងក្រោម ។

### មុខរបរអ្នកភូមិខ្ញុំ

នៅភូមិខ្ញុំ ប្រជាជនភាគច្រើនប្រកបរបរតម្បាញ ។ ពួកគេត្បាញហូល ផាមួង សារុងសូត្រ និងក្រមាសូត្រ ។ ហូល ផាមួងនៅទីនោះ មានគុណភាពល្អ ហើយលក់ដាច់ណាស់ ។ អ្នកភូមិខ្ញុំ ពេញចិត្តនឹងរបរនេះណាស់ ព្រោះធ្វើឱ្យជីវភាពពួកគេបានធូរធារ ។

**សំណួរ**

១. តើប្រជាជនភាគច្រើនប្រកបរបរអ្វី ?

២. តើពួកគេត្បាញអ្វីខ្លះ ?

៣. តើអ្នកភូមិមានទឹកចិត្តដូចម្តេច ចំពោះមុខរបរនេះ ? ព្រោះអ្វី ?

**លំហាត់**

១. ចូរពន្យល់ពាក្យ “ជីវភាព”

២. ចូររកពាក្យន័យដូចនឹងពាក្យ “មុខរបរ”

៣. ចូររកពាក្យផ្ទុយនឹងពាក្យ “ធូរធារ”

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញឃ្លាខាងក្រោមឱ្យបាន ត្រឹមត្រូវ ។

| ទំនេរ | ខ្ញុំ | សូត្រ | សារុងសូត្រ | ប្រកប | ការសូត្រ |
|---|---|---|---|---|---|

១. គេត្បាញហូល ផាមួង ................ និងក្រមា.................. ។

២. ប្រជាជននៅភូមិ .......... ជាអ្នក ................. របរតម្បាញ ។

៣. ឯក្មេងៗពេល ............... ជួយរវៃនិង ....................... ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ “ ការងារ ” ។

# មេរៀនទី ៦០ ដើមត្នោត

## អំណាន



ប្រទេសកម្ពុជាយើង សម្បូរដើមត្នោតណាស់ ។

ដើមត្នោតដុះខ្ពស់ត្រដែត ហើយរាយស្ទើរពាសពេញទឹកដីនៃមាតុភូមិយើង ។ ដើមត្នោតមានរាងមូល ទ្រសំណុំស្លឹកពណ៌បៃតង ហាក់ដូចជាឆត្របើកចោលកណ្ដាលព្ធដ៏អាកាស ។ ដើមត្នោតមានប្រយោជន៍ច្រើនយ៉ាងណាស់ ។ ផ្កាវាគេគាបត្រងយកទឹកមករម្ងាស់បានជាស្ករ មានរសជាតិផ្អែមឈ្ងុយឆ្ងាញ់ ។ ដើមអាចយកមកធ្វើផ្ទះ ធ្វើទូក និងអាចយកមកធ្វើជាវត្ថុផ្សេងៗទៀត ។ គេអាចដេរក្រងស្លឹកត្នោតយកទៅប្រក់ជាដំបូលផ្ទះ ខ្ទម ឬរោងផ្សេងៗ ។

ខ្មែរយើងពេញចិត្តនឹងដើមត្នោតណាស់ ព្រោះវាជាសម្បត្តិធម្មជាតិ តាំងពីដូនតាមក ។

## ការរៀនពាក្យ

ក. អំណានពាក្យ

| | | |
|---|---|---|
| សម្បូរ | អានថា | សំ-បូរ |
| មាតុភូមិ | អានថា | មា-តុ-ភូម |
| ឰដ៏ | អានថា | អៃ-ដ |
| វត្ថុ | អានថា | វ៉ាត់-ថុ |
| សម្បត្តិ | អានថា | សំ-បាត់ |

ខ. ពន្យល់ពាក្យ

មាតុភូមិ : ទីកន្លែងកំណើត ។

ឰដ៏ : ក្នុង លើ ក្រោម ។

សំណុំ : អ្វីដែលគេប្រមូលរួមជាដុំ ។

វត្ថុ : របស់របរប្រើប្រាស់ ។

គ. ពាក្យន័យដូចនឹងពាក្យ " សម្បត្តិ "

សម្បត្តិ ទ្រព្យ ធនធាន

ឃ. ពាក្យផ្ទុយ

មូល ≠ ជ្រុង

សម្បូរ ≠ ខ្សត់ខ្សោយ

## សំណួរ

១. តើប្រទេសកម្ពុជាយើងសម្បូរអ្វី ?

២. តើដើមត្នោតមានដុះនៅកន្លែងណាខ្លះ ?

៣. តើដើមត្នោតផ្តល់ផលប្រយោជន៍អ្វីខ្លះ ?

៤. តើខ្មែរយើងមានទឹកចិត្តដូចម្តេចចំពោះដើមត្នោត ? ព្រោះអ្វី ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទង់និងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| ដើមត្នោត | សំណុំ | ស្ទើរ | ពាសពេញ | មាតុភូមិ | ត្រដែត |
| ឈ្មុយឆ្ងាញ់ | ឰដ៏អាកាស | វត្ថុ | សម្បត្តិ | ធម្មជាតិ | |

ខ. ចូរអានល្បះខាងក្រោមរូបនីមួយៗ ឱ្យបានត្រឹមត្រូវ ។



ពូសានកំពុងឡើងត្នោត ។



ជាតានិងតារាកំពុងផឹកទឹកត្នោត ។

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ កន្សោមពាក្យនិងល្បះខាងក្រោម ។

សម្បូរ មាតុភូមិ ឆត្រ ព្ធដ៏អាកាស ប្រយោជន៍

ខ្មែរយើងពេញចិត្តនឹងដើមត្នោតណាស់ ព្រោះវាជាសម្បត្តិធម្មជាតិ តាំងពីដូនតាមក ។

ខ. ចូរបំពេញល្បះតាមរូបនីមួយៗខាងក្រោមឱ្យបានត្រឹមត្រូវ ។



ប្រទេសកម្ពុជាសម្បូរ ............ ណាស់ ។

ត្នោតមានប្រយោជន៍ ............. យ៉ាង ។

ផ្កាវា គេគាបយកទឹករម្ងាស់ធ្វើ ......... ។

ដើមវា គេយកមកធ្វើ .................. ។



ពូសានកំពុងអុំ ...................... ។

ទូករបស់គាត់ធ្វើពី ...................... ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "រម្ងាស់" ។

មេរៀនទី
៦១

# កិច្ចការនៅសាលារៀន

## មេសូត្រ



(បទកាកគតិ)

យើងទៅសាលា រៀនសព្វកិច្ចការ រៀនកត់ចំណាំ
រៀនអានរៀនលេខ គំនូររបាំ កីឡានិងដាំ
ដំណាំនានា ។

សួនច្បារសាលា មានជីវម្ទេសផ្កា ល្អស្រស់សោភា
ព្រោះយើងស្រោចទឹក មិនដែលខ្ជិលខ្ជា នេះជាការងារ
នៅសាលាយើង ។

## ការរៀនពាក្យ

ក. អំណានពាក្យ

សព្ទ អានថា សប់

ខ. ពន្យល់ពាក្យ

កិច្ចការ : ការដែលត្រូវធ្វើ ។

សោភា : ល្អ ហ្មត់ហ្មង ភ្លឺត្រចះត្រចង់ ។

ខ្ជីខ្ជា : គឺធ្វើការឬនិយាយមិនហ្មត់ចត់ ។

គ. ពាក្យន័យដូចនឹងពាក្យ " ផ្កា "

ផ្កា បុប្ផា បុស្បា

ឃ. ពាក្យផ្ទុយនឹងពាក្យ " ខ្ជីខ្ជា ស្រស់ "

ខ្ជីខ្ជា ≠ ហ្មត់ចត់

ស្រស់ ≠ ក្រៀម

## សំណួរ

១. តើនៅសាលារៀន ពួកគេរៀនអ្វីខ្លះ ?

២. តើដំណាំលូតលាស់ដោយសារអ្វី ?

៣. តើប្អូនចូលចិត្តទៅសាលារៀនដែរឬទេ ? ព្រោះអ្វី ?

## លំហាត់

តើពាក្យណាខ្លះចួននឹងពាក្យ " សាលា ចំណាំ "

សាលា ចួននឹងពាក្យ ...............

ចំណាំ ចួននឹងពាក្យ ...............

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ និងកន្សោមពាក្យខាងក្រោម ។

| | | | | |
|---|---|---|---|---|
| កិច្ចការ | របាំ | សួនច្បារ | ឱ្យខ្ជា | ការងារ |
| សួនច្បារសាលា | | មានជីវម្ទេសផ្កា | | លម្អស្រស់សោភា |

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញមេសូត្រខាងក្រោមឱ្យបាន ត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| ចំណាំ | ការងារ | ដាំ | ឱ្យខ្ជា | កិច្ចការ |

| | | |
|---|---|---|
| យើងទៅសាលា | រៀនសព្វ ..... | រៀនកត់ ........ |
| រៀនអានរៀនលេខ | គំនូររបាំ | កីឡានិង ........ |
| | ដំណាំនានា ។ | |
| សួនច្បារសាលា | មានជីវម្ទេសផ្កា | លម្អស្រស់សោភា |
| ព្រោះយើងស្រោចទឹក | មិនដែល ....... | នេះជា .......... |
| | នៅសាលាយើង ។ | |

គ. ចូរតែងល្បះតាមរូបភាពខាងក្រោម ឱ្យបានត្រឹមត្រូវ ។





..................... ។ ..................... ។ ..................... ។

*រយៈពេល ០៨ ម៉ោងសិក្សា*

មេរៀនទី
៦២

# រាជធានីភ្នំពេញ

## អំណាន



ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ មានវិថីខ្វាត់ខ្វែងនិងមានស្ពានអាកាសកោងខ្ពស់ ។ នៅសងខាងផ្លូវមានផ្ទះថ្មនិងអគារធំៗ ខ្ពស់ៗ ។ នៅពេលរាត្រី មានភ្លើងចម្រុះពណ៌ភ្លឺចិញ្ចាច ។ នៅតាមដងផ្លូវមានមនុស្សម្នាធ្វើចរាចរណ៍យ៉ាងមមាញឹក ។ អ្នកមកលេងរាជធានីភ្នំពេញ ច្រើនទៅវត្តភ្នំ ព្រះបរមរាជវាំង វិមានឯករាជ្យ សារមន្ទីរជាតិ និងកោះពេជ្រ ។

សម្រស់រាជធានីភ្នំពេញបានដក់ជាប់ក្នុងចិត្តអ្នកមកលេងគ្រប់ៗគ្នា ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ចរាចរណ៍ អានថា ចៈ-រ៉ា-ច

ឯករាជ្យ អានថា អែក-កៈ-រាច

បរមរាជវាំង អានថា ប-រ៉ុម-រាច-វាំង

សារមន្ទីរ អានថា សា-រៈ-មន់-ទី

ខ. ពន្យល់ពាក្យ

ចិញ្ចាច : ដែលពេញពន្លឺ ។

ចរាចរណ៍ : ការធ្វើដំណើរទៅមក ។

ឯករាជ្យ : ឈ្នះ ជ័យជម្នះ ។

សារមន្ទីរ : កន្លែងទុកវត្ថុបុរាណ ។

គ. ពាក្យន័យដូចនឹងពាក្យ “ រាត្រី ”

រាត្រី យប់

ឃ. ពាក្យផ្ទុយ

ភ្លឺចិញ្ចាច ≠ ងងឹតសូន្យ មមាញឹក ≠ មួយៗ

## សំណួរ

១. តើរាជធានីរបស់ព្រះរាជាណាចក្រកម្ពុជា ឈ្មោះអ្វី ?

២. តើនៅសងខាងផ្លូវមានអ្វីខ្លះ ?

៣. តើអ្នកមករាជធានីភ្នំពេញ ច្រើនទៅលេងកន្លែងណាខ្លះ ?

៤. តើប្អូនមានទឹកចិត្តដូចម្តេច ចំពោះរាជធានីភ្នំពេញ ?

## លំហាត់

ចូរអានស្លាកសញ្ញានៅក្នុងរូបខាងក្រោមឱ្យបានត្រឹមត្រូវ ។












# សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យ និងល្បះខាងក្រោម ។

វិថី អគារ រាត្រី ចិញ្ចាច ចរាចរណ៍

ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

ខ. ចូរតែងល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ ។




..............................

.............................. ។



..............................

.............................. ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "អាកាស" ។

មេរៀនទី
៦៣

# ភូមិរុងរឿង

## អំណាន



ភូមិខ្ញុំស្ថិតនៅតំបន់ជនបទ តែសម្បូរសប្បាយ ។

ភូមិខ្ញុំមានវាលស្រែធំល្វឹងល្វើយ ផ្លូវថ្នល់ស្អាត មានសាលារៀន មន្ទីរពេទ្យ និងវត្តអារាម ។ ពួកគេធ្វើស្រែចម្ការបានផលល្អជារៀងរាល់ឆ្នាំ ។ ប្រជាជនភាគច្រើន មានជីវភាពសមរម្យ ។ នៅតាមគេហដ្ឋាននីមួយៗ សុទ្ធតែមានបង្គន់អនាម័យ ។ ពួកគេចេះសាមគ្គី ស្រឡាញ់គ្នា និងជួយធុរៈគ្នា ហើយរស់នៅដោយសុខសាន្ត ។ ចំណែកក្មេងៗ បានចូលរៀនគ្រប់ៗគ្នា ។ ខ្ញុំស្រឡាញ់ភូមិខ្ញុំណាស់ ។

ហេតុដូច្នេះហើយ បានជាភូមិខ្ញុំមានឈ្មោះថា ភូមិរុងរឿង ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ហេតុ អានថា ហែត

សមរម្យ អានថា សំ-រំ

វត្ត អានថា វាត់

មន្ទីរពេទ្យ អានថា មន់-ទី-ពែត

ខ. ពន្យល់ពាក្យ

សាមគ្គី : សេចក្ដីព្រមព្រៀងជាមួយគ្នា ដំណើរស្រុះគ្នា ។

សមរម្យ : ដែលត្រូវបែប ត្រូវយ៉ាង ដែលមិនទាស់ភ្នែក ។

គ. ពាក្យន័យដូចនឹងពាក្យ " ផ្លូវ "

ផ្លូវ ថ្នល់ វិថី មាគ៌ា

ឃ. ពាក្យផ្ទុយ

រុងរឿង ≠ អាប់ឱន

ស្រឡាញ់ ≠ ស្អប់

## សំណួរ

១. តើភូមិរុងរឿងមានអ្វីខ្លះ ?

២. តើប្រជាជននៅភូមិរុងរឿង ប្រកបមុខរបរអ្វី ?

៣. តើប្រជាជនទាំងនោះមានជីវភាពដូចម្ដេច ?

៤. ហេតុអ្វីបានជាគេហៅថា ភូមិរុងរឿង ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទួំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| |
|---|
| ប្រជាជន ភូមិ ផល ល្វឹងល្វើយ សាមគ្គី សុខសាន្ត រុងរឿង វត្ត មន្ទីរពេទ្យ |

ខ. ចូរនិយាយពីអ្វីដែលប្អូនចាប់អារម្មណ៍ជាងគេ ក្នុងភូមិរបស់ប្អូនតាមសំណួរដូចខាងក្រោម ។

១. តើប្រជាជននៅក្នុងភូមិរបស់ប្អូនច្រើនប្រកបរបរអ្វី ?

២. តើភូមិរបស់ប្អូនមានមន្ទីរពេទ្យ សាលារៀន វត្តឬទេ ?

៣. តើពេលធ្វើបុណ្យទានម្តងៗ ប្អូននិងអ្នកភូមិទៅវត្តណា ?

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យ និងល្បះខាងក្រោម ។

| |
|---|
| សាមគ្គី រុងរឿង សុខសាន្ត ជីវភាព សមរម្យ |
| ភូមិខ្ញុំមានវាលស្រែធំល្វឹងល្វើយ ផ្លូវថ្នល់ស្អាត មានសាលារៀនមន្ទីរពេទ្យ និងវត្តអារាម ។ |

ខ. ចូរជ្រើសរើសពាក្យទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| រុងរឿង | ភូមិ | ជីវភាព |
|---|---|---|

១. ខ្ញុំស្រឡាញ់ ...................... ខ្ញុំណាស់ ។

២. ប្រជាជនមាន .................. សមរម្យ ។

៣. ភូមិខ្ញុំឈ្មោះថាភូមិ ....................... ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ " រុងរឿង " ។

# មេរៀនទី ៦៤ ផឹកទឹកកខ្វក់នាំឱ្យកើតជំងឺ

## អំណាន



រាល់ថ្ងៃ ស្ពានិងស្ពាយតែងទៅឃ្វាលគោនៅឯវាលឆ្ងាយពីផ្ទះ ។ ជាទម្លាប់ ស្ពាតែងដាក់ទឹកឆ្អិនក្នុងដបយកទៅផឹក ។ ទៅដល់កន្លែងឃ្វាលគោ ស្ពានិងស្ពាយ នាំគ្នាលេងវែកយ៉ាងសប្បាយ ។ ពេលស្រេកទឹក ស្ពាបានផឹកទឹកឆ្អិនដែលខ្លួនបាន យកមកពីផ្ទះ ។ ចំណែកស្ពាយ ចុះទៅក្បង់ទឹកត្រពាំងផឹក ។ ពេលត្រឡប់មកផ្ទះ វិញ ស្ពាយចុកពោះ រាកទល់ភ្លឺមិនបានដេកបន្តិចសោះ ។ លុះព្រឹកឡើង ស្ពាទៅ រៀនជាធម្មតា ។ រីឯស្ពាយវិញ កើតជំងឺរាកមិនអាចទៅសាលារៀនបានឡើយ ។

ការផឹកទឹកកខ្វក់ នាំឱ្យកើតជំងឺ ។ អនាម័យនាំឱ្យមានសុខភាពល្អ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ធម្មតា អានថា ធ័ម-មៈ-តា

អនាម័យ អានថា អៈ-ណា-ម៉ៃ

ខ. ពន្យល់ពាក្យ

ឃ្វាល : ចាំ រក្សាសត្វចិញ្ចឹម ។

អនាម័យ : មិនមានរោគ មិនមានជំងឺ ។

គ. ពាក្យន័យដូចនឹងពាក្យ "ឃ្វាល"

ឃ្វាល ចាំ មើល រក្សា

ឃ. ពាក្យផ្ទុយ

កខ្វក់ ≠ ស្អាត ឆ្អិន ≠ ឆៅ

សំណួរ

១. តើស្ពានិងស្ពាយទៅឃ្វាលគោនៅឯណា ?

២. តើស្ពាមានទម្លាប់ដូចម្តេច ?

៣. ហេតុអ្វីបានស្ពាយកើតជំងឺរាក ?

៤. ហេតុអ្វីបានជាយើងត្រូវផឹកទឹកស្អាត ?

លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទាំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ឃ្វាល ទម្លាប់ ស្រេក ត្រពាំង ធម្មតា កខ្វក់ អនាម័យ សុខភាព បន្តិច

## សំណេរ

ក. ចូរសរសេរតាមអានរៀបចំអត្ថបទខាងក្រោម ។

### ផឹកទឹកកខ្វក់នាំឱ្យកើតជំងឺ

រាល់ថ្ងៃ ស្ពានិងស្ពាយតែងទៅឃ្វាលគោនៅឯវាលឆ្ងាយពីផ្ទះ ។ ជាទម្លាប់ស្ពាតែងដាក់ទឹកឆ្អិនក្នុងដបយកទៅផឹក ។ ចំណែកស្ពាយ ពេលស្រេកទឹក គេចុះ

ទៅក្បែរទឹកត្រពាំងផឹក ។ ពេលត្រឡប់មកផ្ទះវិញ ស្វាយក៏ចុកពោះរាកយ៉ាងខ្លាំង ។ ការផឹកទឹកកខ្វក់ នាំឱ្យកើតជំងឺ ។ អនាម័យនាំឱ្យមានសុខភាពល្អ ។

សំណួរ

១. តើពេលទៅឃ្វាលគោ ស្វាយកទឹកអ្វីទៅផឹក ?

២. ហេតុអ្វីបានជាស្វាយកើតជំងឺ ?

៣. តើប្អូនត្រូវធ្វើដូចម្ដេច ដើម្បីឱ្យមានសុខភាពល្អ ?

លំហាត់

១. ចូរពន្យល់ពាក្យ "អនាម័យ" ។

២. ចូររកពាក្យន័យដូចនឹងពាក្យ "ឃ្វាល" ។

៣. ចូររកពាក្យផ្ទុយនឹងពាក្យ "កខ្វក់" ។

ខ. ចូរគូសភ្ជាប់ផ្នែក "ក" និង "ខ" ខាងក្រោមឱ្យបានត្រឹមត្រូវ ។

| ផ្នែក "ក" | ផ្នែក "ខ" |
|---|---|
| ១. ជាទម្លាប់ ស្វាតែងដាក់ | ក. នាំឱ្យកើតជំងឺ ។ |
| ២. ការផឹកទឹកកខ្វក់ | ខ. ទឹកឆ្អិនក្នុងដបយកទៅផឹក ។ |

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "អនាម័យ" ។

# មេរៀនទី ៦៥ រឿងសត្វលលកនិងស្រមោចខ្មៅ

## អំណាន



មានសត្វលលកមួយហើរទៅឃើញពួកស្រមោចខ្មៅ កំពុងលង់ទឹកហែលតោងគ្នា ។ លលកមានចិត្តអាណិត ក៏ពាំមែកឈើងាប់មួយមកដាក់ធ្វើជាស្ពានឱ្យស្រមោចទាំងនោះតោងវារឡើងមកលើគោក បានរួចផុតពីក្ដីស្លាប់ ។

ថ្ងៃមួយ មានព្រានប្រមាញ់ម្នាក់ ឃើញលលកទំលើមែកជ្រៃ ក៏លើកស្នាតម្រង់បម្រុងនឹងបាញ់លលកនោះ ។ ស្រមោចឃើញដូច្នោះ ក៏នាំគ្នាវារឡើងទៅខាំជើងព្រាន ។ នាយព្រានភ្ញាក់ ក៏ទន្រ្ទាំជើងព្នួសួរដល់លលក ។ លលកដឹងខ្លួនក៏ហើរចេញទៅ រួចផុតពីសេចក្ដីស្លាប់ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

តម្រង់ អានថា តំ-រ៉ង់

ទន្ត្រំ អានថា ទន់-ត្រំ

ដូច្នោះ អានថា ដូច-ចុះ

សេចក្ដី អានថា សាច់-ក្ដី

ខ. ពន្យល់ពាក្យ

ស្នា : អាវុធបុរាណមួយប្រភេទធ្វើសម្រាប់បាញ់ព្រួញ ។

ព្រាន : អ្នកប្រមាញ់សត្វ ។

ទន្ត្រំ : ដាក់ជើងច្រំខ្លាំងៗ ។

វារ : លូនដោយប្រវា ។

គ. ពាក្យមានន័យដូចនឹងពាក្យ "ស្លាប់"

ស្លាប់ ងាប់ អស់ជីវិត ក្ស័យ មរណា ទិវង្គត

មរណៈ សុគត អនិច្ចកម្ម អនិច្ចធម្ម សោយទិវង្គត

ឃ. ពាក្យផ្ទុយ

គោក ≠ ទឹក

ស្លាប់ ≠ រស់

ចេញ ≠ ចូល

## សំណួរ

១. តើលលកឃើញស្រមោចកំពុងធ្វើអ្វី ? នៅកន្លែងណា ?

២. សត្វស្រមោចបានរួចជីវិតដោយសារនរណា ?

៣. ហេតុអ្វីបានជាស្រមោចតោងវារឡើងខាំជើងព្រានប្រមាញ់ ?

៤. ចំពោះប្អូនវិញ តើប្អូនធ្វើដូចស្រមោចឬទេ ? ព្រោះអ្វី ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

វារ ព្រាន អាណិត សេចក្ដី ស្រមោច ប្រមាញ់ តម្រង់ ទន្ត្រំ បម្រុង ស្ពាន

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ និងល្បះខាងក្រោម ។

ភ្ញាក់ ព្រាន ប្រជាជន កសិករ ឧស្សាហ៍

លលកដឹងខ្លួន ក៏ហើរចេញទៅ រួចផុតពីសេចក្ដីស្លាប់ ។

ខ. ចូរតែងល្បះងាយៗដោយប្រើពាក្យ ។

ភូមិ ថែរក្សា ប្រជាជន វារ

១. ............................................................................ ។

២. ............................................................................ ។

៣. ............................................................................ ។

៤. ............................................................................ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "លលក" ។

# មេរៀនទី ៦៦ រឿងចាបនិងដំរី

## អំណាន



នៅព្រៃធំមួយ មានសត្វចាបនិងដំរីដណ្ដើមគ្នាធ្វើជាមេ ។

ថ្ងៃមួយ ដំរីបបួលចាបផឹកទឹកភ្នាល់គ្នា ។ បើអ្នកណាផឹកបានច្រើនជាង អ្នកនោះជាអ្នកឈ្នះ ។ ចាបក៏យល់ព្រម ហើយហើរនាំផ្លូវដំរីកាត់ព្រៃភ្នំទៅកាន់សមុទ្រ ។ ពេលនោះ ទឹកសមុទ្រកំពុងជោរ ចាបក៏ឱ្យដំរីផឹកទឹកមុន ។ ទឹកសមុទ្រប្រៃពិបាកលេបណាស់ តែដោយចង់ឈ្នះ ដំរីខំផឹកឥតឈប់ ។ ទឹកសមុទ្រនៅតែជោរឡើងដល់ពោះវា ទើបដំរីឈប់ផឹក ។ លុះទឹកនាច ចាបក៏ហើរទៅមាត់ទឹកឱនក្បាលជ្រលក់ចំពុះក្នុងទឹកធ្វើជាផឹក ។ ទឹកស្រកចុះ ចាបក៏លោតតាមទឹកនាចធ្វើជាផឹករហូតដល់ជើងដំរី ។ ចាបផឹកទឹករហូត ទាល់តែដំរីយ៉ាត់ ។

តាំងពីពេលនោះមក ចាបក៏បានធ្វើជាមេ ដោយសារប្រាជ្ញាឈ្លាសវៃរបស់ខ្លួន ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ដណ្ដើម អានថា ដន់-ដើម

ខ. ពន្យល់ពាក្យ

ជោរ : ទឹកឡើង ។

នាច : ទឹកស្រក ។

## សំណួរ

១. តើចាបនិងដំរីដណ្ដើមគ្នាធ្វើអ្វី ?

២. តើចាបហើរនាំដំរីទៅណា ?

៣. តើចាបនិងដំរីភ្នាល់គ្នាធ្វើអ្វី ?

៤. តើចាបធ្វើដូចម្ដេច ទើបឈ្នះដំរី ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ព្រៃ សត្វ ដណ្ដើម ភ្នាល់ ភ្នំ សមុទ្រ ជោរ នាច ប្រាជ្ញា ឈ្លាសវៃ

ខ. ចូររៀបល្បះខាងក្រោមឱ្យត្រូវតាមលំដាប់លំដោយសាច់រឿង ។

១. ថ្ងៃមួយ ដំរីបបួលចាបផឹកទឹកភ្នាល់គ្នា ។

២. លុះទឹកនាច ចាបក៏ហើរទៅមាត់ទឹក ឱនក្បាលជ្រលក់ចំពុះក្នុងទឹកធ្វើជាផឹក ។

៣. ពេលនោះ ទឹកសមុទ្រកំពុងជោរ ចាបក៏ឱ្យដំរីផឹកទឹកមុន ។

៤. ទឹកស្រកចុះ ចាបក៏លោតតាមទឹកនាច ធ្វើជាផឹករហូតដល់ជើងដំរី ។

៥. តាំងពីពេលនោះមក ចាបបានធ្វើជាមេ ដោយសារប្រាជ្ញាឈ្លាសវៃរបស់ខ្លួន ។

៦. នៅព្រៃធំមួយ មានសត្វចាបនិងដំរីដណ្ដើមគ្នាធ្វើជាមេ ។

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យ និងល្បះខាងក្រោម ។

| |
|---|
| ដណ្ដើម ភ្ញាល់ ភ្នំ សមុទ្រ ជោរ នាច ប្រាជ្ញា ឈ្លាសវៃ<br>នៅព្រៃធំមួយ មានសត្វចាបនិងដំរីដណ្ដើមគ្នាធ្វើជាមេ ។ |

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឈ្លាសវៃ | ចាប | ដំរី | លេប | ផឹក | នាច | ជោរ | និង |

១. នៅព្រៃធំមួយមានសត្វចាប ............ ដំរីដណ្ដើមគ្នាធ្វើជាមេ ។

២. ពេលនោះ ទឹកសមុទ្រកំពុង ...............ចាបក៏ឱ្យដំរីផឹកទឹកមុន ។

៣. ទឹកសមុទ្រប្រៃ ពិបាក ................ណាស់ តែដោយចង់ឈ្នះ ដំរីខំ ....... ឥតឈប់ ។

៤. ទឹកស្រកចុះ ចាបក៏លោតតាមទឹក ... ធ្វើជាផឹករហូតដល់ជើង ... ។

៥. តាំងពីពេលនោះមក ...បានធ្វើជាមេដោយសារប្រាជ្ញា ...របស់ខ្លួន ។

គ. ចូររកពាក្យមកបំពេញអត្ថបទខាងក្រោមឱ្យបានត្រឹមត្រូវ ។

ពេលនោះ ទឹក ... កំពុងជោរ ចាបក៏ឱ្យដំរីផឹកទឹកមុន ។ ទឹកសមុទ្រប្រៃពិបាកលេប ... តែដោយចង់ ...ដំរីខំផឹកឥតឈប់ ។ ទឹកសមុទ្រនៅតែជោរឡើងដល់ពោះវា ទើបដំរី ...ផឹក ។

មេរៀនទី
៦៧

# វត្ថុប្រើប្រាស់នៅក្នុងផ្ទះ

## អំណាន



ផ្ទះរបស់ខ្ញុំសង់អំពីឈើប្រក់ក្បឿង មានពីរខ្នងនិងមានវត្ថុប្រើប្រាស់ជាច្រើន ។

នៅក្នុងផ្ទះនេះ មានបន្ទប់ទទួលភ្ញៀវ បន្ទប់ដេក និងបន្ទប់ទទួលទានអាហារ ។ បន្ទប់ទទួលភ្ញៀវមានក្តារជឿធំមួយធ្វើអំពីឈើនាងនួនរលោងស្រិល មានតុមួយ កៅអីពីរ និងទូរទស្សន៍មួយ ។ រីឯបន្ទប់ទទួលទានអាហារ មានតុមូលធំមួយនិងកៅអីប្រាំ ។ នៅក្បែរនោះមានទូដាក់ចាន រៀបយ៉ាងស្អាតនិងមានរបៀប ។ ក្នុងបន្ទប់ដេក មានគ្រែ និងទូដាក់សម្លៀកបំពាក់ ។ វត្ថុប្រើប្រាស់នៅក្នុងផ្ទះរបស់ខ្ញុំមិនទំនើបទាន់សម័យមែន ប៉ុន្តែខ្ញុំសម្អាតវាជាប្រចាំ ។

ខ្ញុំស្រឡាញ់ផ្ទះខ្ញុំណាស់ ព្រោះវាបានមកពីកម្លាំងញើសឈាមរបស់ឪពុកម្តាយខ្ញុំ ហើយខ្ញុំរស់នៅក្នុងផ្ទះនេះរាល់ថ្ងៃ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ទូរទស្សន៍ អានថា ទូរៈ-ទស់

សម័យ អានថា សះ-ម៉ៃ

ខ. ពន្យល់ពាក្យ

ទូរទស្សន៍ : ឈ្មោះគ្រឿងប្រដាប់វិទ្យាសាស្ត្រម្យ៉ាងសម្រាប់បញ្ចាំង បញ្ជូនរូបភាព និងសូរស័ព្ទទៅទីឆ្ងាយបាន ។

សម័យ : កាល ពេល វេលា ។

គ. ពាក្យន័យដូចនឹងពាក្យ "ឈាម"

ឈាម លោហិត

ឃ. ពាក្យផ្ទុយ

ទំនើប ≠ បុរាណ

រលោង ≠ គគ្រើម

## សំណួរ

១. តើផ្ទះនេះមានប៉ុន្មានបន្ទប់ ?

២. តើវត្ថុប្រើប្រាស់ក្នុងផ្ទះមានអ្វីខ្លះ ?

៣. ហេតុអ្វីបានជាយើងត្រូវថែទាំសម្អាតវត្ថុប្រើប្រាស់ក្នុងផ្ទះ ?

៤. តើប្អូនមានទឹកចិត្តដូចម្តេច ចំពោះផ្ទះរបស់ប្អូន ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទៀងនិងប្រកប ឱ្យបានត្រឹមត្រូវ ។

| |
|---|
| ទូរទស្សន៍ ស្រឡាញ់ សម័យ គ្រឿង វត្ថុ គ្រែ សម្លៀកបំពាក់ បន្ទប់ |

ខ. ចូរអ្នករៀបរាប់វត្ថុប្រើប្រាស់និងប្រាប់ចំនួនដែលមាននៅក្នុងមេរៀន ។

## សំណេរ

ក. ចូរសរសេរតាមអានរៀបចំអត្ថបទខាងក្រោម ។

### វត្ថុប្រើប្រាស់នៅក្នុងផ្ទះ

ផ្ទះខ្ញុំសង់អំពីឈើប្រក់គ្រឿង មានពីរខ្នងនិងវត្ថុប្រើប្រាស់ជាច្រើន ។ បន្ទប់ទទួលភ្ញៀវមានក្ដារជើងធំមួយ មានតុមួយ កៅអីពីរ និងទូរទស្សន៍មួយ ។ បន្ទប់ទទួលទានអាហារ មានតុមូលធំមួយ និងកៅអីប្រាំ ។ វត្ថុប្រើប្រាស់នៅក្នុងផ្ទះខ្ញុំមិនទំនើបទាន់សម័យមែន ប៉ុន្តែខ្ញុំសម្អាតវាជាប្រចាំ ។

## សំណួរ

១. តើផ្ទះគេសង់អំពីអ្វី ?

២. តើនៅក្នុងបន្ទប់ទទួលភ្ញៀវនិងបន្ទប់ទទួលទានអាហារមានអ្វីខ្លះ ?

៣. តើវត្ថុប្រើប្រាស់ក្នុងផ្ទះនេះ មានលក្ខណៈដូចម្ដេច ?

លំហាត់

១. ចូរពន្យល់ពាក្យ "សម័យ"

២. ចូររកពាក្យន័យដូចនឹងពាក្យ "ឈាម"

៣. ចូររកពាក្យផ្ទុយនឹងពាក្យ "ទំនើប"

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| ឈើ | ទទួលទាន | ភ្ញៀវ | សម្អាត | សម័យ |
|---|---|---|---|---|

១. ផ្ទះរបស់ខ្ញុំសង់អំពី ............ប្រក់ក្បឿង ។

២. នៅក្នុងផ្ទះនេះមានបន្ទប់ទទួល ..................បន្ទប់ដេក បន្ទប់ ............អាហារ ។

៣. វត្ថុប្រើប្រាស់នៅក្នុងផ្ទះរបស់ខ្ញុំ មិនទំនើបទាន់.........ទេ ប៉ុន្តែខ្ញុំ ............វាជាប្រចាំ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "ថៃទាំ" ។

# មេរៀនទី ៦៨ រឿងដឹងសងដឹង អំបែងសងអំបែង

## ការស្ដាប់





## សំណួរ

១. តើបុរសនោះខ្ចីរបស់អ្វីពីសេដ្ឋី ?

២. តើសេដ្ឋីខ្ចីអ្វីពីបុរសនោះ ?

៣. តើបុរសនិងសេដ្ឋីព្រមយករបស់ថ្មីដែរឬទេ ?

៤. បន្ទាប់ពីស្ដេចកាត់ក្ដីហើយ តើបុរសនិងសេដ្ឋីសុខចិត្តដែរឬទេ ? ព្រោះអ្វី ?

រយៈពេល ០៨ ម៉ោងសិក្សា

មេរៀនទី ៦៩

# បឹងទន្លេសាប

## អំណាន



បឹងទន្លេសាប ជាជង្រុកត្រីនៃប្រទេសកម្ពុជា ។

នៅរដូវវស្សា បឹងទន្លេសាបលាតសន្ធឹងល្វឹងល្វើយ ។ បឹងនេះ មានព្រៃរនាមដុះជុំវិញដែលជាជម្រកសម្រាប់ត្រីពង ។ បឹងទន្លេសាបសម្បូរត្រីទឹកសាបជាងគេលើពិភពលោក ។ រៀងរាល់ឆ្នាំ ប្រជាជនយើងនេសាទត្រីបានច្រើនក្រៃលែង ។ ពួកគេយកត្រីទាំងនោះសម្រាប់ធ្វើម្ហូបអាហារដូចជាប្រហុក ផ្អក ត្រីងៀត ត្រីឆ្អើរ ។ល ។ ផ្ទៃដីជុំវិញបឹងទន្លេសាប មានដីជាតិល្អណាស់សម្រាប់ដំណាំកសិកម្ម ពិសេសដំណាំស្រូវ ។

បឹងទន្លេសាប ជាប្រភពធនធានធម្មជាតិមួយយ៉ាងសំខាន់នៃប្រទេសកម្ពុជា ។

## ការរៀនពាក្យ

ក. អំណានពាក្យ

វស្សា អានថា វ័ស-សា

ធម្មជាតិ អានថា ធ័ម-មៈ-ជាត

កសិកម្ម អានថា កៈ-សិ-កាំ

ខ. ពន្យល់ពាក្យ

កសិកម្ម : ការធ្វើស្រែ ចម្ការ ចិញ្ចឹមសត្វ ។

ធម្មជាតិ : អ្វីៗដែលកើតឡើងដោយឯកឯង ។

ធនធាន : ទ្រព្យរបស់ផ្សេងៗដែលគង់នៅ ។

គ. ពាក្យន័យដូចនឹងពាក្យ "ប្រជាជន"

ប្រជាជន ប្រជារាស្ត្រ ប្រជាពលរដ្ឋ

## សំណួរ

១. តើបឹងទន្លេសាបមានលក្ខណៈដូចម្ដេច ?

២. តើនៅជុំវិញបឹងទន្លេសាបមានអ្វីដុះ ?

៣. តើគេយកត្រីមកធ្វើអ្វីខ្លះ ?

៤. ហេតុអ្វីបានជាដំណាំនៅជុំវិញបឹងទន្លេសាបផ្ដល់ផលបានច្រើន ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទួំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| ប្រទេសកម្ពុជា | លាតសន្ធឹង | ព្រៃរនាម | ជម្រក | ពិភពលោក |
| ផ្ទៃដី | ប្រភព | ធនធាន | ធម្មជាតិ | |

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម ។

| |
|---|
| ល្វឹងល្វើយ វស្សា កម្ពុជា ធនធាន ធម្មជាតិ |
| នៅរដូវប្រាំងទឹករាក់ ប្រជាជនយើងនេសាទត្រីបានច្រើនក្រៃលែង ។ |

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| កសិកម្ម | ទឹកសាប | ជុំវិញ | ល្វឹងល្វើយ | ជម្រក |

១. បឹងទន្លេសាប ជា .........ត្រីនៃប្រទេសកម្ពុជា ។

២. នៅរដូវវស្សា បឹងទន្លេសាបលាតសន្ធឹង .............. ។

៣. បឹងទន្លេសាបសម្បូរត្រី ...........ជាងគេលើពិភពលោក ។

៤. ផ្ទៃដី ...........បឹងទន្លេសាប មានដីជាតិល្អណាស់សម្រាប់ដំណាំ .........ពិសេសដំណាំស្រូវ ។

គ. ចូរគូសភ្ជាប់ឃ្លាខាងក្រោមឱ្យបានជាល្បះត្រឹមត្រូវ ។

| | |
|---|---|
| ១. បឹងទន្លេសាបជាជម្រកត្រី | ក. ជាងគេលើពិភពលោក ។ |
| ២. បឹងទន្លេសាបជាប្រភពធនធាន | ខ. នៃប្រទេសកម្ពុជា ។ |
| ៣. បឹងនេះមានព្រៃរនាមដុះជុំវិញ | គ. ធម្មជាតិមួយយ៉ាងសំខាន់នៃប្រទេសកម្ពុជា ។ |
| ៤. បឹងទន្លេសាបសម្បូរត្រីទឹកសាប | ឃ. ដែលជាជម្រកសម្រាប់ត្រីពង ។ |

# មេរៀនទី ៧០ រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម

## អំណាន



កាលពីព្រេងនាយ ពិភពលោកកើតភាពរាំងស្ងួត ក្ដៅហួតហែងគ្មានទឹកភ្លៀងសោះ ។

ស្ទឹង ត្រពាំង ទន្លេ រីងទឹកអស់ ។ សត្វនិងរុក្ខជាតិទាំងឡាយងាប់អស់ជាច្រើន ។

ពួកសត្វនិងរុក្ខជាតិមានហ៊ឹង កង្កែប គីង្គក់ ត្រីតូចធំ សត្វល្អិត ឃ្មុំ ជាដើម កើតការខឹងនឹងតាព្រហ្ម ដែលមិនបង្អុរទឹកភ្លៀង ។ សត្វទាំងនោះបានប្រមូលកម្លាំងឡើងទៅច្បាំងនឹងតាព្រហ្ម ។ គីង្គក់បានបញ្ជាកងទ័ពចូលវាយបំបែក ខាំទិច និងចងពួកមន្ត្រីសេនារបស់តាព្រហ្ម ។ ពលសេនាទាំងនោះភ័យស្លន់ស្លោរត់អស់ ។ តាព្រហ្មសារភាពសុំចុះចាញ់ ហើយសន្យាថានឹងផ្ដល់ទឹកភ្លៀងឱ្យ ។

តាំងពីកាលនោះមក នៅពេលដែលពួសត្វគីង្គក់ ហ៊ឹង កង្កែប ...ស្រែក ភ្លៀងក៏ធ្លាក់មក ។

## ការរៀនពាក្យ

### ក. អំណានពាក្យ

រុក្ខជាតិ អានថា រុក-ខៈ-ជាតិ

បង្គុរ អានថា បង់-អោ

តាព្រហ្ម អានាថា តា-ព្រំ

មន្ត្រី អានថា មន់-ត្រី

សេនា អានថា សេ-ណា

### ខ. ពន្យល់ពាក្យ

រុក្ខជាតិ : ដើមឈើគ្រប់យ៉ាង ។

បង្គុរ : ធ្លាក់ភ្លៀង ។

តាព្រហ្ម : ទេវតាដែលកើតនៅឋានលើ ។

មន្ត្រី : អ្នកធ្វើការងារបម្រើរដ្ឋ ។

ពលសេនា : ពួកទាហាន ពួកពល កងទ័ព ។

### គ. ពាក្យផ្ទុយ

ក្ដៅ ≠ ត្រជាក់ ចាញ់ ≠ ឈ្នះ

## សំណួរ

១. តើពួកសត្វអ្វីខ្លះដែលឡើងទៅច្បាំងនឹងតាព្រហ្ម ? ហេតុអ្វី ?

២. តើអ្នកណាជាអ្នកបញ្ជាកងទ័ព ?

៣. តើចម្បាំងនេះ ខាងណាជាអ្នកឈ្នះ ? ហេតុអ្វី ?

៤. តើតាព្រហ្មសន្យាដូចម្ដេច ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| កង្កែប | គីង្គក់ | តាព្រហ្ម | មន្ត្រី | ទ័ព |
| សេនា | ស្លន់ស្លោ | កម្លាំង | សារភាព | ជោគជ័យ |

ខ. ចូរស្រង់ពាក្យដែលកើតឡើងពីព្យាង្គតម្រួតនៅក្នុងអត្ថបទខាងលើ ។

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ កន្សោមពាក្យ និងល្បះខាងក្រោម ។

រុក្ខជាតិ ខឹងសម្បារ បង្អុរ ស្លន់ស្លោ តាព្រហ្ម
កាលពីព្រេងនាយ ពិភពលោកកើតភាពរាំងស្ងួត ក្ដៅហួតហែងគ្មានទឹកភ្លៀងសោះ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| បញ្ជា | មន្ត្រីសេនា | ស្រែក | ចាញ់ | ពលសេនា | ប្រមូលកម្លាំង |

១. សត្វទាំងនោះ បាន ...ឡើងច្បាំងនឹងតាព្រហ្ម ។
២. គីង្គក់បាន ...កងទ័ពចូលវាយ ខាំ ទិច និងចាប់ចង ...របស់តាព្រហ្ម ។
៣. ...ទាំងនោះ ភ័យស្លន់ស្លោរត់អស់ ។
៤. តាព្រហ្ម សារភាពសុំចុះ ...ហើយសន្យាថានឹងផ្ដល់ទឹកភ្លៀងឱ្យ ។
៥. តាំងពីកាលនោះមក នៅពេលពួសត្វគីង្គក់ ហ៊ីង កង្កែប ...ភ្លៀងក៏ធ្លាក់មក ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "សារភាព" ។

*រយៈពេល ០៨ ម៉ោងសិក្សា*

មេរៀនទី
៧១

# រឿងដង្កូវនិងក្អែក

## អំណាន



មានសត្វដង្កូវមួយកំពុងស៊ីស្លឹកឈើ ។ ពេលនោះ មានសត្វក្អែកមួយហើរមកបម្រុងនឹងស៊ីដង្កូវនោះ ។ ដង្កូវមានប្រាជ្ញាក៏ដាក់ប្រស្នាឱ្យក្អែកដោះស្រាយ ។ បើក្អែកដោះប្រស្នាមិនរួច មិនអាចស៊ីវាបានទេ ។ ដង្កូវដាក់ប្រស្នា ៖ "តើអ្វីដែលផ្អែម ក្រអូប ជូរ និងស្អុយជាងគេ ?" ។ ក្អែកឆ្លើយ ៖ "អ្វីដែលផ្អែមជាងគេគឺស្ករទឹកឃ្មុំ អ្វីដែលជូរជាងគេគឺក្រូចឆ្មារ ក្រអូបជាងគេគឺផ្កា ទឹកអប់ និងស្អុយជាងគេគឺលាមក ឬអាចម៍ " ។ បន្ទាប់មក ដង្កូវឆ្លើយបដិសេធវិញថា មិនត្រូវទេ អ្វីដែលផ្អែមជាងគេនោះគឺ សម្ដីល្អ ពីរោះ ជូរគឺពាក្យទ្រគោះបោះបោក ស្អុយជាងគេគឺ កេរ្តិ៍ឈ្មោះមិនល្អ និងក្រអូបនោះគឺកេរ្តិ៍ឈ្មោះដែលល្អប្រពៃ ។

ដោយទាល់ប្រាជ្ញា ក្អែកក៏ចុះចាញ់ខានបានស៊ីដង្កូវ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ប្រាជ្ញា អានថា ប្រាច-ញ៉ា

លាមក អានថា លា-មក់

អាចម៍ អានថា អាច់

កេរ្តិ៍ អានថា កេ

ខ. ពន្យល់ពាក្យ

ប្រស្នា : ចំណោទ ។

បដិសេធ : មិនយល់ព្រម លែងយកជាការ ។

កេរ្តិ៍ : សេចក្ដីសរសើរ ការល្បី ។

គ. ពាក្យន័យដូចនឹងពាក្យ "ទ្រគោះ"

ទ្រគោះ បោះបោក គំរោះគំរើយ

ឃ. ពាក្យផ្ទុយ

ស្អុយ ≠ ក្រអូប ខុស ≠ ត្រូវ

## សំណួរ

១. ហេតុអ្វីបានជាដង្កូវចោទប្រស្នាដល់ក្អែក ?

២. តើដង្កូវបានដាក់ប្រស្នាអ្វីខ្លះដល់ក្អែក ?

៣. តើក្អែកឆ្លើយដោះប្រស្នារបស់ដង្កូវយ៉ាងដូចម្ដេច ?

៤. តើក្អែកបានស៊ីដង្កូវឬទេ ? ព្រោះអ្វី ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទួននិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ប្រស្នា | លាមក | បដិសេធ | ប្រាជ្ញា | សត្វ | កេរ្តិ៍ឈ្មោះ | ដង្កូវ | ជួរចត់ |

ខ. ចូរអានល្បះនីមួយៗ រួចបង់លេខក្នុងប្រអប់តាមលំដាប់លំដោយដំណើររឿង ។

- ☐ ពេលនោះសត្វក្អែកហើរមកបម្រុងនឹងស៊ីដង្កូវ ។
- ☐ ដង្កូវឆ្លើយបដិសេធថាមិនត្រូវទេ ។
- ☐ មានសត្វដង្កូវមួយកំពុងស៊ីស្លឹកឈើ ។
- ☐ ដង្កូវមានប្រាជ្ញាក៏ដាក់ប្រស្នាឱ្យក្អែកដោះស្រាយ ។

## សំណេរ

ក. ចូរសរសេរតាមអានរៀបចំអត្ថបទខាងក្រោម ។

### រឿងដង្កូវនិងក្អែក

មានសត្វដង្កូវមួយកំពុងស៊ីស្លឹកឈើ ។ ពេលនោះ មានសត្វក្អែកមួយហើរមកបម្រុងនឹងស៊ីដង្កូវនោះ ។ ដង្កូវមានប្រាជ្ញាក៏ដាក់ប្រស្នាឱ្យក្អែកដោះស្រាយ ។ បើក្អែកដោះប្រស្នាមិនរួច មិនអាចស៊ីវាបានទេ ។ ដោយភាពល្ងីតល្ងង់ ក្អែកមិនអាចដោះប្រស្នារួចឡើយ ហើយក៏ខានបានស៊ីដង្កូវនោះទៅ ។

## សំណួរ

១. តើក្អែកបម្រុងស៊ីសត្វអ្វី ?

២. តើដង្កូវធ្វើដូចម្ដេច ?

៣. តើក្អែកបានស៊ីដង្កូវឬទេ ? ព្រោះអ្វី ?

## លំហាត់

១. ចូរពន្យល់ពាក្យ “កេរ្តិ៍”

២. ចូររកពាក្យន័យដូចនឹងពាក្យ “ទ្រគោះ”

៣. ចូររកពាក្យផ្ទុយនឹងពាក្យ “ស្អុយ”

ខ. ចូរបំពេញល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ ។



១. ដង្កូវកំពុង ............... ។



២. ក្អែកទំលើ ................. ។



៣. ឃ្មុំកំពុង .................. ។

មេរៀនទី ៧២

# ច្បារដំណាំ

## មេសូត្រ



(បទកាកគតិ)

រាល់ល្ងាចម៉ោងប្រាំ តាមខ្ញុំចំណាំ ប៉ាចូលក្នុងច្បារ
ស្រោចទឹកបោចស្មៅ ដង្កូវនានា បេះចេញពីផ្កា
មិនឱ្យសល់មួយ ។

ត្រសក់និងល្ពៅ ម្ទេសត្រប់ឥឡូវ កំពុងបែកត្រួយ
ត្រឡាចឡើងទ្រើង ចេញផ្កាមួយៗ ទងងើបបោះពួយ
ដណ្ដើមទីគ្នា ។

ប៉ាជ្រំជ្រួយដី ខ្ញុំទាញបានល្អី រូតរះម្ទឹម្ទា
រត់រកកើបដី អាចម៍មាន់អាចម៍ទា អាចម៍គោរួមគ្នា
ដាក់ច្បារដំណាំ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ឥឡូវ អានថា អី-ឡូវ

ខ. ពន្យល់ពាក្យ

ច្បារ : សួនដំណាំ ទីដីដែលដាំបន្លែ ។

គ. ពាក្យន័យដូចនឹងពាក្យ "រួតរះ" ។

រួតរះ ម៉ឺម៉ា រវៀស ប្រញាប់ រួសរាន់

ឃ. ពាក្យផ្ទុយ

រួម ≠ បែក ឡើង ≠ ចុះ

## សំណួរ

១. តើវាល់ល្ងាចប៉ាធ្វើអ្វីក្នុងច្បារ ?

២. តើនៅក្នុងច្បារមានដំណាំអ្វីខ្លះ ?

៣. តើគេប្រើដីអ្វីខ្លះ សម្រាប់ដាក់ដំណាំ ?

៤. តើគេជួយធ្វើការអ្វីខ្លះ ក្នុងច្បារ ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទួំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ដង្កូវ ផ្លែផ្កា ចិញ្ចឹម ស្រោចទឹក ល្អី ច្បារ ដណ្ដើម ជ្រួយ

ខ. ចូរគូសរង្វង់ជុំវិញពាក្យណាដែលជាក្រុមបន្លែ ។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ដង្កូវ | ត្រឡាច | សាច់ | ទឹក | ននោង | ត្រី | ល្ពៅ | ម្រះ | |
| ទឹកខ្មេះ | ផ្ទី | ប្រហុក | ជីរ | ត្រសក់ | ស្ពរ | ស្ពៃ | ខាត់ណា | ស្លា |

## សំណេរ

ក. ចូរសរសេរតាមអានរៀបចំវគ្គមេសូត្រខាងក្រោម ។

### ច្បារដំណាំ

ប៉ាជ្រំជ្រួយដី ខំទាញបានល្អី រូតរះម្ទីម្នា
រត់រកកើបដី អាចម៍មាន់អាចម៍ទា អាចម៍គោរួមគ្នា
ដាក់ច្បារដំណាំ ។

## សំណួរ

១. តើយើងត្រូវសម្អាតខ្លួនប្រាណយ៉ាងដូចម្តេច ?

២. ហេតុអ្វីបានជាយើងត្រូវលាងដៃមុនពេលបរិភោគអាហារ ?

៣. តើការសម្អាតខ្លួនប្រាណមានប្រយោជន៍អ្វី ?

## លំហាត់

១. ចូរពន្យល់ពាក្យ "ច្បារ" ។

២. ចូររកពាក្យន័យដូចនឹងពាក្យ "រូតរះ" ។

៣. ចូររកពាក្យផ្ទុយនឹងពាក្យ "រួម" ។

ខ. ចូរតែងល្បះនឹងពាក្យខាងក្រោម ។

១. សម្អាត : ................................ ។

២. បរិភោគ : ................................ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "សុខភាព" ។

មេរៀនទី
៧៣

# ផ្សារភូមិខ្ញុំ

## អំណាន



ផ្សារនៅភូមិខ្ញុំតូចល្មម ប៉ុន្តែមានលក់ទំនិញគ្រប់មុខស្របតាមតម្រូវការរបស់អ្នកភូមិ ។

ផ្សារនេះធំជាងផ្សារនៅឯភូមិមួយទៀតបន្តិច មានតូបលក់ដូរច្រើនជាងនិងមានទំនិញច្រើនមុខងាយស្រួលរកទិញ ។ ទំនិញភាគច្រើនមាន ត្រី សាច់ និងបន្លែជាដើម គេលក់ក្នុងតម្លៃថោក ព្រោះគេនាំយកមកពីកន្លែងជិតៗនៅក្នុងភូមិ ។ អ្នកភូមិខ្ញុំមិនចំណាយពេលវេលាច្រើនទេ សម្រាប់ធ្វើដំណើរទៅទិញទំនិញ ព្រោះផ្សារនៅជិតផ្ទះ ។

ខ្ញុំចូលចិត្តទៅផ្សារនៅភូមិខ្ញុំនេះណាស់ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

បន្លែ អានថា បន់-ល៉ែ

តម្រូវ អានថា តំ-រ៉ូវ

ខ. ពន្យល់ពាក្យ

ទំនិញ : អ្វីៗដែលសម្រាប់ឱ្យគេទិញ ។

អ្នកភូមិ : មនុស្សនៅក្នុងភូមិ ។

គ. ពាក្យផ្ទុយ

ថោក ≠ ថ្លៃ តូច ≠ ធំ

## សំណួរ

១. តើផ្សារនៅភូមិនោះតូចឬធំ ?

២. តើផ្សារនៅភូមិនោះមានលក់អ្វីខ្លះ ?

៣. ហេតុអ្វីបានជាទំនិញនៅផ្សារនោះមានតម្លៃថោក ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោម ដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| ទំនិញ | តម្រូវការ | កន្លែង | ភាគច្រើន | អ្នកភូមិ | សម្រាប់ | ផ្សារ | តម្លៃ |
|---|---|---|---|---|---|---|---|

ខ. ចូរគូសរង្វង់ជុំវិញពាក្យណាដែលជាក្រុមពាក្យសត្វផ្តល់សាច់ ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| គោ | ស្លែក្តោប | ប្រហិត | ដំឡូង | ត្រី | ត្រកួន | ក្តាម | |
| បង្កង | ត្រាវ | បង្គា | មាន់ | ទា | ម្នាស់ | មឹក | ជ្រូក |

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ កន្សោមពាក្យ និងល្បះខាងក្រោម ។

ទំនិញ តម្រូវការ កន្លែង ភាគច្រើន អ្នកភូមិ

ផ្សារនៅភូមិខ្ញុំតូចល្មម ប៉ុន្តែមានលក់ទំនិញគ្រប់មុខ ស្របតាមតម្រូវការរបស់អ្នកភូមិ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| ធំជាង | ចូលចិត្ត | ទំនិញ | ចំណាយ | ច្រើនជាង | ទិញ |

១. ផ្សារនៅភូមិខ្ញុំតូចល្មម ប៉ុន្តែមានលក់ .............. គ្រប់មុខ ។

២. ផ្សារនេះ ...... ផ្សារនៅឯភូមិមួយទៀតបន្តិច មានតូបលក់ដូរ...... ។

៣. អ្នកភូមិខ្ញុំមិន .................. ពេលវេលាច្រើនទេ សម្រាប់ធ្វើដំណើរទៅ ....... ទំនិញ ។

៤. ខ្ញុំ ............ ទៅផ្សារនៅភូមិខ្ញុំនេះណាស់ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ “ចំណាយ” ។

# មេរៀនទី ៧៤ ការប្រៀបធៀបទីកន្លែងនិងវត្ថុ

## ការនិយាយ



បូរ៉ា : ថង! តើផ្សារនៅភូមិខ្ញុំ និងផ្សារនៅភូមិឯងខុសគ្នាដូចម្ដេចខ្លះ ?

ថង : អូ! ផ្សារនេះធំជាងផ្សារនៅភូមិខ្ញុំ ។ ទីនេះមានតូបលក់ដូរច្រើនជាង និងមានទំនិញច្រើនមុខងាយស្រួលរកទិញជាងផ្សារនៅភូមិខ្ញុំ ។ ប៉ុន្តែរបស់ខ្លះថ្លៃជាងផ្សារនៅភូមិខ្ញុំ ។

បូរ៉ា : តើទំនិញណាខ្លះដែលគេលក់ថោកជាងផ្សារនៅភូមិខ្ញុំ ?

ថង : អូ! ត្រី សាច់ និងបន្លែ គេលក់ថោកជាង ព្រោះគេនាំយកមកពីកន្លែងជិតៗនេះ ។

## សំណួរ

១. តើផ្សារនៅភូមិថងនិងផ្សារនៅភូមិប៉ូវ៉ាមួយណាធំជាង ?

២. តើកន្លែងលក់ដូររបស់ផ្សារទាំងពីរខុសគ្នាដូចម្ដេច ?

៣. តើផ្សារណាមានទំនិញច្រើនជាង ?

៤. តើថងថាទំនិញអ្វីខ្លះ នៅផ្សារភូមិខ្លួនថោកជាង ? ព្រោះអ្វី ?

## លំហាត់

ចូរប្រៀបធៀបផ្សារនៅភូមិអ្នកនិងផ្សារណាមួយដែលអ្នកធ្លាប់ស្គាល់ ។

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ កន្សោមពាក្យ និងល្បះខាងក្រោម ។

ធំជាង ច្រើនជាង ថោកជាង ងាយស្រួល

អូ ! ត្រី សាច់ និងបន្លែ គេលក់ថោកជាង ព្រោះគេនាំយកមកពីកន្លែងជិតៗនេះ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។

ច្រើនជាង | ថោកជាង | ធំជាង | ខុសគ្នា | ជិតៗ

១. ផ្សារនៅភូមិខ្ញុំនិងផ្សារនៅភូមិឯង .................... ។

២. ផ្សារនេះ ...........ផ្សារនៅភូមិខ្ញុំ ។ ទីនេះមានតូបលក់ដូរ ..........
និងមានទំនិញច្រើនមុខ ។

៣. ត្រី សាច់ និងបន្លែ គេលក់ ... ព្រោះគេនាំយកមកពីកន្លែង ... នេះ ។

មេរៀនទី
៧៥

# រឿងមេក្រួចនិងពស់

## អំណាន



ថ្ងៃមួយពេលភ្ញាក់ពីដំណេក មេក្រួចឃើញពស់មួយយ៉ាងធំ រុំព័ទ្ធជុំវិញសម្បុកវា។ មេក្រួចភ័យណាស់ ព្រោះឃើញពស់សម្លឹងមើលខ្លួនដោយក្តីស្រេកឃ្លាន។ មេក្រួចនិយាយ ៖ "សួស្តីបងពស់! ខ្ញុំរីករាយណាស់ដោយបានជួបបង។ បងមិន ដែលមកលេងខ្ញុំសោះ។ ដូច្នេះ ខ្ញុំនឹងធ្វើអាហារជូនបងពិសា។ ប៉ុន្តែគួរឱ្យស្តាយណាស់ អ្នកជិតខាងបានខ្ចីឆ្នាំងទៅបាត់។ ខ្ញុំនឹងប្រើកូន ឱ្យទៅយកមកវិញ"។ និយាយចប់ មេក្រួចកេះកូនឱ្យក្រោកឡើង ហើយហើរចេញទៅ។

ភ្លាមនោះមេក្រួចក៏ហើរពីសម្បុក រួចនិយាយ ៖ "លាសិនហើយ ថ្ងៃនេះបងនឹងមិនបានអាហារហូបទេ"។

ពស់ក៏វារទៅកាន់រន្ធវាវិញ ដោយក្តីស្រេកឃ្លាន។

## ការរៀនពាក្យ

ក. អំណានពាក្យ

ព័ទ្ធ អានថា ពាត់

រន្ធ អានថា រន់

សម្លឹង អានថា សំ-ឡឹង

ខ. ពន្យល់ពាក្យ

ព័ទ្ធ : រុំជុំវិញ ចោមជុំវិញ។

រន្ធ : រូង ប្រហោង រូងទាល់។

គ. ពាក្យន័យដូចនឹងពាក្យ "ជូន"

ជូន ឱ្យ ប្រគល់ ថ្វាយ ប្រគេន

ឃ. ពាក្យផ្ទុយ

ខ្ញី ≠ សង ស្រេកឃ្លាន ≠ ឆ្អែតឆ្អន់

## សំណួរ

១. តើមេក្រួចបានឃើញអ្វីនៅជិតសម្បុកវា ?

២. តើមេក្រួចប្រើល្បិចដូចម្ដេច ដើម្បីរំដោះខ្លួនឯងនិងកូន ?

៣. តើពស់បានស៊ីមេក្រួចនិងកូនក្រួចឬទេ ?

៤. តើអ្នកគួរយកតម្រាប់តាមមេក្រួចឬទេ ? ព្រោះអ្វី ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទុំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | | | |
|---|---|---|---|---|---|---|
| កន្លែង | រន្ធ | ស្រែកឃ្លាន | សួស្តី | សម្បុក | រុំព័ទ្ធ | សម្លឹង |

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ កន្សោមពាក្យ និងល្បះខាងក្រោម ។

កន្លែង រន្ធ ស្រែកឃ្លាន សួស្តី រុំព័ទ្ធ សម្លឹង

សួស្តីបងពស់! ខ្ញុំរីករាយណាស់ដោយបានជួបបង ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| ភ័យ | ពស់ | ផ្ទាំង | ហើរ | ស្រែកឃ្លាន | រន្ធ |

១. ពេលភ្ញាក់ពីដំណេក មេក្រួចឃើញ ............មួយយ៉ាងធំ ។

២. មេក្រួច ..........ខ្លាំងណាស់ រួចនិយាយទៅកាន់ពស់ ។

៣. ខ្ញុំនឹងប្រើវាឱ្យទៅយក ..............មកវិញ ។ ថាហើយក៏កេះកូនឱ្យ ..........ចេញទៅ ។

៤. ពស់ក៏វារទៅកាន់ ..............វិញ ដោយក្តី.............. ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ “និយាយ” ។

# មេរៀនទី ៧៦ ក្មេងសុចរិត

## អំណាន



ថ្ងៃអាទិត្យមុន សំណាងបានទៅផ្សារជាមួយម្ដាយ ។

សំណាងបានសុំម្ដាយទិញផ្លែមៀនកន្លះគីឡូក្រាមនិងចេកអំបូងមួយស្និត ។ អ្នកលក់ប្រាប់ថា មៀនមួយគីឡូក្រាមថ្លៃប្រាំពីរពាន់រៀល ឯចេកមួយស្និតថ្លៃពីរពាន់រៀល ។ ម្ដាយសំណាងហុចក្រដាសប្រាក់មួយម៉ឺនរៀលទៅអ្នកលក់ ។ គាត់ក៏អាប់លុយប្រាំពាន់ប្រាំរយរៀលមកវិញ ។ សំណាងប្រាប់អ្នកលក់ ៖ "អ៊ំស្រី អាប់លុយលើសមួយពាន់រៀលហើយ" ។ អ្នកលក់សើចហើយនិយាយ ៖ "អូ! អ៊ំច្រឡំ អរគុណហើយក្មួយ ។ ក្មួយជាក្មេងទៀងត្រង់ណាស់ ។"

ម្ដាយសំណាងសប្បាយចិត្តណាស់ ដោយមានកូនឆ្លាត និងចេះធ្វើអំពើល្អយ៉ាងនេះ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

សុចរិត អានថា សុ-ចៈ-រិុត

អាទិត្យ អានថា អា-ទិត

ខ. ពន្យល់ពាក្យ

សុចរិត : ការប្រព្រឹត្តល្អ ។

ស្និត : សំណុំផ្លែចេកដែលនៅជាប់នឹងស្ទង ឬដែលពន្លះចេញពីស្ទង មកមិនឱ្យរបេះដាច់ពីគ្នា ។

គ. ពាក្យន័យដូចនឹងពាក្យ "សុចរិត"

សុចរិត ទៀងត្រង់ ស្មោះត្រង់

ឃ. ពាក្យផ្ទុយ

សរសើរ ≠ បង្អាប់ សុចរិត ≠ ទុច្ចរិក

## សំណួរ

១. តើសំណាងទៅផ្សារជាមួយអ្នកណា ?

២. តើសំណាងបានសុំម្ដាយទិញអ្វីខ្លះ ?

៣. តើសំណាងធ្វើដូចម្ដេច នៅពេលឃើញអ្នកលក់អាប់លុយលើស ?

៤. តើអ្នកគិតថា សំណាងជាក្មេងដូចម្ដេច ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

អាទិត្យ ម្ដាយ សុចរិត មៀន គីឡូក្រាម ក្រដាស ទៀងត្រង់ ស្និត

## សំណេរ

ក. ចូរសរសេរតាមអានរៀបចំអត្ថបទខាងក្រោម ។

### ក្មេងសុចរិត

ថ្ងៃអាទិត្យមុន សំណាងបានទៅផ្សារជាមួយម្ដាយ ។ សំណាងបានសុំម្ដាយទិញផ្លែមៀនកន្លះគីឡូក្រាមនិងចេកអំបូងមួយស្និត ។ ម្ដាយសំណាងហុចក្រដាសប្រាក់មួយម៉ឺនរៀលទៅអ្នកលក់ ។ អ្នកលក់ក៏អាប់លុយលើសមួយពាន់រៀល ។ ពេលនោះ សំណាងក៏ប្រាប់អ្នកលក់ ។ អ្នកលក់សរសើរថា សំណាងជាក្មេងសុចរិតណាស់ ។

សំណួរ

១. តើសំណាងបានសុំម្ដាយទិញអ្វីខ្លះ ?

២. តើសំណាងប្រាប់អ្នកលក់ដូចម្ដេច ?

៣. តើអ្នកលក់សរសើរសំណាងដូចម្ដេច ?

លំហាត់

១. ចូរពន្យល់ពាក្យ "ស្និត" ។

២. ចូររកពាក្យន័យដូចនឹងពាក្យ "សុចរិត" ។

៣. ចូររកពាក្យផ្ទុយនឹងពាក្យ "សរសើរ" ។

ខ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "សុចរិត" ។

មេរៀនទី
៧៧

# ជីដូនជីតា

## អំណាន



ជីដូនជីតាខ្ញុំ មានវ័យចាស់ជរាណាស់ទៅហើយ ។

ព្រឹកនេះ ម្ដាយឪពុកខ្ញុំនិងខ្ញុំយកនំចំណី ផ្លែឈើទៅជូនគាត់ ។ យើងសប្បាយរីករាយណាស់នៅពេលទៅដល់ផ្ទះគាត់ ព្រោះបានជួបលោកទាំងពីរ ។ គាត់បានអង្អែលនិងឱបខ្ញុំ ។ គាត់សាកសួរអំពីការរៀនសូត្ររបស់ខ្ញុំ ។ ជីដូនជីតាខ្ញុំមានវ័យចំណាស់បន្តិចមែន តែសុខភាពគាត់នៅមាំមួនល្អ ៕

ខ្ញុំគោរពស្រឡាញ់ជីដូនជីតាខ្ញុំណាស់ ព្រោះគាត់តែងទូន្មានខ្ញុំឱ្យខិតខំរៀនសូត្រនិងធ្វើខ្លួនជាកូនល្អ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ជរា អានថា ជៈ-រា

វ័យ អានថា វៃ

សូត្រ អានថា សូត

ខ. ពន្យល់ពាក្យ

ជរា : ចំណាស់ សេចក្ដីគ្រាំគ្រា ទ្រុឌទ្រោម ។

វ័យ : អាយុ កំណត់អាយុ ។

គ. ពាក្យន័យដូចនឹងពាក្យ "ជរា"

ជរា ចាស់ ចំណាស់ ទ្រុឌទ្រោម

ឃ. ពាក្យផ្ទុយ

មាំមួន ≠ ទន់ខ្សោយ សួរ ≠ ឆ្លើយ

សំណួរ

១. តើជីដូនជីតាគេមានវ័យដូចម្ដេច ?

២. តើម្ដាយឪពុកគេយកអ្វីទៅជូនជីដូនជីតា ?

៣. តើជីដូនជីតាសាកសួរគេអំពីអ្វី ?

៤. ហេតុអ្វីបានជាគេគោរពស្រឡាញ់ជីដូនជីតា ?

លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| ជីដូនជីតា | ជរា | ម្ដាយឪពុក | អង្អែល | មាំមួន |
| ឱប | វ័យ | ចំណាស់ | ទូន្មាន | ស្រឡាញ់ |

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ និងល្បះខាងក្រោម ។

ជរា អង្អែល មាំមួន ឱប វ័យ

ជីដូនជីតាខ្ញុំមានវ័យចំណាស់បន្តិចមែន តែសុខភាពគាត់នៅមាំមួនល្អ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបាន ត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| ព្រោះ | វ័យ | គោរព | ព្រឹកនេះ | ជរា |

១. ជីដូនជីតាខ្ញុំមានវ័យចាស់ .........ណាស់ទៅហើយ ។

២. ......ម្ដាយឪពុកខ្ញុំនិងខ្ញុំ យកនំចំណី ផ្លែឈើទៅជូនគាត់ ។

៣. ជីដូនជីតាខ្ញុំ មាន .............ចំណាស់បន្តិចក្តី តែសុខភាពគាត់នៅមាំមួនល្អ ។

៤. ខ្ញុំ ............ស្រឡាញ់ជីដូនជីតាខ្ញុំណាស់ .........គាត់តែងទូន្មានខ្ញុំឱ្យខិតខំរៀនសូត្រ ។

គ. ចូរតែងល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ ។



.......................... ។



.......................... ។

មេរៀនទី ៧៨

# សេចក្ដីជូនដំណឹង

## អំណាន



ថ្ងៃមួយ វីតានិងម្ដាយបានចូលរួមប្រជុំ ស្ដាប់មេភូមិប្រកាសដំណឹងនៅស្នាក់ការភូមិ ។

រដូវនេះមានបុណ្យទានច្រើន បងប្អូនតែងតែរៀបចំម្ហូបអាហារទៅវត្ត ។ ប៉ុន្តែសូមប្រុងប្រយ័ត្នសាច់មាន់ ទា ដែលយកមកធ្វើម្ហូបត្រូវ ៖

១. កុំយកមាន់ ទា មានជំងឺមកធ្វើម្ហូប ។

២. ពេលធ្វើមាន់ ទា ត្រូវពាក់ម៉ាស់ការពារជានិច្ច ។

៣. សម្អាតដៃនិងសម្ភារៈប្រើប្រាស់ជាមួយសាប៊ូឱ្យបានស្អាត ។

៤. ចម្អិនសាច់ដែលត្រូវធ្វើម្ហូបឱ្យបានឆ្អិនល្អ ។ យើងទាំងអស់គ្នាធ្វើបែបនេះ មិនឆ្លងជំងឺផ្ដាសាយបក្សីទេ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ប្រយ័ត្ន អានថា ប្រ-យ៉ាត់

បក្សី អានថា ប័ក-សី

សម្ភារៈ អានថា សំ-ភា-រាក់

ចម្អិន អានថា ចំ-អិន

ខ. ពន្យល់ពាក្យ

ប្រយ័ត្ន : ការប្រុងដោយមិនធ្វេសប្រហែស ។

សម្ភារៈ : គ្រឿងប្រើប្រាស់ ។

បក្សី : សត្វមានស្លាប ។

គ. ពាក្យន័យដូចនឹងពាក្យ "ប្រកាស"

ប្រកាស ប្រាប់ ផ្សព្វផ្សាយ ជូនដំណឹង

ឃ. ពាក្យផ្ទុយ

ឆ្អិន ≠ ឆៅ ប្រយ័ត្ន ≠ ធ្វេសប្រហែស

## សំណួរ

១. តើនរណាជាអ្នកប្រកាសដំណឹង ?

២. តើគាត់ប្រកាសដំណឹងប្រាប់នរណាខ្លះ ?

៣. តើគាត់ប្រកាសឱ្យប្រុងប្រយ័ត្នដូចម្ដេចខ្លះ ?

៤. ហេតុអ្វីបានជាគាត់ប្រកាសដំណឹងនេះ ?

លំហាត់

ចូរនិយាយរៀបរាប់ឡើងវិញ សេចក្តីប្រកាសរបស់នាយកសាលាអំពី

១. ការឈប់សម្រាកនៅថ្ងៃបុណ្យ

២. ការធ្វើពលកម្មនៅសាលារៀន ។

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យ កន្សោមពាក្យ និងល្បះខាងក្រោម ។

| | | | | |
|---|---|---|---|---|
| មាន់ទា | ផ្កាសាយបក្សី | ម្ហូបអាហារ | សម្ភារៈ | ពាក់ម៉ាស់ |

រដូវនេះមានបុណ្យទានច្រើន បងប្អូនតែងតែរៀបចំម្ហូបអាហារទៅវត្ត ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោម ។

| | | | | | |
|---|---|---|---|---|---|
| មាន់ទា | ផ្កាសាយបក្សី | ម្ហូបអាហារ | សម្ភារៈ | ឆ្អិន | ពាក់ម៉ាស់ |

១. រដូវនេះមានបុណ្យទានច្រើន បងប្អូនតែងតែរៀបចំ ..........ទៅវត្ត ។ ប៉ុន្តែសូមប្រុងប្រយ័ត្នសាច់មាន់ ទាដែលត្រូវយកមកធ្វើម្ហូប ។

២. កុំយក ....... មានជំងឺមកធ្វើម្ហូប ។ ពេលធ្វើមាន់ទា ត្រូវ ........... ការពារជានិច្ច ។

៣. សម្អាតដៃ និង ............ ប្រើប្រាស់ជាមួយសាប៊ូឱ្យបានស្អាត ។ ចម្អិនសាច់ដែលត្រូវធ្វើម្ហូបឱ្យបាន ........ ល្អ ។

៤. យើងទាំងអស់គ្នាធ្វើបែបនេះ មិនឆ្លងជំងឺ ............ទេ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "ការពារ" ។

មេរៀនទី ៧៩

# រឿងសត្វត្មាត

## អំណាន



កាលពីព្រេងនាយ មានត្មាតមួយគ្រួសាររស់នៅលើភ្នំ ។

ត្មាតម្ដាយនិងឪពុកចាស់ជរា ពុំអាចហើរបានឡើយ ។ ត្មាតកូនតែងហើរទៅរកចំណីមកចិញ្ចឹម ។ ថ្ងៃមួយ កូនត្មាតហើររកចំណីក៏បានជាប់អន្ទាក់ព្រាន ។ ព្រានបម្រុងនឹងសម្លាប់តែកូនត្មាតអង្វរ ៖ “ឱ ! បងព្រានសូមបងកុំសម្លាប់ខ្ញុំអី ! បើបងសម្លាប់ខ្ញុំដូចសម្លាប់ម្ដាយឪពុកខ្ញុំដែរ ព្រោះគាត់រស់ដោយសារខ្ញុំជាអ្នករកស៊ីចិញ្ចឹម” ។ សម្ដីនេះធ្វើឱ្យព្រានពិចារណា ៖ “ឱ ! ខ្ញុំអើយ ខំរកស៊ីសព្វថ្ងៃពុំដែលបានជួយម្ដាយឪពុកជរារបស់ខ្ញុំសោះ” ។

ព្រានគិតហើយក៏លែងត្មាតទៅវិញ រួចតាំងចិត្តចិញ្ចឹមម្ដាយឪពុកដូចសត្វត្មាតដែរ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ចិញ្ចឹម អានថា ចិញ-ចឹម

សម្លាប់ អានថា សំ-ឡាប់

ខ. ពន្យល់ពាក្យ

សម្លាប់ : ធ្វើឱ្យស្លាប់ បំបាត់ជីវិត ផ្តាច់ជីវិត ។

ពិចារណា : ការត្រិះរិះ រំពឹងគិត ការគិតហ្មត់ចត់ ។

គ. ពាក្យន័យដូចនឹងពាក្យ "សម្លាប់"

សម្លាប់ ពិឃាដ ធ្វើគត ប្រល័យ ប្រហារ

ឃ. ពាក្យផ្ទុយ

អង្ករ ≠ សម្លុត ជរា ≠ មាំមួន

## សំណួរ

១. តើត្មាតរស់នៅឯណា ?

២. តើឪពុកម្តាយត្មាតមានវ័យដូចម្តេច ?

៣. តើអ្នកណារកស៊ីចិញ្ចឹមត្មាតម្តាយនិងឪពុក ?

៤. តើព្រានពិចារណាដូចម្តេចខ្លះ ក្រោយពីស្តាប់សម្តីត្មាត ?

៥. តើប្អូនត្រូវធ្វើដូចម្តេច ចំពោះឪពុកម្តាយប្អូន ពេលគាត់ចាស់ជរា ?

## លំហាត់

ចូរនិយាយសង្ខេបរឿង សត្វត្មាត ឡើងវិញ ។

## សំណេរ

ក. ចូរសរសេរតាមអានរៀបចំអត្ថបទខាងក្រោម ។

### រឿងសត្វត្មាត

ឱ ! បងព្រានសូមបងកុំសម្លាប់ខ្ញុំអី ! បើបងសម្លាប់ខ្ញុំដូចសម្លាប់ម្ដាយឪពុកខ្ញុំដែរ ព្រោះគាត់រស់ដោយសារខ្ញុំជាអ្នករកស៊ីចិញ្ចឹម ។ សម្ដីនេះធ្វើឱ្យព្រានពិចារណា ៖ "ឱ ! ខ្ញុំអើយ ខំរកស៊ីសព្វថ្ងៃពុំដែលបានជួយម្ដាយឪពុកជរារបស់ខ្ញុំសោះ" ។ ព្រានគិតហើយ ក៏លែងត្មាតទៅវិញ រួចតាំងចិត្តចិញ្ចឹមម្ដាយឪពុកដូចសត្វត្មាតដែរ ។

សំណួរ

១. ហេតុអ្វីបានជាសត្វត្មាតអង្វរព្រាន ?

២. ពេលបានស្ដាប់សម្ដីត្មាត តើព្រានធ្វើដូចម្ដេច ?

លំហាត់

១. ចូរពន្យល់ពាក្យ "ពិចារណា" ។

២. ចូររកពាក្យន័យដូចនឹងពាក្យ "សម្លាប់" ។

៣. ចូររកពាក្យផ្ទុយនឹងពាក្យ "ជរា" ។

ខ. ចូរតែងល្បះនឹងពាក្យខាងក្រោម ។

១. ចិញ្ចឹម : ........................................... ។

២. ម្ដាយឪពុក : ........................................... ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "ពិចារណា" ។

មេរៀនទី
៨០

# ថ្ងៃបុណ្យចូលឆ្នាំ

## អំណាន





ឆ្នាំថ្មីចូលនៅថ្ងៃទី១៣ ឬ១៤ ខែមេសា ។

គ្រប់ផ្ទះបានរៀបចំតុទទួលទេវតាឆ្នាំថ្មី ។ តាមផ្ទះមានការតុបតែងលម្អដោយផ្កាភ្ញី គោមពណ៌ និងភ្លើងចម្រុះពណ៌យ៉ាងស្រស់ស្អាត ។

ពេលព្រឹក មនុស្សម្នា ក្មេងចាស់ ប្រុសស្រី ជាច្រើនយកចង្ហាន់ទៅវត្ត ។ អ្នកខ្លះទូលល្អី ខ្លះយួរចានស្រាក់ ខ្លះទៀតយកនំចំណី ផ្លែឈើ ទៅប្រគេនព្រះសង្ឃ ។ នៅតាមវត្តនិងផ្ទះ គេនាំគ្នាលេងល្បែងប្រជាប្រិយយ៉ាងខ្ញៀវខ្ញារ ដូចជាបោះអង្គុញ លាក់កន្សែង ទាញព្រ័ត្រ ដណ្ដើមស្លឹកឈើ ចាប់កូនខ្លែងជាដើម ។ អ្នកខ្លះរាំកម្សាន្តយ៉ាងសប្បាយរីករាយ ។

បុណ្យចូលឆ្នាំថ្មី ជាបុណ្យប្រពៃណីរបស់ខ្មែរ ។ បុណ្យចូលឆ្នាំថ្មី ឆ្នាំណាក៏សប្បាយរីករាយដែរ ។

## ការរៀនពាក្យ

### ក. អំណានពាក្យ

ចង្ហាន់ អានថា ចង់-ហាន់

អង្គុញ អានថា អង់-គុញ

ប្រជាប្រិយ អានថា ប្រជា-ប្រី

ព្រ័ត្រ អានថា ព្រាត់

### ខ. ពន្យល់ពាក្យ

ចង្ហាន់ : អាហារសម្រាប់ព្រះសង្ឃ ។

ប្រជាប្រិយ : ដែលជាទីស្រឡាញ់ពេញចិត្តរបស់ប្រជាជន ។

### គ. ពាក្យន័យដូចនឹងពាក្យ "ខ្ញៀវខ្ញារ"

ខ្ញៀវខ្ញារ អ៊ូអរ អឹងកង កងរំពង

### ឃ. ពាក្យផ្ទុយ

ខ្ញៀវខ្ញារ ≠ ស្ងាត់ជ្រងំ ថ្មី ≠ ចាស់

## សំណួរ

១. តើបុណ្យចូលឆ្នាំខ្មែរចាប់ផ្តើមពីថ្ងៃណា ? ខែណា ?

២. តើនៅតាមផ្ទះនីមួយៗ គេរៀបចំតុបតែងលម្អអ្វីខ្លះ ?

៣. តើនៅតាមវត្តនិងផ្ទះ គេនាំគ្នាលេងល្បែងអ្វីខ្លះ ?

៤. នៅពេលបុណ្យចូលឆ្នាំថ្មី តើអ្នកចូលចិត្តធ្វើអ្វីដែរ ?

## លំហាត់

ចូររាប់ឈ្មោះល្បែងប្រជាប្រិយ ដែលគេចូលចិត្តលេងក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ។

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ កន្សោមពាក្យ និងល្បះខាងក្រោម ។

ទេវតា ឆ្នាំថ្មី ចង្ហាន់ ល្បែង ប្រជាប្រិយ

បោះអង្គញ់ ចោលឈូង ទាញព្រ័ត្រ លាក់កន្សែង ខ្មៅខ្វារ

តាមផ្ទះមានតុបតែងលម្អដោយផ្កាភ្ញី គោមពណ៌ និងភ្លើងចម្រុះពណ៌យ៉ាងស្រស់ស្អាត ។

ខ. ចូរតែងល្បះតាមរូបភាពនីមួយៗខាងក្រោម ឱ្យបានត្រឹមត្រូវ ។



........................ ។



........................ ។



........................ ។



........................ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "មេសា" ។

មេរៀនទី ៨១

# បុណ្យភ្ជុំបិណ្ឌ

## អំណាន



ពិធីបុណ្យភ្ជុំបិណ្ឌ ជាប្រពៃណីរបស់ប្រជាជនខ្មែរដែលមានរយៈពេល ១៥ថ្ងៃ ។

ចាប់ពីថ្ងៃ ១រោចដល់ថ្ងៃ ១៤រោច ខែភទ្របទ គេនាំគ្នាដាក់បិណ្ឌ ឬកាន់បិណ្ឌ ។ ក្នុងការកាន់បិណ្ឌ អ្នកស្រុកចែកគ្នាជាក្រុមដាក់វេន ធ្វើចង្ហាន់ទៅប្រគេនព្រះសង្ឃនៅឯវត្ត ។ នៅថ្ងៃទី ១៥រោច គេធ្វើពិធីបុណ្យភ្ជុំបិណ្ឌនៅវត្ត ។ ពេលនោះ មានមនុស្សច្រើនកុះករមកជួបជុំគ្នាច្រើនជាងថ្ងៃដាក់បិណ្ឌ ។ គេបានយកចង្ហាន់ នំចំណី ផ្លែឈើ តែ ស្ករ និងវត្ថុផ្សេងៗទៀតទៅប្រគេនព្រះសង្ឃ និងរាប់បាត្រ ដើម្បីបញ្ជូនកុសលដល់ញាតិដែលបានចែកឋានទៅ ។

ប្រជាជនខ្មែរ តែងធ្វើពិធីបុណ្យភ្ជុំបិណ្ឌយ៉ាងខ្ជាប់ខ្ជួនជារៀងរាល់ឆ្នាំ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ភ្ជុំបិណ្ឌ អានថា ភ្ជុំ-បិន

ភត្រុបទ អានថា ភ័ត-ទ្រៈ-បុត

កុសល អានថា កុ-សល់

ព្រះសង្ឃ អានថា ព្រះ-សង់

ខ. ពន្យល់ពាក្យ

បិណ្ឌ : ការប្រមូលឱ្យមូល ឬពូតជាដុំ ។

កុសល : ដែលកម្ចាត់បង់នូវអំពើអាក្រក់ ។

គ. ពាក្យន័យដូចនឹងពាក្យ "ចែកឋាន"

ចែកឋាន ស្លាប់ ងាប់ មរណៈ អនិច្ចកម្ម

ឃ. ពាក្យផ្ទុយ

កុសល ≠ អកុសល បុណ្យ ≠ បាប

## សំណួរ

១. តើការដាក់បិណ្ឌចាប់ផ្ដើមពីថ្ងៃណាដល់ថ្ងៃណា ? ខែណា ?

២. តើថ្ងៃណា ជាថ្ងៃភ្ជុំបិណ្ឌ ?

៣. នៅថ្ងៃភ្ជុំបិណ្ឌ តើមនុស្សម្នាទាំងឡាយធ្វើអ្វីខ្លះ ?

៤. តើអ្នកធ្វើអ្វីខ្លះ នៅថ្ងៃភ្ជុំបិណ្ឌ ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទួំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ព្រះសង្ឃ ភ្ជុំបិណ្ឌ កុសល ប្រពៃណី ភត្រុបទ ចង្ហាន់ ចែកឋាន បាត្រ ញាតិ

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យ និងល្បះខាងក្រោម ។

ចង្ហាន់ ព្រះសង្ឃ បាត្រ កុសល ញាតិ ចែកឋាន

ពិធីបុណ្យភ្ជុំបិណ្ឌ ជាប្រពៃណីរបស់ប្រជាជនខ្មែរ ដែលមានរយៈពេល ១៥ថ្ងៃ ។ ចាប់ពីថ្ងៃ ១រោចដល់ថ្ងៃ ១៤រោចខែភទ្របទគេនាំគ្នាកាន់បិណ្ឌ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញអត្ថបទខាងក្រោម ។

ចង្ហាន់ | ភ្ជុំបិណ្ឌ | ប្រគេន | ភទ្របទ | កុះករ | កុសល

ចាប់ពីថ្ងៃ ១រោច ដល់ថ្ងៃ ១៤រោចខែ ....គេនាំគ្នាដាក់បិណ្ឌ ឬកាន់បិណ្ឌ ។ ក្នុងការកាន់បិណ្ឌ អ្នកស្រុកចែកគ្នាជាក្រុមដាក់វេនធ្វើ...ទៅប្រគេនព្រះសង្ឃនៅឯវត្ត ។ នៅថ្ងៃទី ១៥រោច គេធ្វើពិធីបុណ្យ...នៅឯវត្ត ។ ពេលនោះមានមនុស្សច្រើន ...មកជួបជុំគ្នាច្រើនជាងថ្ងៃកាន់បិណ្ឌ ។ គេបានយកចង្ហាន់ នំចំណី ផ្លែឈើ តែ ស្ករ និងវត្ថុផ្សេងៗទៀតទៅ...ព្រះសង្ឃ ។ អ្នកទាំងនោះនាំគ្នាប្រគេនចង្ហាន់ព្រះសង្ឃ រាប់បាត្រ ដើម្បីបញ្ជូន ......ដល់ញាតិដែលបានចែកឋានទៅ ។

គ. ចូរតែងល្បះតាមរូបខាងក្រោមឱ្យបានត្រឹមត្រូវ ។



១. ............. ។



២. ............... ។

ឃ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ “ចំណី”

# បទានុក្រម

## ក

| | | |
|---|---|---|
| កន្ទិប | (ន.) | : ឈ្មោះម្ជុកមួយយ៉ាង ដែលមនុស្សកាន់សាសនាមហាម៉ាត់ពាក់ ។ |
| កន្ទើយ | (កិ.វិ. ឬគុ.) | : ព្រងើយ មិនយកចិត្តទុកដាក់ ។ |
| កន្ទ្រល | (គុ.) | : រល ននលមិនសមរម្យ ។ |
| កម្ចី | (គុ. ឬន.) | : អ្វីដែលនៅខ្ចី ការឱ្យខ្ចី ។ |
| កម្រាល | (ន.) | : របស់សម្រាប់ក្រាល ឧ.កម្រាលព្រំ ។ |
| កសិកម្ម | (ន.) | : ការធ្វើស្រែ ចម្ការ ចិញ្ចឹមសត្វ ។ |
| កសិករ | (ន.) | : អ្នកធ្វើស្រែ ចម្ការ ។ |
| កាកគតិ | (ន.) | : ឈ្មោះបទកាព្យពាក្យ ៤(បទដំណើរក្អែកលោត) ។ |
| កាយា | (ន.) | : រូប ខ្លួន ។ |
| ការស្នូត្រ | (កិ.) | : មូរសរសៃស្នូត្រ សរសៃអំបោះជាដើមដោយខ្នារ ។ |
| កុដិ | (ន.) | : ខ្ទម ផ្ទះ ឬលំនៅរបស់អ្នកបួស ។ |
| កុសល | (ន.) | : ដែលកម្ចាត់បង់នូវអំពើអាក្រក់ ។ |
| កេរ | (ន.) | : ដំណែល ជាសម្បត្តិរបស់ដូនតា ។ |
| កេរ្តិ៍ | (ន.) | : សេចក្តីសរសើរ ការល្បី ការល្បីលេចឮ ខ្ចរខ្ចារ ។ |
| ក្តារងឿ | (ន.) | : ក្តារក្រាស់បន្ទះធំៗពីរ ឬបីសន្លឹកតម្រៀបភ្ជិតគ្នាលើជើងម៉ាទម្រ ។ |
| ក្រហេងក្រហូង | (ន.) | : ក្រហូងតូច ធំ ខ្ពស់ ទាប ។ |
| ក្រឌីឈូក | (ន.) | : ខ្នែងដែលបែកចេញពីមើមឈូក ។ |
| ក្ស័យ | (ន.) | : សេចក្តីស្លាប់ ការបាត់បង់ សេចក្តីវិនាស ។ |

## ខ

| | | |
|---|---|---|
| ខ្ជាប់ខ្ជួន | (គុ. ឬកិ.វិ.) | : ខ្ជាប់ណាស់ មាំមួនណាស់ ។ |
| ខ្ជីខ្ជា | (កិ.វិ.) | : គឺធ្វើការ ឬនិយាយមិនម៉ត់ចត់ ។ |
| ខ្សៀវខ្សារ | (កិ.វិ.) | : ដែលទ្រហឹងអឹងកង ដោយសូរសម្រែកនៃសត្វបក្សី ។ |

## គ

| | | |
|---|---|---|
| គឃៀវ | (គុ. ឬកិ.វិ.) | : ដែលបែកញើសហៀរហូរសស្រាក់ ។ |
| គោរព | (ន.) | : សេចក្តីឱនលំទោន ដំណើរប្រតិបត្តិតាម សេចក្តីកោតក្រែង ។ |

គោម (ន.) : ឈ្មោះចានម្យ៉ាងរាងក្រឡូម ធំជាងចានសម្ល ។

(ន.) : ប្រទីបមានទ្បត មានប្រឆេះ មានលំផូង មានច្រើនបែប ច្រើនយ៉ាង មានសណ្ឋានផ្សេងគ្នា សម្រាប់ប្រើកាន់លើកដាក់បាន ។

*ឧទាហរណ៍ :* គោមពណ៌ដុតបំភ្លឺពេលចូលឆ្នាំ ។

## ឃ

ឃោរឃៅ (គុ.) : កាចខ្លាំងឥតមានមេត្តាប្រណី ។

## ង

ងងឹត (គុ.) : ទីទៃពីភ្លឺ ដែលឥតមានពន្លឺ : យប់ងងឹត ខែងងឹត ងងឹតភ្នែក ។

## ច

ចង្រៃ (ន.) : ឧបទ្រព ដែលបណ្ដាលឱ្យមានទុក្ខ មានកង្វល់ ។

ចន្ទ្រា (ន.) : លោកខែ ព្រះចន្ទ ។

ចរាចរណ៍ (ន.) : ការធ្វើដំណើរទៅមក ។

ចាក់ត្លុក (កិ.) : លោតក្រមាច់ក្រមើម ។

ចេចចាច (ន.) : សូរភាសាបក្សី មានគ្រលេងគ្រលោងជាដើម ។

ចេតិយ (ន.) : ទីដែលគេគោរពបូជា ។

ចែកឋាន (កិ.) : ស្លាប់ ។

ចៅហ្វាយ (ន.) : អ្នកដែលជាម្ចាស់លើគេ ។

ច្រែះ (ន.) : ស្នឹមលោហជាតិមានដែកជាដើម ។

ច្បារ (ន.) : សួនដំណាំ ទីដីដែលដាំបន្លែ ។

## ឆ

ឆត្រ (ន.) : ប្រដាប់មានដងឆ្អឹង គន្លឹះ ពាសសំពត់ សម្រាប់បើកកាន់បាំងកម្ដៅថ្ងៃ បាំងភ្លៀង ។

ឆ្គាំឆ្គង (គុ.) : មិនសមរម្យ មោះមៃបន្តិចបន្តួច ។

ឆៃយ៉ាំ (ន.) : ឈ្មោះភ្លេងមួយបែបគេច្រើនលេងកម្សាន្តក្នុងពិធីបុណ្យកឋិនឬបុណ្យផ្កា ។

## ជ

ជង្រុក (ន.) : កន្លែងដាក់ស្រូវ ក្រង់ស្រូវ ។

ជានិច្ច (គុ.) : ទៀង ពិត ម៉ែន រឿយៗ មិនដែលដាច់ ។

ជំនោរ (ន.) : ទឹកដែលជោរ ឈ្មោះនាំទឹកឱ្យជោរ ។

## ឈ

ឈើទាល (ន.) : ឈ្មោះឈើមួយប្រភេទមានជ័រសម្រាប់ធ្វើចន្លុះ ឬលាប ថិទ ពរទូកជាដើម ឯខ្លឹមសម្រាប់ជាគ្រឿងទព្វសម្ភារៈផ្សេងៗ ជាឈើមានប្រយោជន៍ ។

## ញ

ញ៉ីរ (កិ.) : កម្រើកទទាក់ កម្រើករន្ធាន់ ។

ញាតិ (ន) : អ្នកដែលរួមខ្សែលោហិតនឹងគ្នាខាងមាតា ឬខាងបិតា ។

ញ៉េះញ៉ោះ (កិ.ឬកិ.វិ.) : រឡេះរឡោះ ដោយលេង ឬដោយប្រឡែង ។

## ដ

ដឹង (ន.) : ប្រដាប់ប្រើប្រាស់ធ្វើដោយដែកមានដង មានផ្លែសម្រាប់ក្របែលពុះចាំងឈើ ។

ដំបៅងា (ន.) : ឈ្មោះដំបៅមួយប្រភេទ ។

## ឋ

ឋានន្តរ (ន.) : លំដាប់នៃទី មុខងារ ងារ ថ្នាក់ងារ ថ្នាក់កិត្តិយស ។

*ឧទាហរណ៍ :* លោកមានឋានន្តរជាអភិបាលក្រុង ។

## ឌ

ឌឺ (កិ.) : ផ្តើនឱ្យ និយាយផ្តើន ស្តីប្រដៅទៅវាឌឺឱ្យមកវិញ ឌឺឱ្យឈឺចិត្ត ។

(កិ.វិ.) : និយាយឌឺ ដេរឌឺ ។

## ឍ

ឍាមរា (ន.) : ក្ងាន ហង្ស ។

## ណ

ណាស់ (និ.) : ក្រៃពេក ក្រៃលែង លើសលប់ ខ្លាំង ។ ឧ. ល្អណាស់ អាក្រក់ណាស់ ។

## ត

តន្ត្រី (ន.) : គ្រឿងភ្លេងខ្មែរ គ្រឿងភ្លេងដេញ ដំ ផ្លុំ កូត ។

តាខេ (ន.) : ឈ្មោះគ្រឿងភ្លេងមួយប្រភេទមានខ្សែធ្វើដោយលួស មានស្នូករាងដូចក្រពើ ។

ត្រឈឹងត្រឈៃ (គុ.) : ម្លប់ជិតឈឹងសន្ទៃ ។

ត្លុក (ន.) : អ្នកកំប្លែង អ្នកក្រមាច់ក្នុងល្បែងរបាំដើម្បីឱ្យគេសើច ។

ត្លុម (ន.) : ឈ្មោះសត្វស្លាបមួយប្រភេទ មានជើងវែង សម្បុរដូចខ្វែកត្រោកមាន

វារិជជាតិជាចំណី ។

ផ្ទើក (កិ.) : កម្រើកញាក់សរសៃទ្រូងដល់ក បង្កើតឱ្យចេញខ្យល់មានទាំងសូរអឹកៗ ង៉ឹកៗមកផង ។

## ថ

ថ្នុរ (ន.) : ខ្សែចងអំបោះឆ្វាក់ សម្រាប់ត្បាញ ។

ថ្គក់ (កិ.) : កោះ កាវ ដោយតម្លក់ ។

ថ្លាឈ្វេង (គុ.) : ដែលជ្រះស្រឡះឥតមន្ទិល ។

ថ្លុក (ន.) : ទីដីក្រហូងដែលដក់ទឹកភ្លៀងក្នុងរដូវវស្សា តែតូចជាងត្រពាំង ច្រើនកើតដោយសារក្របីដេក ។

## ទ

ទន់ល្មើយ (គុ.) : ដែលទន់ល្មៃ ទន់ដូចសំឡី ។

ទន្ទ្រាំ (កិ.) : ដាក់ជើងច្រំខ្លាំងៗ ។

ទន្ទ្រាន (កិ.) : ពារពានលើ រុករានលើ ។

ទិដ្ឋភាព (ន.) : ភាពនៃអ្វីៗដែលគេបានឃើញ បានជួបប្រទះ ។

ទុក្ខ (ន.) : សេក្តីព្រួយ សេចក្តីលំបាក ។

ទ្រនំ (ន.) : ទីដែលសត្វស្លាបតែងទំ ។

ទេសភាព (ន.) : ដែលប្រកបដោយធម្មជាតិមាន ទឹក ដី ព្រៃព្រឹក្សាជាដើម ។

ទ្រព្យ (ន.) : វត្ថុ ធនធាន សម្បត្តិ ។

ទ្រគោះ (កិ.វិ. ឬគុ.) : ដែលច្រឡោះបោះ គំរោះគំរើយ ។

## ធ

ធនធាន (ន.) : ទ្រព្យរបស់ផ្សេងៗដែលគង់នៅ ។

ធម្មតា (ន.) : ប្រក្រតី អ្វីៗដែលតែងមានមក ទំនៀម ទម្លាប់ ។

ធម្មជាតិ (ន.) : អ្វីៗដែលកើតឡើងឯកឯង ។

ធុរៈ (ន.) : រវល់ ដំណើរជំពាក់ដោយកិច្ចការនីមួយៗ ។

ធូប (ន.) : គ្រឿងក្រអូបសម្រាប់អុជបង្ហុយផ្សែងជាគ្រឿងបូជា ។

## ន

ននោង (ន.) : ឈ្មោះវល្លិ៍ដំណាំឡើងទ្រើងមានផ្លែជាអាហារ មានច្រើនប្រភេទគឺ ននោងជ្រុង ននោងទេស ននោងសាញជាដើម ។

## ប

បន្តោង (ន.) : ឈ្មោះគ្រឿងអលង្ការដាក់គោងជាមួយខ្សែ ក សម្រាប់ស្ត្រី ។

បន្ទោបង់ (កិ.) : បញ្ចេញចោល ។

បវេសនកាល (ន.) : ថ្ងៃចូលរៀនដំបូងនៅដើមឆ្នាំសិក្សា ។

បង្គំ (កិ.) : សំពះ ឬក្រាបសំពះទៅរកអ្នកដែលគួរគោរព ។

បិណ្ឌ (ន.) : ការប្រមូលឱ្យមូល ឬពូនឱ្យជាដុំ ដុំ ការចិញ្ចឹមជីវិត ។

បុរាណ (គុ.) : ចាស់ ដែលកើតមានមុន ដែលមានយូរហើយ ដែលធ្លាប់មានពីព្រេងនាយ ។

(ន.) : កាលពីបុរាណ បុរាណពីដើម ។

ប្រាជ្ញ (ន.) : សេចក្តីដឹងទូទៅ សេចក្តីដឹងកើតអំពីការរៀន ស្តាប់ គិត សួរ ការដឹងច្បាស់នូវសេចក្តីពិត ។

ប្រពៃ (កិ.វិ. ឬគុ.) : ល្អ ស្រួល ត្រឹមត្រូវ ។

ប្រយុទ្ធ (កិ.) : ច្បាំងគ្នាតស៊ូគ្នាទៅវិញទៅមក ។

ប្រាកដ (គុ.) : ជាក់ច្បាស់មែន ។

ប្រជាប្រិយ (គុ.) : ដែលជាទីស្រឡាញ់របស់ប្រជាជន ។

បង្ហូរ (កិ.) : ធ្លាក់ភ្លៀង ។

ប្រស្នា (ន.) : ពាក្យឬសេចក្តីដែលមានអាថ៌កំបាំង ចំណោទ ។

ប្រយ័ត្ន (ន.) : ការប្រុងដោយមិនធ្វេសប្រហែស ។

បដិសេធ (កិ. ឬន.) : មិនយល់ព្រម លែងយកជាការ ។

## ផ

ផ្តាសាយ (ន.) : ឈ្មោះរោគមួយប្រភេទមានអាការបណ្តាលឱ្យកណ្តាស់ ឱ្យហូរហៀរទឹកសម្បោរ ។

ផ្កាភ្ញី (ន.) : ផ្កាកម្រង និងផ្កាវាយផ្សេងៗ ។

ផ្ចិតផ្ចង់ (កិ.) : យកចិត្តទុកដាក់ ប្រិតប្រៀន ។

ផ្តែផ្តាំ (កិ.) : ផ្តាំហើយ ផ្តាំទៀត ។

ផ្ទៃ (ន.) : ពោះ ។

ផ្សំផ្គុំ (កិ.) : ផ្សំឱ្យបានគ្នាជាប្តីប្រពន្ធ ។

| | | |
|---|---|---|
| ផល | (ន.) : | សម្បត្តិ សេចក្ដីរុងរឿង ។ |
| ផែ | (ន.) : | រាន ឬក្បួនបណ្ដែតទឹក សម្រាប់អែបនាវាឱ្យងាយចុះឡើង ។ |
| ផ្ដាប់ផ្ដុន | (កិ.) : | ខំផ្ដាប់ដោយយកចិត្តទុកដាក់ មិនឱ្យឃ្លើសចិត្ត ឬទាស់ចិត្ត ។ |

## ព

| | | |
|---|---|---|
| ពន្យារ | (កិ.) : | ធ្វើឱ្យយារ ធ្វើឱ្យយឺតយូរ ។ |
| ពលសេនា | (ន.) : | ពួកទាហាន ពួកពលកងទ័ព ។ |
| ពិណ | (ន.) : | ចាប៉ី ។ |
| ពិភពលោក | (ន.) : | សកលលោកទាំងមូលជាឋានរស់នៅរបស់មនុស្សសត្វទាំងពួង ។ |
| ព័ទ្ធ | (កិ.) : | ចង ចងវ័ណ្ឌជុំវិញ រុំជុំវិញ ចោមជុំវិញ ចោមស្ទាក់ជុំវិញមិនឱ្យមានផ្លូវចេញរួច ។ |
| ព្រាន | (ន.) : | អ្នកប្រមាញ់សត្វ ។ |
| ពាំ | (កិ.) : | នាំយកអ្វីៗដោយខាំនឹងមាត់ ។ |
| ព្រ័ត្រ | (ន.) : | ពួរ ឬខ្សែព្រ័ត្រក្អួចធ្វើដោយស្បែកគោ ។ |
| ពិចារណា | (ន.) : | ការត្រិះរិះ រំពឹងគិត ការគិតម៉ត់ចត់ ។ |
| ព្រំ | (ន.) : | ឈ្មោះកម្រាលពិសេសមួយប្រភេទវិចិត្រដោយពណ៌និងក្បាច់រចនា ។ |

## ភ

| | | |
|---|---|---|
| ភទ្របទ | (ន.) : | ឈ្មោះខែទី ១០ ខាងចន្ទគតិ ។ |
| ភ័យ | (ន.) : | សេចក្ដីខ្លាច ។ |
| ភាស៊ី | (ន.) : | ពន្ធទំនិញដែលរាជការដកហូតពីអ្នកលក់ ឬអ្នកនាំទំនិញចេញចូល ។ |
| ភ្ជុំបិណ្ឌ | (ន.) : | ឈ្មោះពិធីធ្វើទានមួយ ចាប់ពីថ្ងៃ០១រោចខែភទ្របទដល់ខែដាច់(១៥ថ្ងៃ) |
| ភ្នាក់ងារ | (ន.) : | បង្អែកការងារ អ្នកព្រនាក់ការងារ ។ |

## ម

| | | |
|---|---|---|
| មន្ត្រី | (ន.) : | អ្នកធ្វើការងារបម្រើរដ្ឋ ។ |
| មមាញឹក | (កិ. ឬកិ.វិ.) : | ដែលញឹកខ្លាំង ដែលញឹកញាប់ពេកឥតស្រាក ។ |
| មាតុភូមិ | (ន.) : | ទីកន្លែងកំណើត ។ |
| ម៉ាស់ | (ន.) : | កំណាត់ពាក់ការពារច្រមុះកុំឱ្យធូលីហុយចូល ឬកុំឱ្យឆ្លងរោគ ។ |

## យ

| | | |
|---|---|---|
| យោធា | (ន.) : | ទាហានទាំងឡាយ ពួកទាហាន ។ |

## រ

រប៉ាំ (ន.) : ល្បែងច្រៀងរាំ ។

រនាប (ន.) : ចម្រៀកឫស្សី ឬឈើ ដែលយកមកក្រាលធ្វើគ្រែ ធ្វើផ្ទះជាដើម ។

រលករលេញ (កិ.) : រលកប្រដេញបន្តគ្នាឥតដាច់ ។

រលោងស្រិល (គុ.) : រលោងខ្មៅរលើប ។

រញ្ជួយ (កិ.) : កក្រើក រង្គើដោយទាញ ដោយអង្រួន ឬដោយខ្យល់បក់ ។

រាយមាយ (គុ. ឬកិ.វិ.) : ដែលពុំប្រាកដ ដែលមានអារម្មណ៍សាត់អណ្ដែតរាត់រាយ ។

រុងរឿង (គុ.) : ភ្លឺត្រចះត្រចង់ស្រស់ប៉ប្រិមឆើត ឆើតឆាយ ល្អប្រពៃថ្កុំថ្កើង ថ្កើងថ្កើន ប្រសើរ ថ្លៃថ្លា ។

ឫក ឬឫកពា (ន.) : មារយាទ កិរិយា បែបបទ សណ្ដាប់ធ្នាប់ ។

រ៉ាំរ៉ៃ (គុ.) : ត្រាំត្រែង យូរ ។

រំភើប (កិ.) : រញ្ជួយ ព្រឺព្រួច ។

រន្ធ (ន.) : រូង ប្រហោង ។

រហ័ស (គុ.កិ.) : ឆាប់រួសរាន់ លឿន ការប្រញាប់ដែលមិនយឺត ។

រឭក (ន.) : ការដឹងខ្លួន ការភ្ញាក់ដឹងខ្លួន ។

រានហាល (ន.) : រានវាលជាប់នឹងផ្ទះសម្រាប់ហាលអ្វីៗ ។

រុក្ខជាតិ (ន.) : ជាតិឈើ ឈើគ្រប់យ៉ាង ។

## ល

ល្បិច (ន.) : កលឧបាយ កិច្ចកល ស្នៀតសម្រាប់គេច ។

ល្ហឹងល្ហើយ (គុ.) : ល្ហល្ហេវក្រៃពេក ធំធេង ។

ល្មើយ (គុ.) : ដែលទន់ល្មៃ ទន់ដូចសំឡី ។

លទ្ធផល (ន.) : ផលដែលបានហើយ ផលសម្រេច ។

លា (ន.) : សត្វពាហនៈមួយប្រភេទមានរាងដូចសេះ តែមានត្រចៀកវែងជាងសេះ ។

លាតសន្ធឹង (គុ.) : ក្រាលសន្ធឹង ត្រដាងវែងអន្លាយ ។

ល្វាចេក (ន.) : ឈ្មោះបក្សីតូចមួយប្រភេទសម្បុរខ្មៅលាយសបន្តិចត្រង់ស្លាប ។

ល្វែង (ន.) : ប៉ែក សង្កាត់ ចន្លោះជួរសសរ ។ *ឧទាហរណ៍ :* ល្វែងផ្ទះ ។

## វ

វង្វេង (កិ.) : ភ្លេច ឬភ័ន្តស្មារតី ភ័ន្តផ្លូវ ភ័ន្តដំណើរគ្នា ច្រឡំចាំមិនបាន ។

វ័យ (ន.) : អាយុ កំណត់អាយុ ។

វារ (កិ.) : លូនដោយប្រវា ។

វិចិត្រ (គុ.) : ល្អប្លែក ។

វស្សា (ន.) : រដូវភ្លៀង ។

វិជ្ជា (ន.) : ចំណេះ ការចេះដឹង ។

វិថី (ន.) : ផ្លូវ ។

វេន (ន.) : កាលកំណត់ ដំណើរផ្លាស់គ្នា ។

## ស

សកម្មភាព (ន.) : ការបំពេញមុខការងារ ការកម្រើក ។

សង្គ្រាម (ន.) : ការច្បាំងគ្នា ។

សញ្ជឹង (កិ. ឬកិ.វិ.) : ទ្រឹងជញ្ជឹងគិតដោយអាការក្រៀមក្រំ ។

សាគរ (ន.) : សមុទ្រ ។

សារភាព (ន.) : ដំណើរ ឬសេចក្ដីពិត ។

សារមន្ទីរ (ន.) : កន្លែងទុកវត្ថុបុរាណ ។

សម័យ (ន.) : កាល ពេលវេលា ។

សមាជិក (ន.) : អ្នកចូលរួម ។

សម្បត្តិ (ន.) : របស់ទ្រព្យបរិបូណ៌ ។

សម្បុរ (ន.) : ពណ៌សម្រាប់ប្រើចំពោះមនុស្ស និងសត្វ ។

សម្បូរ (គុ.) : ច្រើន ។

សម្ផស្ស (ន.) : រូបរាង ពណ៌សម្បុរលក្ខណៈ ។

សិរី (ន.) : សេចក្ដីសុខ ចម្រើន ។

ស៊យ (កិ.) : ជួបហេតុអាក្រក់ចង្រៃ ។

សសរ (ន.) : គ្រឿងសម្រាប់ទ្រ ។ *ឧទាហរណ៍ :* សសរផ្ទះ ។

សាខា (ន.) : មែកបែកគ្នា ។

ស្នង (ន.) : តំណាង ។

ស្នាក់ការ (ន.) : ទីកន្លែងណាត់ជួបជុំ ។

សុចរិត (ន.) : ការប្រព្រឹត្តល្អ ។

## អ

អាសា (ន.ឬគុ.) : ការជួយឈឺឆ្អាលដោយស្ម័គ្រចិត្តឥតអ្នកណាបង្ខំ ។

អារម្មណ៍ (ន.) : គ្រឿងទាក់ទាញចិត្ត ។

អីវ៉ាន់ (ន.) : វត្ថុ ឬរបស់នេះខ្លះ នោះខ្លះពុំចេញឈ្មោះរបស់ដែលហៅដោយរួបរួម ។

អំបែង (ន.) : បន្ទះបំណែកនៃក្អមឆ្នាំងកែវចានជាដើម ។ ក្អមដី ឬឆ្នាំងដីដែលគោះបោះត្រង់ក្អែងម្ខាងឱ្យមានចន្លោះធំល្មមដល់ការសម្រាប់លីងអ្វីៗ ។

អធ្យាស្រ័យ (ន.) : ការអត់ឱនឱ្យគ្នាទៅវិញទៅមក ការអត់ធ្មត់ ។

(ន.) : សភាវៈដែលដេកអាស្រ័យនៅក្នុងចិត្តគឺបំណង ចំណង់ចិត្ត ចំណុចចិត្ត អារម្មណ៍ ។

អន្ទាក់ (ន.) : ប្រដាប់ធ្វើដោយខ្សែ ឬដោយចម្រៀកផ្តៅជាដើមមានក្រវិលរូតបាន សម្រាប់ទាក់ សម្រាប់ដាក់ឱ្យជាប់ សត្វទ្វេបាទ ចតុប្បាទជាដើម ។

អាស្រ័យ (ន.) : ទីតាំង ទីពឹងពំនាក់ ។

អាវុធ (ន.) : គ្រឿងប្រហារ ឬគ្រឿងចម្បាំងផ្សេងៗដែលទីទៃពីសស្ត្រា ។

ឦសាន (ន.) : ទិសខាងកើតឆៀងខាងជើង ។

ឧកញ៉ា (ន.) : អ្នកមានបុណ្យសក្តិខ្ពស់ អ្នកមានទ្រព្យច្រើន ។

ឪទឹន (ន.) : ក្រឡមានមាត់តូចល្មម សម្រាប់ដាក់ទឹកត្រីជាដើម ។

ឯករាជ្យ (ន.) : ការឈ្នះ ជ័យជម្នះ ។

ឰដ៏អាកាស (ន.) : ក្នុងអាកាស លើអាកាស ។

ឱសថ (ន.) : ថ្នាំសម្រាប់ព្យាបាលរោគ ។

សម្គាល់ :

- (កិ.) កិរិយាសព្ទ
- (កិ.វិ.) កិរិយាវិសេស
- (គុ.) គុណនាម
- (គុ.វិ.) គុណនាមវិសេស
- (ន.) នាម
- (ឧ.) ឧទាហរណ៍
- (និ.) និបាតសព្ទ

## ស្រៈនិស្ស័យ

◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ

◌ៀ ◌េ ◌ែ ◌ៃ ◌ោ ◌ៅ ◌ុំ ◌ំ ◌ាំ ◌ះ

◌ុះ ◌េះ ◌ោះ

## ព្យញ្ជនៈនិងជើងព្យញ្ជនៈ



| ព្យញ្ជនៈ ពួក អ | | | | ព្យញ្ជនៈ ពួក អ៊ | | | |
|---|---|---|---|---|---|---|---|
| ក្ក | ខ្ខ | | | គ្គ | ឃ្ឃ | ង្ង | |
| ច្ច | ឆ្ឆ | | | ជ្ជ | ឈ្ឈ | ញ្ញ | |
| ដ្ដ | ឋ្ឋ | ណ្ណ | | ឌ្ឌ | ឍ្ឍ | | |
| ត្ត | ថ្ថ | | | ទ្ទ | ធ្ធ | ន្ន | |
| ប្ប | ផ្ផ | | | ព្ព | ភ្ភ | ម្ម | |
| ស្ស | ហ្ហ | ឡ្ឡ | អ្អ | យ្យ | រ្រ | ល្ល | វ្វ |



## ស្រៈពេញតួ

អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ

ឭ ឮ ឯ ឰ ឱ ឳ

**បោះពុម្ពដោយ គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

13 107
IBC INTERNATIONAL BOOK CENTER
$ 3.50
978